សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des sciences Economiques

Royal University of law and Economics


## សារណាបញ្ចប់ការសិក្សា

# មូលហេតុ និងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងនិងស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា ៖ **ឡុង ដាវីន**

លោក ៖ **ថេង ជួងថេង**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**


ថ្នាក់ **បរិញ្ញាបត្រនីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ឡុង ដាវីន** និងខ្ញុំបាទឈ្មោះ **ថេង ជួងថេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងនូវសេចក្តីកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត៖

- សូមលើកអញ្ជលីលំឱនកាយវាចាចិត្តគោរពដល់ លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើតចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ទាំងស្មារតី និងថវិកាឲ្យកូនបានរៀនសូត្ររហូតដល់ពេលបច្ចុប្បន្ននេះ ។
- ឯកឧត្តម **លុយ ចន្ថា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងខ្ញុំចូលសិក្សានៅក្នុងសាកលវិទ្យាល័យនេះ និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ ។
- លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ជាសាស្ត្រាចារ្យណែនាំ ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងមមាញឹកក្នុងការបង្ហាត់បង្រៀនផ្តល់ការណែនាំ ថែមទាំងបានផ្តល់ឯកសារមួយចំនួនដល់យើងខ្ញុំ ដើម្បីរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះឡើង ។
- ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ និងបុគ្គលិកសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ ។
- សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតថែមទៀត ចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញ ព្រមទាំងទស្សនៈវិទូល្បីក្នុងលោក ដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវក្នុងពេលកន្លងមក ។

សូមទទួលនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត និងមិនអាចបំភ្លេចបាន ចំពោះឧបការគុណដ៏ធំធេងអំពីយើងខ្ញុំ ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរជូនដល់ លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមបានប្រកបដោយជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ជាបឋម នាងខ្ញុំ **ឡុង ដារ៉ាវីន** និង ខ្ញុំបាទ **ថេង ជួងវេង** សូមស្វាគមន៏ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេស សិស្ស និស្សិត ជាទីរាប់អាន ព្រមទាំងសាស្ត្រចារ្យជាទីគោរព ។

ក្នុងនាមជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងរាជធានីភ្នំពេញ បានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទស្តីពី **មូលហេតុនិងនីតិវិធីនៃការលត់បណ្តឹងអាជ្ញា** ដែលត្រូវបានទទួលនូវការគាំទ្រ និងការជួយលើកទឹកចិត្តបង្ហាត់បង្រៀនកែតម្រូវយ៉ាងពេញទំហឹងពីសំណាក់ លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រចារ្យផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។

យើងខ្ញុំទាំងពីរបានសម្រេចជ្រើសរើសយកប្រធានបទនេះ មកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឡើងក្នុងគោលបំណង គឺដើម្បីចូលរួមជាវិភាគទានដ៏សំខាន់នៅក្នុងដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាបច្ចុប្បន្ន ហើយក៏ទុកជាឯកសារសម្រាប់បំពេញនូវតម្រូវការរបស់និស្សិតជំនាន់ក្រោយៗ និងជួយដល់លោកអ្នកទាំងអស់ ដែលបានធ្វើការសិក្សាស្រាវជ្រាវជំនាញវិជ្ជាជីវៈនីតិសាស្ត្រ ជាពិសេសពួកយើងខ្ញុំផ្ទាល់ក៏ចង់ដឹង និងចង់សិក្សាឲ្យបានស៊ីជម្រៅច្បាស់លាស់បន្ថែមទៀត អំពីខ្លឹមសារ និងអត្ថន័យ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាក់ស្តែងទាក់ទងនឹងប្រធានបទនេះផងដែរ ។

ម្យ៉ាងវិញទៀត នៅក្នុងការស្រាវជ្រាវ និងចងក្រងឯកសារនេះឡើង ប្រាកដជាមាននូវចំណុចខ្វះខាតផ្នែកខ្លឹមសារ និងកំហុសឆ្គងខាងអក្ខរាវិរុទ្ធជាក់ជាមិនខាន ។ ដូច្នេះយើងខ្ញុំសង្ឃឹមថា រាល់កំហុសឆ្គងទាំងឡាយណាដែលកើតមានឡើងក្នុងឯកសារនេះនឹងទទួលបានការអធ្យាស្រ័យ និងការអភ័យទោសពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋានជាក់ជាមិនខាន ។

យើងខ្ញុំសូមទទួលរងចាំនូវការរិះគន់ និងកែតម្រូវ ក្នុងន័យស្ថាបនា ពីសំណាក់ អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់គ្រប់ពេលវេលា ។

ជាទីបញ្ចប់នេះ សូមជូនពរដល់ អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់រូបឲ្យជួបប្រទះតែភាពសុខដុមរមនា រុងរឿងថ្កុំថ្កើង និងមានសុភមង្គលជានិច្ចនិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ ។

# មាតិកា


ទំព័រ

**សេចក្ដីផ្ដើម.....01**

**ជំពូកទី១**

**ស្ថានភាពទូទៅនៃបណ្ដឹងអាជ្ញា**

**ផ្នែកទី១ ដំណើរការនៃបណ្ដឹងអាជ្ញា.....0៦**

១.១ និយមន័យ..... 0៦

១.២ ប្រភេទនៃបណ្ដឹងអាជ្ញា.....0៦

១.២.១ បណ្ដឹងអាជ្ញា..... 0៦

១.២.១.១ គោលការណ៍ទូទៅ.....0៧

១.២.១.២ អញ្ញត្រកម្ម.....0៧

១.២.១.៣ ការអនុវត្តបណ្ដឹងអាជ្ញា.....0៧

១.២.១.៤ ការចោទប្រកាន់នៅចំពោះមុខយុត្តាធិការស៊ើបសួរ.....0៨

១.២.១.៥ ការចោទប្រកាន់ទៅចំពោះមុខយុត្តាធិការជំនុំជម្រះ.....0៨

១.២.២ បណ្ដឹងរដ្ឋប្បវេណី..... 0៨

**ផ្នែកទី ២ អាជ្ញាយុកាល..... 0៩**

២.១ អាជ្ញាយុកាលនៃបណ្ដឹងព្រហ្មទណ្ឌ.....0៩

២.១.១.អាជ្ញាយុកាលនៃបទល្មើស.....0៩

២.១.១.១អំពើប្រល័យពូជសាសន៍ .....១១

២.១.១.២ អំពើប្រឆាំងនិងមនុស្សជាតិ.....១១

២.១.១.៣ អំពើដែលជាឧក្រិដ្ឋកម្មសង្គ្រាម.....១២

២.១.១.៤ អំពើដែលជាបទឧក្រិដ្ឋផ្សេងទៀត.....១៣

២.១.២.មូលហេតុទូទៅដែលមានការប៉ះពាល់ការអនុវត្តទោស.....១៤

២.១.២.១ អាជ្ញាយុកាលនៃទោសព្រហ្មទណ្ឌ.....១៤

២.២.អាជ្ញាយុកាលនៃបណ្ដឹងរដ្ឋប្បវេណី.....១៥

**ជំពូកទី២**

**មូលហេតុនៃការរលត់បណ្ដឹងអាជ្ញា**

**ផ្នែកទី ១ មូលហេតុទូទៅ.....២០**

១.១ មរណភាពនៃជនល្មើស.....២០

១.២ ការផុតអាជ្ញាយុកាល............ .២១
១.២.១ ការផុតអាជ្ញាយុកាលនៃបទល្មើស............២១
១.២.២ ការផុតអាជ្ញាយុកាលនៃទោស............២១
១.៣ ការលើកលែងទោសជាទូទៅ............២២
១.៣.១ អានុភាព............២២
១.៣.២ កាបន្ធូរបន្ថយទោស ការលើកលែងទោស និងការដោះលែងទណ្ឌិត............២៤
១.៣.៣ ចំពោះបុណ្យជាតិ............ ..២៦
១.៤.និរាករណ៍ច្បាប់ព្រហ្មទណ្ឌ............២៦
១.៤.១ និរាករណ៍នៃច្បាប់ដោយតុណ្ឌិភាព............២៧
១.៤.២ និរាករណ៍នៃច្បាប់ ដោយមានការបង្គាញខ្លួននៃច្បាប់ថ្មី............២៧
១.៥ អាជ្ញាអស់ជំនុំ............២៧
១.៥.១ គោលការណ៍មិនអាចជំនុំជម្រះពីរដងក្នុងរឿងតែមួយ............២៨
១.៥.១.១ ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល............២៩
១.៥.២ ផលវិបាកនៃការជំនុំជម្រះលើរឿងក្តីតែមួយ............៣០
១.៥.២.១ ករណីលើកលែង............៣០
១.៥.២.២ សិទ្ធិដឹងពីប្រភេទ និងបុព្វហេតុនៃការចោទប្រកាន់ និងកង្វះភស្តុតាង............៣០
**ផ្នែកទី២.មូលហេតុផ្សេងទៀតដែលនាំឲ្យរលត់បណ្តឹងអាជ្ញា**............៣២
២.១ ការសម្របសម្រួលជាមួយរដ្ឋ............៣២
២.២ ការដកពាក្យបណ្តឹង............៣៣
២.៣ ការបង់ប្រាក់ពិន័យសរុបដើម្បីសម្របសម្រួសជាមួយរដ្ឋ............៣៣

## ជំពូកទី៣
## នីតិវិធីរលត់បណ្តឹងអាជ្ញា

**ផ្នែកទី១ ការតម្កល់រឿងទុកឥតចាត់ការ**............៣៩
១.១ នត្ថិភាពនៃបទល្មើស............៣៩
១.២ អវត្តមាននៃបទល្មើសដែលពិបាកចោទប្រកាន់ ............៤០
១.៣ បទល្មើសមានលក្ខណៈមិនគ្រប់គ្រាន់............៤០
១.៤ មូលហេតុគតិយុត្តផ្សេងទៀត............៤០
១.៤.១ អភ័យឯកសិទ្ធិ............៤១
១.៤.២ អនិយ័តភាពនៃកិច្ចនីតិវិធី............៤១

១.៤.៣ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស..................................................៤១
១.៤.៤ ការចោទប្រកាន់មិនផ្តល់ប្រយោជន៍...........................................................៤៣
**ផ្នែកទី២ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ.................................................៤៤**
២.១ ទម្រង់ការនៃដីកាតម្កល់រឿងទុកឥតចាត់ការ.......................................................................៤៥
២.២ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ.........................................................................៤៥
២.៣ បច្ច័យនៃការតម្កល់រឿងទុកឥតចាត់ការ............................................................................៤៦
២.៤ យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ.........................................................៤៧
**សេចក្តីសន្និដ្ឋាន**...............................................................................................៤៩
**អនុសាសន៍...............................................................................................៥១**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅក្នុងការគ្រប់គ្រងប្រទេសមួយ ដើម្បីទទួលបានសន្តិសុខ សណ្តាប់ធ្នាប់ យុត្តិធម៌ តម្លាភាព និងការអភិវឌ្ឍជឿនលឿនលើគ្រប់វិស័យ ប្រទេសនោះអាចទាមទារឲ្យមានការបង្កើតច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលជាការធានាប្រសិទ្ធិភាពនៃការអនុវត្តច្បាប់នៅក្នុងប្រទេសនោះផងដែរ។ លើសពីនេះទៅទៀត ដើម្បីបម្រើនិងការពារផលប្រយោជន៍សាធារណៈ ច្បាប់ទាំងនោះត្រូវតែអនុវត្តដោយត្រឹមត្រូវមិនលំអៀង និងឈរលើភាពយុត្តិធម៌ គោលការណ៍គោរពសិទ្ធិមនុស្ស ជាពិសេសគឺជួយដល់ជនស្លូតត្រង់ដែលទទួលរងគ្រោះជាដើម។ ដូច្នេះទើបបានជាតម្រូវឲ្យមានប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ដើម្បីពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនប្រព្រឹត្តអំពើអសីលធម៌។

បើក្រឡេកមកមើលសង្គមសម័យទំនើប ឬយុគសម័យទំនើបវិញ ឃើញថាប្រព័ន្ធយុត្តិធម៌ នៅក្នុងប្រទេសកម្ពុជាត្រូវបានគេបែងចែកជាន់ និងថ្នាក់ ទន្ទឹមនឹងការបែងចែងប្រព័ន្ធយុត្តិធម៌នេះដើម្បីដំណើរការដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនិងបទល្មើសព្រហ្មទណ្ឌនោះ អ្នកតាក់តែងវិធានច្បាប់ បានតាក់តែងនូវវិធានច្បាប់ដើម្បីឲ្យការអនុវត្តដូចជាមន្ត្រីមានសមត្ថកិច្ច នៅតាមតុលាការអនុវត្តទៅតាមលំហូរនៃវិធាននីតិវិធី ដែលមានប្បញ្ញត្តិទុកជាស្រេចក្នុងច្បាប់ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ជនដែលត្រូវទទួលរងនូវការចោទប្រកាន់ ឬជនរងគ្រោះនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាមាត្រា១៣១ បានចែងថា "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា"។ មានន័យថាព្រះរាជអាជ្ញា គឺជាភាគីនៃបណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌដែលមានតួនាទីតំណាងឲ្យរដ្ឋ តំណាងឲ្យសង្គម ការពារផលប្រយោជន៍ទូទៅ និងធ្វើបណ្តឹងអាជ្ញាចោទប្រកាន់ទៅតុលាការឲ្យផ្តន្ទាទោសចំពោះជនដែលប្រព្រឹត្តបទល្មើស។

មុនពេលក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឆ្នាំ២០០៧ប្រកាសឲ្យប្រើ តំណាងអយ្យការមានតែជម្រើសនៃការចោទប្រកាន់តែមួយប៉ុណ្ណោះគឺ ការចោទប្រកាន់បញ្ជូនសំណុំរឿងឲ្យស៊ើបសួរ ហើយព្រះរាជអាជ្ញាត្រូវគោរពនូវគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ មានន័យថានៅពេលណាមានបទល្មើសគឺព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ជាច់ខាត។ ថ្វីត្បិតតែនីតិវិធីនេះ មានភាពល្អិតល្អន់បន្តិចក៏ដោយដែលទាមទារឲ្យតុលាការត្រូវតែធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីត្រួតពិនិត្យលើយុត្តាធិការស៊ើបអង្កេតជៀសវាងកំហុសឆ្គងណាមួយដែលកើតក្នុងអំឡុងពេលស៊ើបអង្កេត និងបញ្ហាខ្វះចន្លោះនានាដែលជាកត្តានាំឲ្យបាត់ប្រយោជន៍ដល់ភាគីជនរងគ្រោះ និងភាគីជនជនជាប់ចោទ។ ប៉ុន្តែដោយសារតែនៅពេលដែលមានបទល្មើសកើតឡើង គឺព្រះរាជអាជ្ញាត្រូវតែធ្វើការបើការស៊ើបអង្កេត លើគ្រប់បទល្មើសដែលខ្លួនយល់ថាជាអំពើប៉ះពាល់ដល់សង្គម។

ប្រសិនបើធ្វើការពិនិត្យឲ្យស៊ើបជម្រៅ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ជាជម្រើសដល់ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ និង ធ្វើដីកាសម្រេចរលត់បណ្តឹងអាជ្ញា ឬសម្រេចធ្វើបណ្តឹងសុំចោទប្រកាន់យុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ដើម្បីស្វែងរកឲ្យឃើញអំពីអត្ថិភាពនៃបទល្មើស ដើម្បីផ្តន្ទាទោសជនល្មើសតាមច្បាប់។ នេះគឺបានស្តែងឲ្យគេឃើញថាក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧នេះ គោរពគោលការណ៍កាលានុវត្តភាពនៃចោទប្រកាន់ ដែលបើកសិទ្ធិឲ្យព្រះរាជអាជ្ញាមានសិទ្ធិថ្លឹងថ្លែងពីបទល្មើស និងការប៉ះពាល់ដល់សង្គម ថាតើគួរចោទប្រកាន់ ឬសម្រេចតម្កល់រឿងនោះ ទុកឥតចាត់ការ ដើម្បីឆ្លើយតបទៅនិងវិបត្តិដែលជួបប្រទះខាងលើ។ ហើយការផ្តល់ជម្រើសឲ្យព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬអាចសម្រេចធ្វើការចោទប្រកាន់ គឺជាករណីថ្មីមួយរបស់ព្រះរាជអាជ្ញាតែជម្រើសនេះមានភាពស្មុគស្មាញជាងនីតិវិធីនៃច្បាប់ចាស់ ដែលតម្រូវឲ្យព្រះរាជអាជ្ញាត្រូវតែយល់ច្បាស់អំពីនីតិវិធីនិងលក្ខខណ្ឌចាំទាំងឡាយដែលទាក់ទងនិងការប្រើប្រាស់ជម្រើសនីមួយៗ។

ដូចបានរៀបរាប់ខាងលើ ការផ្តល់ជម្រើសឲ្យព្រះរាជអាជ្ញា គឺជាករណីដ៏ថ្មីមួយសម្រាប់ព្រះរាជអាជ្ញាដោយឆ្លងកាត់តាមការស្រាវជ្រាវផ្អែកតាមទ្រឹស្តីទាំងក្រមនីតិវិធីចាស់ និងក្រមនីតិវិធីថ្មីនេះ ខ្ញុំបាទ/នាងខ្ញុំ យល់ឃើញថាមានករណីយល់ខុសគ្នាច្រើនណាស់ចំពោះការប្រើប្រាស់នីតិវិធីថ្មីនៅស្ថាប័នអយ្យការនេះ។

**១). លំនាំបញ្ហានៃការស្រាវជ្រាវ**

អង្គការអយ្យការ ថ្វីបើជាតួអង្គមួយយ៉ាងសំខាន់នៅក្នុងដំណើរកិច្ចនីតិវិធីព្រហ្មទណ្ឌក៏ដោយប៉ុន្តែការយល់ដឹងអំពីស្ថាប័ននេះហាក់ដូចជានៅមានភាពយល់ដឹងនិងមានកម្រិតនៅឡើយ។ នៅក្នុងស្ថាប័នមួយនេះ គឺមានអ្នកតំណាងដែលយើងស្គាល់ថា ជាព្រះរាជអាជ្ញាដែលជាអ្នកតំណាងឲ្យសង្គម និងតំណាងឲ្យប្រទេសជាតិយើងក៏ជាម្ចាស់នៃបណ្តឹងអាជ្ញាផងដែរ។

ដូចនេះដើម្បីស្វែងយល់បន្ថែមអំពីមូលហេតុ និងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញា សារណាមួយនេះ និងរៀបរាប់ពី ស្ថាប័នដែលអនុវត្តនេះទៅតាមកម្រិតថ្នាក់បរិញ្ញាបត្រ ដើម្បីជាការចែករំលែកចំណេះដឹងជូនដល់មិត្តអ្នកអានទាំងអស់ដែលមានស្មារតីសិក្សា ជាពិសេសសម្រាប់មិត្តណាដែលចង់ក្លាយខ្លួនទៅជាអនុវត្តនៅក្នុងស្ថាប័នអយ្យការនាថ្ងៃអនាគត។ យើងសង្ឃឹមថាសារណាមួយនេះ អាចចូលរួមចំណែកពុទ្ធិដ៏តូចមួយសម្រាប់ជាការជួយដល់សង្គម និងពង្រឹងដល់ភាពត្រឹមត្រូវនៃការអនុវត្តនីតិវិធីក៏ដូចជាការដឹកនាំនីតិវិធី និងការចូលរួមរបស់តំណាងអយ្យការក្នុងដំណាក់ចោទប្រកាន់ មួយនេះ។

**២). ចំណោទបញ្ហានៃការដោះស្រាយ**

ដើម្បីជាការយល់ដឹងឲ្យកាន់តែច្បាស់នូវ មូលហេតុ និងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញានេះ យើងត្រូវតែដឹងថា៖

- តើអ្វីទៅជាបណ្តឹងអាជ្ញា?

- តើដំណើរការនៃបណ្តឹងអាជ្ញាមានលក្ខណៈយ៉ាងណាខ្លះ?

- តើមានមូលហេតុយ៉ាងណាដែលធ្វើឲ្យអយ្យការសម្រេចរលត់បណ្តឹងអាជ្ញា តើការសម្រេចនេះមាននីតិវិធីអ្វីខ្លះ?

- តើបែបបទនិងការយល់ឃើញនូវនីតិវិធីអ្វីខ្លះដែលធ្វើឲ្យព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ ហើយការសម្រេចតម្កល់នេះមានផលវិបាកអ្វីខ្លះដល់ការអនុវត្តនីតិវិធី?

### ៣). គោលបំណងនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ មានគោលបំណងក្នុងការចែករំលែកនូវចំណេះដឹងខ្លះៗ ឬមួយផ្នែកអំពីប្រធានបទស្តីពី មូលហេតុ និងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញា ថាតើមូលហេតុ និងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញានេះមានសារៈសំខាន់យ៉ាងណាខ្លះ ក្នុងប្រព័ន្ធតុលាការ ឬវិស័យយុត្តិធម៌? តើអ្វីទៅជាមូលហេតុ និងនីតិវិធីនៃការរំលត់នៃបណ្តឹងអាជ្ញា ? តើមូលហេតុនេះបានចូលរួមអ្វីខ្លះដល់សង្គម និងតុលាការ? ហើយខ្ញុំបាទ/នាងខ្ញុំជឿជាក់ថា ការស្រាវជ្រាវនេះជាវណ្ណកម្មមួយសម្រាប់ជាជំនួយដល់និស្សិត ដែលមានបំណងចង់សិក្សាស្វែងយល់ពី មូលហេតុ និងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញានេះ ដើម្បីជាប្រយោជន៍ដល់ការប្រកបវិជ្ជាជីវៈក្នុងវិស័យតុលាការ។

### ៤).ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់ការស្រាវជ្រាវនេះមានដែនកំណត់ផ្តោតទៅលើការសិក្សាទាក់ទងនិង មូលហេតុ និងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញាទាំងឡាយណាដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងសិក្សាអំពីការចូលរួមរបស់អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ក្នុងកិច្ចដំណើរការនៃរឿងក្តីព្រហ្មទណ្ឌដែលមានដូចជា ស៊ើបអង្កេត ការចោទប្រកាន់ កិច្ចស៊ើបសួរ ការជម្រះក្តី និងការអនុវត្តទោសព្រហ្មទណ្ឌ។ ចំពោះការសិក្សាគឺផ្តោតតែទៅលើមូលហេតុ និងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញា ដែលស្ថិតនៅក្នុងដំណាក់កាលចោទប្រកាន់។

### ៥).សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានអត្ថប្រយោជន៍ជាជំនួយស្មារតី ជាពុទ្ធិ និងពង្រឹងចំណេះដឹង ក៏ដូចជាការជំនួយដល់ធនធានចំណេះដឹង នៅក្នុងប្រធានបទស្តីពី មូលហេតុ និងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញា។ ជាពិសេសមិត្តអ្នកអានគ្រប់រូបអាចស្វែងយល់អំពីតួនាទី និងកិច្ចការដែលពាក់ព័ន្ធនិងមូលហេតុ និងនីតិវិធីនៃការរលត់បណ្តឹងអាជ្ញា ដែលមានលក្ខណៈជាទ្រឹស្តីរបស់អង្គការអយ្យការឲ្យកាន់តែមានភាពច្បាស់លាស់។

### ៦).វិធីសាស្រ្តនៃការស្រាវជ្រាវ

ចំពោះការប្រមូលទិន្នន័យឯកសារផ្សេងៗដែលទាក់ទងនិងប្រធានបទនេះ ខ្ញុំបាទ/នាងខ្ញុំ និងព្យាយាម

ស្រាវជ្រាវជាលក្ខណៈទូទៅនៃប្រធានបទនេះនៅតាមប្រព័ន្ធអ៊ីនធើណេត ក៏ដូចជាការចុះស្រាវជ្រាវនៅតាមសាលាដំបូងរាជធានី-ខេត្ត ជាពិសេសការសាកសួរសុំយោបល់ពីសំណាក់សាស្ត្រាចារ្យផ្នែកច្បាប់ សិស្សច្បងមិត្តរួមការងារ និងមន្ត្រីនៅតាមសាលាដំបូងមួយចំនួន និងមន្ត្រីបម្រើការងារក្នុងស្ថាប័នរដ្ឋ។

**៧).រចនាសម្ព័ន្ធការស្រាវជ្រាវ**

សារណានេះត្រូវបានចែកចេញជា ០៣ ( បី ) ជំពូក ៖

**ជំពូកទី១៖** រៀបរាប់អំពីស្ថានភាពទូទៅនៃបណ្តឹងអាជ្ញា ? តើបណ្តឹងអាជ្ញាត្រូវមានសារៈសំខាន់អ្វីខ្លះត្រូវអនុវត្តដោយនរណា? តើដំណើរការនៃបណ្តឹងអាជ្ញានេះត្រូវមានអ្វីខ្លះ?

**ជំពូកទី២៖** រៀបរាប់អំពីមូលហេតុនៃការរលត់បណ្តឹងអាជ្ញា។

**ជំពូកទី៣៖** រៀបរាប់អំពីមូលហេតុ និងនីតិវិធីរលត់បណ្តឹងអាជ្ញា។ តើមានមូលហេតុអ្វីខ្លះដែលអាចឲ្យរលត់បណ្តឹងអាជ្ញាបាន?

# ជំពូកទី១
# ស្ថានភាពទូទៅនៃបណ្តឹងអាជ្ញា

ក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ញត្តិអំពីគោលការណ៍ទូទៅនៃបណ្តឹងអាជ្ញាដូចខាងក្រោមៈ បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ។ អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[1]។ តួនាទីអយ្យការត្រូវតែចែកឲ្យដាច់ពីមុខងារតុលាការ។ ព្រះរាជអាជ្ញាត្រូវដើរតួនាទីយ៉ាងសកម្មក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលនីត្យានុកូលភាពក្នុងការស៊ើបអង្កេតនានា ការអនុវត្តសាលក្រម និងការបំពេញតួនាទីផ្សេងៗទៀត ដោយតំណាងឲ្យផលប្រយោជន៍សាធារណៈ[2]។

បណ្តឹងអាជ្ញា ជានិច្ចកាលត្រូវផ្តួចផ្តើមឡើងដោយព្រះរាជអាជ្ញា ។ ជនរងគ្រោះណាម្នាក់នៃបទល្មើសណាមួយអាចដាក់ពាក្យបណ្តឹងទៅនគរបាល ឬទៅអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលមានភារកិច្ចបើកការស៊ើបអង្កេតបឋម[3] ។ អាជ្ញាធរ និងមន្ត្រីសាធារណៈទាំងអស់ ត្រូវមានភារកិច្ចរាយការណ៍អំពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលខ្លួនបានដឹង ទៅមន្ត្រីនគរបាលយុត្តិធម៌ ឬទៅព្រះរាជអាជ្ញា ( លើកលែងតែមន្ត្រីទាំងនោះមានកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ ឬច្បាប់បញ្ញត្តថាជាករណីលើកលែង ) ។[4]

ក្រមនីតិវិធីព្រហ្មទណ្ឌ ចែងអំពីអាជ្ញាយុកាលដែលត្រូវធ្វើចំពោះបណ្តឹងអាជ្ញា[5] ។ អាជ្ញាយុកាលនេះអាស្រ័យលើភាពធ្ងន់ធ្ងរនៃបទល្មើស[6] និងត្រូវ " ផ្តាច់ " នៅពេលកិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរត្រូវបានធ្វើឡើង ។

ចំណុចពិសេសមួយនៃប្រព័ន្ធច្បាប់កម្ពុជា ដែលអនុវត្តតាម ប្រព័ន្ធច្បាប់ស៊ីវិល ( ឬ ប្រព័ន្ធច្បាប់រ៉ូម៉ាណូហ្សឺម៉ានិក )[7] ដែលផ្ទុយទៅនិង ប្រព័ន្ធច្បាប់ខម៉ន់ឡ (ឬ ប្រព័ន្ធច្បាប់រ៉ូមាំង )[8] ។

ជាទូទៅ នៅពេលមានបទល្មើសមួយកើតឡើង អាចមានបណ្តឹងពីរផ្សេងគ្នាតែងតែកើតឡើង គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ។

នៅក្នុងប្រទេសកម្ពុជាយើង បានទទួលស្គាល់នូវបណ្តឹងទាំងពីរប្រភេទនេះ ក្នុងនោះមានបណ្តឹងរដ្ឋប្បវេណី

---

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤

[2] គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញារបស់អង្គការសហប្រជាជាតិ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ចំណុច១០និងចំណុច១១

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤០

[4] ក្រមនីតិវិធីព្រហ្មណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៧ និង មាត្រា ១០

[6] ១៥ ឆ្នាំ សម្រាប់បទឧក្រិដ្ឋ, ៥ ឆ្នាំ សម្រាប់បទមជ្ឈិម, និង ១ ឆ្នាំ សម្រាប់បទលហុ ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាមពុំមានអាជ្ញាយុកាលទេ ។ សូមមើលមាត្រា៩ និង មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[7] ប្រព័ន្ធច្បាប់ស៊ីវិល ( Civil Law System ) ជាប្រព័ន្ធច្បាប់សម្រាប់សរសេរ ដែលអនុវត្តដូចជានៅប្រទេសកម្ពុជា និងបារាំងជាដើម ។

[8] ប្រព័ន្ធច្បាប់ខមម៉ន់ឡ ( Common Law System ) ជាប្រព័ន្ធច្បាប់ឥតសរសេរ ដែលអនុវត្តដូចជានៅសហរដ្ឋអាមេរិកជាដើម ។

ដែលជាបណ្តឹងធ្វើឡើងដើម្បីដោះស្រាយនូវវិវាទរវាងបុគ្គលឯកជន និងបុគ្គលឯកជន ដោយតម្រូវឲ្យមានការសងជាសំណងពន្យសនកម្ម រីឯបណ្តឹងមួយទៀតគឺបណ្តឹងអាជ្ញាដែលត្រូវបានធ្វើឡើងដោយព្រះរាជាអាជ្ញាដែលជាអ្នកតំណាងឲ្យសង្គម ដើម្បីកំណត់ថា តើមានប្រព្រឹត្តបទល្មើសដែរឬទេ បើមានការប្រព្រឹត្តមែន ជនល្មើសត្រូវទទួលទោសពិន័យ និង/ឬ ទោសដាក់ពន្ធនាគារទៅតាមទោសបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ ។

# ផ្នែកទី១ ដំណើរការនៃបណ្តឹងអាជ្ញា

## ១.១ និយមន័យ

បណ្តឹងអាជ្ញា គឺជាបណ្តឹងដែលមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់[៩]។ បណ្តឹងនេះកើតឡើង និងបញ្ចប់ទៅវិញដោយមូលហេតុជាក់លាក់ ពីព្រោះវាគឺជាប្រភេទនៃបណ្តឹងមួយដែលមានគោលដៅប្រឆាំងនិងអំពើ ( អង្គហេតុ ) និងបុគ្គលដែលប្រព្រឹត្តអំពើនោះ ហើយអំពើនោះធ្វើឲ្យចលាចលដល់សង្គម ឬសណ្តាប់ធ្នាប់សាធារណៈ។

## ១.២ ប្រភេទនៃបណ្តឹងអាជ្ញា

នៅក្នុងរឿងព្រហ្មទណ្ឌអំពើដែលកើតឡើងដោយរូបវ័ន្តបុគ្គលដែលបានប្រព្រឹត្តអំពើដែលច្បាប់បានហាមឃាត់គឺឃើញថា តែងតែមានបណ្តឹងពីរកើតឡើងគឺ បណ្តឹងអាជ្ញា និង បណ្តឹងរដ្ឋប្បវេណី។

### ១.២.១ បណ្តឹងអាជ្ញា

នៅក្នុងផ្នែកទី១នេះយើងនិងសិក្សាអំពីការចាប់ផ្តើម និងអនុវត្តបណ្តឹងអាជ្ញារបស់តំណាងអយ្យការដោយធ្វើការរៀបរាប់តែនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតរបស់ព្រះរាជាតែប៉ុណ្ណោះ និង ធ្វើការបកស្រាយដល់ដំណាក់កាលផ្សេងៗទៀតនោះទេ។ នៅដំណាក់កាលស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា យើងសង្កេតឃើញមានការស៊ើបអង្កេត ០២( ពីរ ) ប្រភេទគឺៈ

- ការស៊ើបអង្កេតករណីជាក់ស្តែង និង
- ការស៊ើបអង្កេតបឋម។

ការស៊ើបអង្កេតទាំងពីរប្រភេទនេះហើយ ដែលជាមូលដ្ឋានដ៏ចម្បងសម្រាប់ឲ្យព្រះរាជអាជ្ញាថ្លឹងថ្លែងពិចារណាអំពីចំណាត់ការ ឬចំណាប់ផ្តើមនៃបណ្តឹងអាជ្ញារបស់ខ្លួនប្រឆាំងទៅនឹងបុគ្គលដែលបានប្រព្រឹត្តបទល្មើស។ បណ្តឹងអាជ្ញានេះអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវ័ន្តបុគ្គល ទាំងនីតិបុគ្គលដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ[10]។នេះគឺជាគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ដែលជាគោលការណ៍គ្រឹះមានចែង

[៩] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ២ កថាខណ្ឌទី២

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៣

នៅក្នុងរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាហើយវាមានលក្ខណៈស្របទៅនិងសិទ្ធិជាមូលដ្ឋានដែលមានចែង នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រង់មាត្រា ១៤ ផងដែរ ។

ការចាប់ផ្តើមដំណើរការនៃបណ្តឹងអាជ្ញាមាន ០២ ( ពីរ ) របៀបៈ ដោយអយ្យការ ( គោលការណ៍ទូទៅ ) និងដោយជនរងគ្រោះ ( អញ្ញត្រកម្ម ) ។

**១.២.១.១ គោលការណ៍ទូទៅ**

ជាគោលការណ៍បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ ។ អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ [11] ។

មានតែអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[12] ។ ការធ្វើបណ្តឹងអាជ្ញា មានន័យថាការប្តឹងទៅយុត្តាធិការស៊ើបសួរ ឬជំនុំជម្រះនូវអង្គហេតុ ឬជាយថាហេតុរួមទាំងបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសនោះផងដែរ ប្រសិនបើបុគ្គលនោះត្រូវបានគេស្គាល់ ។

**១.២.១.២ អញ្ញត្រកម្ម**

អញ្ញត្រកម្មទៅនិងគោលការណ៍ខាងលើ ឃើញមានការបើកផ្លូវឲ្យជនរងគ្រោះនៃអំពើដែលជាបទល្មើសព្រហ្មទណ្ឌអាចដាក់បណ្តឹងអាជ្ញាឲ្យមានចលនាផងដែរ ។ *មាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឲ្យជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍នៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបញ្ញត្តិដោយមាត្រា ១៣៩ ( ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា ) និងមាត្រា ១៤០ ( ការដាក់ប្រាក់តម្កល់ទុក ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។*

**១.២.១.៣ ការអនុវត្តបណ្តឹងអាជ្ញា**

ការអនុវត្តបណ្តឹងអាជ្ញាមានលក្ខណៈមិនសូវខុសគ្នានោះទេ ទោះបីក្នុងក្របខណ្ឌបណ្តឹងអាជ្ញារបស់អយ្យការឬរបស់ជនរងគ្រោះក៏ដោយ ។ ព្រះរាជអាជ្ញាមានជម្រើសក្នុងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌចំពោះអង្គហេតុដែលខ្លួនយល់ឃើញថាជាបទល្មើស ។ ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹងនិងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក[13] តាមរយៈការបើកការស៊ើបអង្កេត ។ ករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាអាជ្ញាអមសាលាឧទ្ធរណ៍

---

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤

[12] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចូលជាធរមានថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា ១៣១ថ្មី ( មាត្រា ១១២ចាស់ )

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៤ កថាខណ្ឌទី១

ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ចំណុចនេះបង្ហាញអំពីការអនុវត្តនូវគោលការណ៍ឋានានុក្រម ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌គឺជានាយឋានានុក្រមនៃអង្គអយ្យការ ។

ការចោទប្រកាន់របស់ព្រះរាជអាជ្ញាអាចធ្វើតាមៈ

- ការចោទប្រកាន់ទៅចំពោះមុខយុត្តាធិការស៊ើបសួរនិង
- ការចោទប្រកាន់ទៅចំពោះមុខយុត្តាធិការជំនុំជម្រះ ។

### ១.២.១.៤ ការចោទប្រកាន់នៅចំពោះមុខយុត្តាធិការស៊ើបសួរ

ព្រះរាជអាជ្ញាអាចបើកឲ្យធ្វើការស៊ើបសួរចំពោះអង្គហេតុ ដែលខ្លួនយល់ថាជាបទល្មើសព្រហ្មទណ្ឌដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិម តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅចៅក្រមស៊ើបសួរ ។ ការស៊ើបសួរអាចបើកប្រឆាំងនិងបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានការចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញត្រជន ប្រសិនបើជននេះមិនត្រូវបានគេស្គាល់អត្តសញ្ញាណ ។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវតែគោរពទម្រង់ការ ដែលមានចែងក្នុងមាត្រា៤៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បើពុំដូច្នេះទេនិងត្រូវទុកជាមោឃៈ ។ ទម្រង់ការនេះរួមមានៈ

- សេចក្ដីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះនៃបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។

ដីកានេះត្រូវចុះកាលបរិច្ឆេទ និងហត្ថលេខា ។

### ១.២.១.៥ ការចោទប្រកាន់នៅចំពោះមុខយុត្តាធិការជំនុំជម្រះ

ព្រះរាជអាជ្ញាក៏អាចសន្និដ្ឋានចោទប្រកាន់ចំពោះអង្គហេតុ និងបុគ្គល ( ត្រូវតែមានអត្តសញ្ញាណច្បាស់លាស់ ) ទៅចំពោះមុខយុត្តាធិការជំនុំជម្រះ តាមរយៈនីតិវិធី ០២ ( ពីរ ) យ៉ាងគឺៈ

- ការបញ្ជូនរឿងទៅជំនុំជម្រះដោយផ្ទាល់[14] និង
- ការបង្ហាញខ្លួនភ្លាម[15] ។

ព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភស្តុតាងនានា ដែលជាមូលដ្ឋាននៃការចោទប្រកាន់របស់ខ្លួន ចំពោះអំពើល្មើសរបស់ជនត្រូវចោទ ឬជនជាប់ចោទ ក្រោយពីការសម្រេចចោទប្រកាន់របស់ខ្លួន ។

## ១.២.២ បណ្តឹងរដ្ឋប្បវេណី

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៣, ៤៥, ៤៦ និងមាត្រា ៤៩

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៣, ៤៥, ៤៧ និងមាត្រា ៤៨

បណ្ដឹងរដ្ឋប្បវេណីជាគោលការណ៍ទូទៅ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៣ នៃក្រមនេះ ។[16] បណ្ដឹងរដ្ឋប្បវេណីមានគោលបំណងធ្វើយ៉ាងណាឲ្យមានការជួសជុលការខូតខាតដែលបានបណ្ដាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណង ធ្វើយ៉ាងណាអោយជនរងគ្រោះទទួលបាននូវសំណង ជម្ងឺចិត្តធួនល្មម និងព្យសនកម្មដែលខ្លួនបានប្រព្រឹត្ត ។[17] បណ្ដឹងរដ្ឋប្បវេណី គឺជាសិទ្ធិមួយដែលច្បាប់បានកំណត់ទទួលស្គាល់សម្រាប់បុគ្គលឯកជន អាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល ក្នុងការធ្វើបណ្ដឹងទៅស្ថាប័នតុលាការឲ្យជួយដោះស្រាយវិវាទ និងទាមទារអោយចេញសាលក្រមតាមការ ទាមទាររបស់គូភាគីនៃអំពើ និងព្យសនកម្មដែលកើតឡើង ។

បណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានជួសជុល ដោយត្រូវទទួលបានការបង់ជម្ងឺចិត្ត ដោយការសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬដោយការធ្វើឲ្យមានការសងនូវសភាពដើមវិញនូវទ្រព្យដែលគេបានបំផ្លិចបំផ្លាញ ឬធ្វើឲ្យខូចខាត ។[18]

## ផ្នែកទី ២ អាជ្ញាយុកាល

ជាទូទៅនៅក្នុងរឿងព្រហ្មទណ្ឌច្បាប់បានកំណត់ពីអាជ្ញាយុកាលនៃរឿងព្រហ្មទណ្ឌ គឺជាចិរវេលាមួយដែលច្បាប់បានកំណត់ពីអំឡុងពេលមួយដែលមានអត្ថិភាពអានុភាពនៃសិទ្ធិឬកាតព្វកិច្ចរបស់បុគ្គលដែលត្រូវទទួលខុសចំពោះអំពើដែលខ្លួនបានប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ។[19]

ជាទូទៅអាជ្ញាយុកាលនៅក្នុងរឿងព្រហ្មទណ្ឌ គឺមានគោលបំណង ពីរ យ៉ាង:

- ដើម្បីជាប្រយោជន៍សង្គម ឬ សិទ្ធិអំណាចរបស់រដ្ឋក្នុងការប្រើប្រាស់ពេលវេលាក្នុងការឆ្លើយតបចំពោះអំពើល្មើសច្បាប់ដែលបង្កព្យសនកម្មក្នុងសង្គម ពីសំណាក់បុគ្គលដែលនៅក្នុងទឹកដី និងដែនអធិប្បតេយ្យភាពរបស់រដ្ឋគ្រប់គ្រង ។
- គឺជាផលប្រយោជន៍ដែលបុគ្គលល្មើសតាមរយៈការទទួលស្គាល់នូវសិទ្ធិជាសកលអំពីកាលវេលាដែលកន្លងហួសចំពោះអំពើល្មើសរបស់ខ្លួនដែលត្រូវរួចផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់ ។

### ២.១. អាជ្ញាយុកាលនៃបណ្ដឹងព្រហ្មទណ្ឌ

ជាគោលការណ៍អាជ្ញាយុកាលនៃរឿងព្រហ្មទណ្ឌត្រូវបានបែងចែកជាពីរ ( ០២ ) ប្រភេទគឺ អាជ្ញាយុកាលនៃបទល្មើស[20] និងអាជ្ញាយុកាលនៃទោស។

#### ២.១.១.អាជ្ញាយុកាលនៃបទល្មើស

---

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១៣

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ២ កថាខណ្ឌទី ២

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១៤ កថាខណ្ឌទី១

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១០

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១០

អាជ្ញាយុកាលនៃបទល្មើស គឺជារយៈពេលមួយកំណត់ដែលអាចឲ្យមន្ត្រីនគរបាលយុត្តិធម៌ព្រះរាជអាជ្ញាឬចៅក្រមអនុវត្តបណ្តឹងអាជ្ញាតាមរយៈកិច្ចស៊ើបអង្កេតនិងកិច្ចស៊ើបសួរឬការជំនុំជម្រះលើករណីរឿងក្តីព្រហ្មទណ្ឌបាន ។ តាមគោលការណ៍នេះមានតែអង្គការអយ្យការមួយប៉ុណ្ណោះដែលមាន សិទ្ធិធ្វើបណ្តឹងអាជ្ញា ។ បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឲ្យឃើញពិរុទ្ធនៃបទល្មើសនិងធ្វើការអនុវត្តទោសតាមច្បាប់កំណត់ ។

ចំពោះថិរវេលានៃអាជ្ញាយុកាល ត្រូវបានកំណត់តាមប្រភេទនៃបទល្មើសដែលមានដូចជា៖ តាមរយៈពេល ១ ឆ្នាំ ចំពោះលហុ/ រយៈពេល ៥ ឆ្នាំ ចំពោះបទល្មើសមជ្ឈិម /រយៈពេល ១៥ ឆ្នាំ ចំពោះបទឧក្រកិដ្ឋ ។

- បទល្មើសជាបទលហុ គឺជាបទល្មើសក្នុងករណីដែលមានអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើ៦ ថ្ងៃដែល ។[21] ឬបទល្មើសដែលត្រឹមពិន័យជាប្រាក់ប៉ុណ្ណោះ ។[22]
- បទល្មើសជាបទមជ្ឈឹមគឺ បទដែលត្រូវផ្តន្ទាទោសក្នុងអតិបរមានៃទោសដាក់ពន្ធនាគាររយៈពេលលើសពី ៦ថ្ងៃ និងដល់ក្រោមឬស្មើនិង ៥ឆ្នាំ ។[23] ទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែល ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចូលជាធរមានថ្ងៃទី ៣០ ខែវិច្ឆការ ឆ្នាំ២០០៩ មាត្រា ៤៧ កថាខណ្ឌទី២ ។[24]
- បទល្មើសជាបទក្រិដ្ឋ គឺជាអំពើល្មើសមួយដែលធ្ងន់ធ្ងរបំផុតដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពីរ ៥ ឆ្នាំ និងក្រោមឬស្មើនិង៣០ ឆ្នាំ។[25]
- និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

ជាគោលការណ៍ប្រជាធិបតេយ្យនៅប្រទេសកម្ពុជាត្រូវបានលុបបំបាត់នៅទោសប្រហាជីវិតដោយអនុលោមតាមគោលការណ៍មនុស្សធម៌អន្តរជាតិ មាត្រា៧ស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដោយត្រូវបានចែងយ៉ាងច្បាស់ថា"គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ប្រព្រឹត្ត ឬទារុណកម្មដែលឃោឃៅអមនុស្សធម៌ធ្វើអោយមានអំពើថោកទាបបានឡើយ ជាពិសេសការហាមយកជនណាម្នាក់មកធ្វើការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនបានឡើយ"។ដោយសារដាក់ជំនួសមកវិញនៅទោសដាក់ពន្ធនាគារអស់មួយជីវិតព្រោះក្នុងច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យកមាត្រា៣២"ជនគ្រប់

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៤៨
[22] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៤៤ កថាខណ្ឌទី២
[23] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៤៧
[24] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៤៧ កថាខណ្ឌទី២
[25] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៤៦ កថាខណ្ឌទី២ និង កថាខណ្ឌទី១

រូបមានសិទ្ធិរស់រានមានជីវិតមានសេរីភាពនិងមានសន្តិសុខផ្ទាល់ខ្លួន "ចំពោះកថាខណ្ឌចុងក្រោយបានកំណត់ថាទោសប្រហារជីវិតមិនត្រូវអោយមានឡើយ " ។[26]

ក្នុងន័យនេះហើយត្រូវបានចែងនៅក្នុងក្រមព្រហ្មទណ្ឌកំណត់ទោសដែលធ្ងន់ជាងគេគឺត្រឹមតែការផ្តន្ទាទោសមានរយៈពេល ៣០ ឆ្នាំ និងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

ដោយឡែកចំពោះបទឧក្រិដ្ឋធំៗ មួយចំនួន ដូចជាបទឧក្រិដ្ឋប្រល័យពូជសាសន៍/ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ / និងបទឧក្រិដ្ឋកម្មសង្គ្រាម គឺក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ច្បាប់យក មាត្រា ៩ មកធ្វើជាគោលការណ៍អនុវត្ត ព្រោះថាបទល្មើសទាំងបី ប្រភេទនេះមិនអាចផុតអាជ្ញាយុកាលបានឡើយ ។[27] ជាគោលការណ៍គឺបទល្មើសជាអំពើដល់សាហាវបំផុតនិងជាប្រភេទដែលបំផ្លាញមនុស្សជាតិនិងទ្រព្យសម្បត្តិរដ្ឋជាពិសេស គឺអំពើមួយចំនួនដែលរដ្ឋមិនអាចទទួលយកបានដូចជាៈ[28]

**២.១.១.១អំពើប្រល័យពូជសាសន៍**

- ឃាតកម្មលើសមាជិកនៃក្រុម ។
- ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬសតិបញ្ញារបស់សមាជិកនៃក្រុម ។
- ការដាក់ឲ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខណ្ឌដែលនាំឲ្យវិនាសអន្តរាយទាំងស្រុង ឬមួយផ្នែកនៃក្រុម ។
- វិធានការដោយបង្ខំ ឬមធ្យោបាយដោយមិនបង្ខំ សំដៅដល់ការរារាំងកំណើតទារកនៅក្នុងក្រុម ។
- ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយផ្សេងទៀត ។

**២.១.១.២ អំពើប្រឆាំងនិងមនុស្សជាតិ**

ជាអំពើមួយក្នុងចំណោមអំពើដែលរៀបរាប់ដូចខាងក្រោមនេះ[29]

- ឃាតកម្ម ។
- ការសម្លាប់រង្គាល ។
- ការធ្វើឲ្យទៅជាទាសករ ។
- ការនិរទេស ឬជម្លៀសប្រជាជនដោយបង្ខំ ។

[26] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចូលជាធរមានថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា ៣២

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៩

[28] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ១៨៣

[29] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ១៨៨

- ការដាក់ពន្ធនាគារ ឬគ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបង្ខំទៅលើបទបញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ។
- ការធ្វើទារុណកម្ម ។
- ការចាប់រំលោភសេពសន្ថវៈ ការធ្វើទាសកម្មខាងផ្លូវភេទ ពេស្យាចារដោយបង្ខំការមានគភ៌ដោយបង្ខំ វណ្ណកម្មដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហិង្សាខាងផ្លូវភេទ ដែលមានទម្ងន់ប្រហាក់ប្រហែលគ្នា ។
- ការធ្វើទុកបុកម្នេញលើក្រុម ឬសមូហភាពដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិ ជាតិពន្ធុ វប្បធម៌ សាសនា ឬភេទ ។
- ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ។
- ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ជាប្រយោជន៍ ជាប្រព័ន្ធតាមបែបអាប៉ាថេដ ។
- គ្រប់អំពើអមនុស្សធម៌ទៅលើបូរណភាពខាងរូបភាព ខាងរូបកាយ ។

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។[30]

**២.១.១.៣ អំពើដែលជាឧក្រិដ្ឋកម្មសង្រ្គាម**

អំពើល្មើសដែលជាឧក្រិដ្ឋកម្មសង្រ្គាម ជាអំពើមួយក្នុងចំណោមអំពើដែលរៀបរាប់ដូចខាងក្រោមនេះដែលត្រូវបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។[31]

- ឃាតកម្ម ។
- ទារុណកមម្ម ឬគ្រប់អំពើអមនុស្សធម៌ រួមបញ្ចូលទាំងការពិសោធជីវសាស្រ្ត ។
- អំពើបង្កដោយចេតនានូវការឈឺចាប់ ឬដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណខាងរូបកាយ ឬ សុខភាព ។
- ការបំផ្លាញ ឬការធ្វើឲ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយគ្មានហេតុផលចាំបាច់ខាងយោធា និងក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់ និងតាមទំនើងចិត្ត ។
- អំពើឈ្លើយសឹក ឬជនស៊ីវិល ឲ្យបម្រើក្នុងកងកម្លាំងប្រដាប់អាវុធរបស់សត្រូវ ។
- អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬជនស៊ីវិល ក្នុងការទទួលការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលំអៀង ។

[30] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ១៨៩

[31] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ មាត្រា ១៩៣

- ជម្លៀស ការបញ្ជូន ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ។
- ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង ។

### ២.១.១.៤ អំពើដែលជាបទឧក្រិដ្ឋផ្សេងទៀត

អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺជាបទឧក្រិដ្ឋសង្គ្រាមដែរ ដែលត្រូវបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។[32]

- ការប្រើប្រាស់អាវុធដែលមានជាតិពុល ឬអាវុធដែលស្ថាបនាឡើងដើម្បីបង្កការឈឺចាប់ឥតប្រយោជន៍ ។
- អំពើវាយប្រហារ ឬទម្លាក់គ្រាប់បែកដោយចេតនា តាមមធ្យោបាយណាក៏ដោយទៅលើទីក្រុង ភូមិ ទីកន្លែងរស់ ឬអគារដែលមិនមានការការពារ និងដែលមិនមែនជាកម្មវត្ថុខាងយោធា ។
- អំពើវាយប្រហារដោយចេតនាទៅលើមនុស្ស ឬសម្ភារៈដែលប្រើប្រាស់ក្នុងក្របខណ្ឌនៃបេសកកម្មមនុស្សធម៌ ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ។
- អំពើបង្កគ្រោះទុរ្ភិក្សដោយចេតនា ដល់ប្រជនស៊ីវិល ដោយដកហូតនូវទ្រព្យសម្បត្តិចាំបាច់សម្រាប់បន្តការរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនេះ ។
- អំពើប្រើប្រាស់ជនស៊ីវិល ដើម្បីបញ្ចៀសពីគោលដៅនៃប្រតិបត្តិការយោធាទៅលើអគារខ្លះ តំបន់ខ្លះនៃដែនដី ឬកងកម្លាំងយោធាខ្លះ ។
- អំពើបំផ្លាញ ឬធ្វើឲ្យខូចខាតដោយចេតនា នូវអគារសម្រាប់សាសនា សប្បុរសធម៌ អប់រំ សិល្បៈ និងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈ ឬស្នាដៃដែលមានលក្ខណៈវិទ្យាសាស្ត្រ ។
- អំពើបង្កដល់បរិស្ថានធម្មជាតិ នូវការខូចខាតដ៏ធំ យូរអង្វែង និងធ្ងន់ធ្ងរ ដែលមានលក្ខណៈហួសហេតុយ៉ាងជាក់ស្តែង បើប្រៀបធៀបទៅនិងផលប្រយោជន៍ពិតប្រាកដ និងផ្ទាល់ ខាងផ្នែកយោធាដែលសង្ឃឹមទុក ។
- ការលួចប្លន់សម្បត្តិសាធារណៈ ឬឯកជន ។

អំពើដូចដែលបានរៀបរាប់ខាងលើនេះគឺមិនត្រូវអោយរួចផុតពីអាជ្ញាយុកាលបានឡើយ ព្រោះជាអំពើដែលសាហាវ និងមានហានិភ័យខ្ពស់ដល់សង្គមទាំងមូល ។

ជាទូទៅបណ្តឹងអាជ្ញាអាចត្រូវបានចាប់ផ្តើមគិតរយៈពេលនៃអាជ្ញាយុកាល ត្រូវរាប់ចាប់ពីពេលប្រព្រឹត្តបទល្មើស ។ អាជ្ញាយុកាលអាចត្រូវកាត់ផ្តាច់ដោយគ្រប់កិច្ចនីតិវិធីនៃកិច្ចចោទប្រកាន់ និង កិច្ចស៊ើបសួរនីមួយ ។

[32] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ មាត្រា ១៩៤

ដែលនាំអោយចាប់ផ្ដើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល ថិរវេលាថ្មីអាចនិងយកទៅជំទាស់បានចំពោះជនគ្រប់រូបដែលបានទាក់ទិនទៅក្នុងរឿងក្ដីនោះ ។

ឧទាហរណ៍ៈ នៅថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១០ មានបុគ្គលម្នាក់ឈ្មោះ A បានធ្វើសកម្មភាពលួចទូរស័ព្ទ ម៉ាក់ QQ បានសម្រេចពីបុគ្គលឈ្មោះ B ពេលដែលគាត់ទុកទូរស័ព្ទនៅលើតុក្នុងការិយាល័យ ។ លោក B បានស្គាល់ លោក A ច្បាស់ណាស់ថាជាអ្នកលួចទូរស័ព្ទរបស់លោក លោកក៏បានទៅដាក់ពាក្យបណ្ដឹងនៅថ្ងៃទី ១២ ខែវិច្ឆិការ ឆ្នាំ២០១០ លោក B បានដាក់ពាក្យបណ្ដឹងនេះនៅនគរបាលយុត្តិធម៌ ។ តែទោះជាយ៉ាងណាលោក A មិនបានចូលខ្លួនតាមការកោះហៅរបស់មន្ត្រីនគរបាលដែរ ។ នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១០ ព្រះរាជអាជ្ញាបានចេញដីកាកោះហៅឈ្មោះ A ឲ្យចូលខ្លួនទៅឆ្លើយបំភ្លឺក្នុងករណីលួចទូរស័ព្ទខាងលើនេះ តែយ៉ាងណាលោក A មិនបានចូលខ្លួនដដែល ។ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ ព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ ។

តាមរយៈឧទាហរណ៍ខាងលើនេះបើសិនលោក B មិនបានប្ដឹងទៅនគរបាលទេនោះ អាជ្ញាយុកាលគឺគិតចាប់ពីថ្ងៃ ទី១០ ខែតុលា ឆ្នាំ២០១០ រហូតដល់គ្រប់៥ ឆ្នាំព្រោះថាអំពើលួចជាបទមជ្ឈិម ។ ប៉ុន្តែរយៈពេល ៥ឆ្នាំ នៃអាជ្ញាយុកាលនៃអំពើរបស់លោក A នេះត្រូវផ្ដាច់តាមរយៈនៃកិច្ចស៊ើបសួរ និងការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។[33]

## ២.១.២.មូលហេតុទូទៅដែលមានការប៉ះពាល់ការអនុវត្តទោស

### ២.១.២.១ អាជ្ញាយុកាលនៃទោសព្រហ្មទណ្ឌ

អាជ្ញាយុកាលនៃទោស គឺជារយៈពេលមួយដែលកំណត់ដោយច្បាប់ ដែលត្រូវបានអនុវត្តលើទោសដែលត្រូវបានប្រកាសដោយតុលាការព្រហ្មទណ្ឌ ចំពោះបុគ្គលណាម្នាក់ដែលតុលាការរកឃើញថាមានពិរុទ្ធភាព ។ ជាទូទៅអាជ្ញាយុកាលនៃទោសត្រូវបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។ ថិរវេលានៃអាជ្ញាយុកាលនៃទោសត្រូវបានកំណត់តាមប្រភេទនៃទោសដូចខាងក្រោមៈ

១. បទឧក្រិដ្ឋ

បទឧក្រិដ្ឋ គឺបទល្មើសដែលមានទណ្ឌកម្មធ្ងន់ធ្ងរបំផុត ។បទល្មើសនេះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ ( ប្រាំ ) ឆ្នាំនិងក្រោម ឬស្មើនិង ៣០( សាមសិប ) ឆ្នាំ ឬដាក់ពន្ធនាគារអស់មួយជីវិត ។ ជាទូទៅនៅក្នុងការកំណត់ថាបទល្មើសជាបទឧក្រិដ្ឋត្រូវតែកំណត់តាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ២០០៩ ។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១១

យោងតាមមាត្រា៤៦នៃក្រមព្រហ្មទណ្ឌគឺបានចែងអំពីរបៀបក្នុងការស្គាល់ថាបទល្មើសមួយជាបទឧក្រិដ្ឋតាមរយៈទោសដាក់ពន្ធនាគារ។អញ្ចឹងមាត្រា៤៦បានកំណត់ថាប្រសិនបើទោសដាក់ពន្ធនាគារដែលមានចែងក្នុងច្បាប់គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិតមួយឬក៏ជាទោសដាក់ពន្ធនាគារមានថិរវេលាកំណត់ប៉ុន្តែលើសពី៥ឆ្នាំឡើងទៅដល់ក្រោមឬស្មើ៣០ឆ្នាំ។ ក្នុងករណីនេះឲ្យតែបទល្មើសមួយចែងក្នុងច្បាប់ផ្តន្ទាទោសក្នុងកម្រិតដូចបានជម្រាបជូនអម្បិញមិញគឺអាជ្ញាយុកាលនៃទោសត្រូវបានកំណត់ថាមានអាជ្ញាយុកាលរយៈ២០( ម្ភៃ ) តាមអំណាចសាលក្រមរបស់តុលាការដែលសម្រេចផ្តន្ទាទោសបុគ្គលណាម្នាក់ ។[34]

២.បទមជ្ឈិម

បទមជ្ឈិម គឺជាបទល្មើសដែលមានទណ្ឌកម្មមធ្យមនៃទោសដែលត្រូវដាក់ពន្ធនាគារមានរយៈពេលលើសពី៦ ( ប្រាំមួយ ) ថ្ងៃ ដល់ ៥ ( ប្រាំ ) ឆ្នាំ ។[35] យោងតាមមាត្រា ៤៧ ដើម្បីអាចស្គាល់ថាបទល្មើសជាបទមជ្ឈិមបាននោះយើងត្រូវត្រួតពិនិត្យមើលថា តើអតិបរមានៃទោសដែលមានចែងក្នុងច្បាប់នោះផ្តន្ទាទោសគឺមានកម្រិតប៉ុណ្ណាជាទូទៅអាជ្ញាយុកាលនៃទោសមជ្ឈិម គឺមានរយៈពេល ៥ ( ប្រាំ ) ឆ្នាំ ដោយតាមអំណាចសាលក្រមរបស់តុលាការដែលត្រូវអនុវត្តតាមអំណាចសាលក្រម ។[36]

៣.បទលហុ

បទលហុ គឺលហុជាបទល្មើសដែលមានទណ្ឌកម្មស្រាលជាងគេ ។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើ និង ៦ ( ប្រាំមួយ ) ថ្ងៃ ឬពិន័យជាប្រាក់ប៉ុណ្ណោះ[37] ។ យោងតាមមាត្រា ៤៨ របៀបក្នុងការសម្គាល់បទលហុមាន ២ គឺលក្ខខណ្ឌវិន័ថ្វ័យមើលទៅលើទោសដាក់ពន្ធនាគារ ។ ផ្អែកតាមមាត្រានេះ បទល្មើសមួយត្រូវបានចាត់ទុកថាជាបទលហុនៅពេលដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលមានចែងក្នុងច្បាប់ហ្នឹង គឺចាប់ពី ១ថ្ងៃទៅ ដល់ក្រោម ឬស្មើនិង ៦ថ្ងៃ មានន័យថា ៦ថ្ងៃចុះក្រោម ឲ្យតែមានទោសទោសពន្ធនាគារ ។ ចំពោះអាជ្ញាយុកាលនៃទោសលហុនេះត្រូវគិត ចាប់ពីពេលដែលសាលក្រម ត្រូវបានប្រកាសតាមអំណាចសាលក្រមរបស់តុលាការ ដែលមានកម្រិតអាជ្ញាយុកាលនៃទោស គឺ ១ ( មួយ ) ឆ្នាំ ។[38]

## ២.២.អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី

ការរាប់រយៈពេលនៃអាជ្ញាយុកាល មានភាពខុសគ្នាទៅតាមប្រភេទនៃបទល្មើស ដូចជាបទល្មើសភ្លាម ៗ ឬជាបទល្មើសអូសបន្លាយ ។

[34] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ចែងអំពី "និយមន័យនៃបទឧក្រិដ្ឋ"

[35] យោងតាមសន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១៤០

[36] យោងតាមមាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែវិច្ឆិការ ឆ្នាំ ២០០៩ ចែងអំពី "និយមន័យនៃបទមជ្ឈិម"

[37] យោងតាមពាក្យសន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១៦១

[38] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៨ ចែងអំពី "និយមន័យនៃបទលហុ"

ជាគោលការណ៍ ថិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្ដើមគិតពីពេលដែលត្រូវបានប្រព្រឹត្ត បទល្មើស (មាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ) ។

ចំណែកឯក្រមរដ្ឋប្បវេណី មាត្រា ៤៨២ បានកំណត់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលកំណត់ចំនួន ៥ ឆ្នាំ។ ប្រសិនបើអាជ្ញាយុកាលផ្នែករដ្ឋប្បវេណីកំណត់ដោយច្បាប់មានរយៈពេលវែងជាងអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាការផុតអាជ្ញាយុកាលនៃបទល្មើសពុំអាចជាឧបសគ្គរាំងដល់ជនរងគ្រោះប្ដឹងទៅតុលាការរដ្ឋប្បវេណីដើម្បីទាមទារសំណងការខូចខាតទេ។ ចំណែកឯការទទួលខុសត្រូវក្រៅកិច្ចសន្យាអាជ្ញាយុកាលមានរយៈពេលតែ ៣ ឆ្នាំប៉ុណ្ណោះ ( ក្រឹត្យច្បាប់លេខ ៣៨ ) ។

# ជំពូកទី២

# មូលហេតុនៃការរលត់បណ្តឹងអាជ្ញា

អយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋ សម្រាប់ដំណើរការបណ្តឹងសាធារណៈ ឬបណ្តឹងព្រហ្មទណ្ឌ ។[39] ពាក្យថា អយ្យការ គឺជាស្ថាប័នមួយ ដូចនេះពាក្យថា អង្គការអយ្យការ គឺជាស្ថាប័នអយ្យការទាំងឡាយ ដែលត្រូវបានដាក់ពង្រាយឲ្យអមនៅតាមសាលាជម្រះក្តីនីមួយៗគ្រប់ជាន់ថ្នាក់ ។ អយ្យការគឺជាស្ថាប័នដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា និងការពារផលប្រយោជន៍សាធារណៈ ។ "តួនាទីអយ្យការត្រូវតែចែកឲ្យដាច់ពីមុខងារតុលាការ"[40] អង្គការអយ្យការ មិនមែនជាស្ថាប័នដែលទទួលបន្ទុកក្នុងការជម្រះក្តីដូចតុលាការឡើយ តែអយ្យការគឺជាភាគីនៃរឿងក្តីព្រហ្មទណ្ឌដែលជាអ្នកតំណាងឲ្យផលប្រយោជន៍ទូទៅ ដោយមានសិទ្ធិក្នុងការធ្វើបណ្តឹងអាជ្ញា ។

ព្រះរាជអាជ្ញាមានសិទ្ធិជាគោលការណ៍ក្នុងការផ្តើមធ្វើបណ្តឹងអាជ្ញា ចាប់តាំងពីពេលដែលខ្លួនបានដឹងអំពីបទល្មើស ។ ជាអាទិ៍ព្រះរាជអាជ្ញាប្រើប្រាស់គោលការណ៍កាលានុវត្តភាពនៅក្នុងជម្រើសនៃការចោទប្រកាន់របស់ខ្លួន។ គោលការណ៍កាលានុវត្តភាពនេះផ្តល់ឲ្យព្រះរាជអាជ្ញានូវសេរីភាពក្នុងការវាយតម្លៃថាគួរតែធ្វើបណ្តឹងអាជ្ញា ឬតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកទៅលើស្ថានទម្ងន់ទោសនៃបទល្មើស កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ភាពរឹករវល់សណ្តាប់ធ្នាប់សាធារណៈ និងភស្តុតាងផ្សេងៗទៀតដែលប្រមូលបានក្នុងពេលស៊ើបអង្កេត ។ គោលការណ៍នេះអនុញ្ញាតឲ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការ ហើយទោះបីជាច្បាប់បានចែងទុកថាអំពើនោះ គឺជាបទល្មើសដែលត្រូវតែផ្តន្ទាទោសក៏ដោយ ។ អាចនិយាយបានម្យ៉ាងទៀតថា គោលការណ៍គោលការណ៍កាលានុវត្តភាពរបស់ព្រះរាជអាជ្ញា បានបំពានទៅលើបទបញ្ញត្តិស្តីពីគោលការណ៍នីត្យានុកូលភាព មាត្រា៣ នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលចែងឲ្យប្រកាសអំពីទោសចំពោះអំពើដែលច្បាប់ចាត់ទុកថាជាបទល្មើស ។

## ១ គោលកាណ៍សំខាន់ៗនៃស្ថាប័នអយ្យការ និង គោលការណ៍ឯកភាព ឬឋានានុក្រម

យោងតាមក្រមពិភាក្សាព្រហ្មទណ្ឌឆ្នាំ១៩៦២បានបញ្ញត្តិថាស្ថាប័នអយ្យការគឺជា ក្រុមអយ្យការ។ បន្ថែមពីលើនេះទៀតកថាខណ្ឌទី១ មាត្រា៧៥នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាបានបញ្ញត្តបន្ថែមទៀត

[39] សូមមើល កុយ នាម និង ឡុង បញ្ញាវុឌ្ឍ, អង្គការអយ្យការ ( ប្រវត្តិ និងការសិក្សាប្រៀបធៀប ), ពិនិត្យ និងកែសម្រួលដោយ លោកចៅក្រម ហ៊ីង ធីឬទ្ធិ, លោក ម៉ែន និម្មិត, លោកចៅក្រម សេង នាង, លោកមេធាវី សួន វិសាល, លោកមេធាវី ជីវ សុងហាក់, លោក កុយ ពន្លក និង បុគ្គលិកបណ្ណាដ្ឋានជាតិ និងបណ្ណាល័យជាតិ, ភ្នំពេញ, ឧបត្ថការបោះផ្សាយពីលោកមេធាវី ជីវ សុងហាក់, បោះពុម្ពលើកទី១, ឆ្នាំ២០០៦, ទំព័រទី៤៥។

[40] សូមមើលគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាអាជ្ញា,អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបីស្តីពីការបង្ការបទឧក្រិដ្ឋ និងការ គ្រប់គ្រងជនល្មើស នាថ្ងៃទី ២៧ ខែសីហា ដល់ថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី១០

ថាអង្គអយ្យការជាអង្គឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងត្រួតពិនិត្យតាមឋានានុក្រម ។ បញ្ញត្តិទាំងពីរនេះបានបង្ហាញឲ្យឃើញថាស្ថាប័នអយ្យការនេះ ជាអង្គភាពដែលមានឯកភាពជាមួយគ្នា ក្នុងការបំពេញការងារតំណាងឲ្យតែស្ថាប័នខ្លួន និងទទួលខុសត្រូវរួមគ្នា ។ ចៅក្រមអយ្យការទាំងអស់ត្រូវបំពេញការងារស្ថិតក្រោមការដឹកនាំទៅតាមឋានានុក្រមរបស់ខ្លួន ។ ដោយឡែកឋានានុក្រមនោះ ត្រូវបែងចែកតាមថ្នាក់នៃសាលាជម្រះក្តីនីមួយៗមានដូចជា៖ នៅអយ្យការអមសាលាដំបូង មានព្រះរាជអាជ្ញាអមសាលាដំបូងជានាយឋានានុក្រម នៅមហាអយ្យការអមសាលាឧទ្ធរណ៍មានអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជានាយឋានានុក្រម និងនៅមហាអយ្យការអមតុលាការកំពូល មានអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលជានាយឋានានុក្រម ។[41]

នៅក្នុងទំនាក់ទំនងនៃការងាររបស់ខ្លួន ចៅក្រមអយ្យការត្រូវគោរពជាចាំបាច់នូវគោលការណ៍ឋានានុក្រម មានន័យថានៅសាលាដំបូងគ្រប់ព្រះរាជអាជ្ញារងទាំងអស់ ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យពីព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។ រីឯនៅសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យដោយអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។ ចំណែកឯនៅតុលាការកំពូល ព្រះរាជអាជ្ញារង និងអគ្គព្រះរាជអាជ្ញារងនៃតុលាការកំពូល ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យដោយអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។

ក្រៅពីនេះនៅក្នុងក្របខណ្ឌនៃដំណើរការរឿងក្តីព្រហ្មទណ្ឌ ចៅក្រមអយ្យការទាំងអស់ត្រូវតែគោរពទៅតាមអធិបញ្ជានៃឋានានុក្រមរបស់ខ្លួន ។ បានសេចក្តីថាព្រះរាជអាជ្ញារងត្រូវគោរពតាមអធិបញ្ជាពីព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងដែលខ្លួនស្ថិតនៅ ។ រីឯព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងវិញត្រូវគោរពតាមអធិបញ្ជារបស់ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ឬអធិបញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ នៅក្នុងចំណាត់ការសំណុំរឿងក្តីនេះដែរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏អាចធ្វើអធិបញ្ជាទៅឲ្យព្រះរាជអាជ្ញាអមសាលាដំបូង ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អំពីបទល្មើសដែលខ្លួនបានដឹង ។ ចំពោះការធ្វើអធិបញ្ជានេះអាចធ្វើការណែនាំជាលាយលក្ខណ៍អក្សរដែរត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងឲ្យធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការគួរ ។[42] ប៉ុន្តែទោះបីជាគ្រប់ចៅក្រមអយ្យការទាំងអស់ ត្រូវតែគោរពតាមអធិបញ្ជារបស់ថ្នាក់លើរបស់ខ្លួនក៏ដោយ ក៏នៅក្នុងពេលសវនាការ ចៅក្រមអយ្យការអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់ដោយសេរីតាមការដែលខ្លួនយល់ឃើញថាស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន[43] ហើយការកត់សម្គាល់នេះ

[41] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា ១៥

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ២៩

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៣០

មិនត្រូវបានចាត់ទុកជាការរំលោភបំពាននូវគោលការណ៍ឋានានុក្រម ដែលជាមូលហេតុនាំឲ្យមានការចោទប្រកាន់ខាងវិន័យណាមួយឡើយដោយសារតែការបញ្ចេញការយល់ឃើញរបស់ខ្លួននៅក្នុងពេលសវនាការនោះទេ ។ បញ្ញត្តិនៃមាត្រា៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះក៏មានសុភាសិតច្បាប់របស់បារាំងមួយដែលបកប្រែជាភាសាខ្មែរថា " បកាជាទាសី សម្តីដោយសេរី " ហើយសុភាសិតនេះ ត្រូវបានកម្ពុជាទទួលយកមកធ្វើជាមូលដ្ឋានដើម្បីរៀបចំច្បាប់របស់ខ្លួនតាំងពីអតីតកាលរហូតមកទល់បច្ចុប្បន្ន ។

**២ គោលការណ៍ឯករាជ្យ**

គោលការណ៍ឯករាជ្យភាពរបស់អង្គភាពអយ្យការ គឺជាគោលការណ៍ដែលបញ្ជាក់ថាអង្គការអយ្យការមានឯករាជ្យភាពរបស់ខ្លួន ហើយដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួនអមនោះឡើយ ។ នៅសាលាជម្រះក្តីទាំងឡាយគ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយបើទោះជាក្នុងករណី ដែលព្រះរាជអាជ្ញាមានកំហុសឆ្គងយ៉ាងណាក៏ដោយក៏សាលាជម្រះក្តីនោះមិនត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួន យកការស្តីបន្ទោសអ្វីចំពោះព្រះរាជាអាជ្ញាឡើយ ។ ចំពោះបម្រាមនេះត្រូវអនុវត្តទាំងក្នុងរឿងព្រហ្មទណ្ឌ និងរឿងក្តីផ្សេងទៀត ។ ប៉ុន្តែសាលាជម្រះក្តីនោះ អាចលើកសំណើរទៅនាយកឋានានុក្រមរបស់ព្រះរាជអាជ្ញាអំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញានោះបាន ។[44]

**៣ គោលការណ៍សំខាន់ៗនៃចៅក្រមអយ្យការ និង គោលការណ៍មិនប្តឹងជិតចិត្ត**

ទោះបីជាព្រះរាជអាជ្ញាត្រូវបានចាត់ទុកថាជាចៅក្រមក៏ដោយ ក៏គេមិនអាចប្តឹងជិតចិត្តចៅក្រមអយ្យការបានដែរ ។ ចៅក្រមអយ្យការធ្វើការងារតំណាងឲ្យស្ថាប័នរបស់ខ្លួន ដើម្បីការពារផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ទូទៅរបស់សង្គម ។ ចៅក្រមអយ្យការអាចតំណាងឲ្យគ្នាទៅវិញទៅមកបាននៅគ្រប់កិច្ចនីតិវិធីទាំងអស់ ដូច្នេះសេចក្តីសម្រេចរបស់ចៅក្រមអយ្យការ ត្រូវបានចាត់ទុកជាសេចក្តីសម្រេចរបស់អង្គអយ្យការទាំងមូលផងដែរ ។

ម្យ៉ាងទៀតតំណាងអយ្យការមានឋានៈត្រឹមតែជាភាគីនៃរឿងក្តីប៉ុណ្ណោះ ដូច្នេះសេចក្តីសម្រេចរបស់ចៅក្រមអយ្យការគ្រាន់តែជាការប្តឹងសុំឲ្យតុលាការអនុវត្តន៏ច្បាប់តែប៉ុណ្ណោះ គ្មានអានុភាពជាការសម្រេចសេចក្តីអំពីទោសឡើយ ។[45]

**៤ គោលការណ៍អវិភាគកម្ម**

គោលការណ៍អវិភាគ សំដៅដល់ការបំពេញការងាររបស់សមាជិកម្នាក់ៗនៃអង្គអយ្យការតំណាងឲ្យអង្គភាពរួម ឬដើម្បីប្រយោជន៍សមូហភាព ក្នុងគោលដៅធ្វើឲ្យសង្គមមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព ។ យោងតាមគោល

[44]ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា ៧៥
[45] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៥៥៦

ការណ៍នេះ ទើបបានជានៅចំពោះមុខសាលាជម្រះក្តីទាំងអស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងតែងតែប្រើប្រាស់ពាក្យថា " យើងជាតំណាងអយ្យការ " ធ្វើសេចក្តីសន្និដ្ឋានតាំងនាមឲ្យអង្គការអយ្យការ ។[46]

ចំណែកឯមាត្រា៧៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានបញ្ញត្តិថា អង្គការអយ្យការគឺជាអង្គអវិភាគ ដែលតម្រូវឲ្យព្រះរាជអាជ្ញាដែលបំពេញមុខងារនៅអយ្យការអមសាលាជម្រះក្តីនីមួយៗមានកាតព្វកិច្ចរួមគ្នាក្នុងមុខងារហើយអាចជំនួសគ្នាទៅវិញទៅមកបាន ។ តាមគោលការណ៍នេះ តំណាងអយ្យការច្រើនរូបអាចបន្តការងារពីគ្នាបាន នៅក្នុងសំណុំរឿងតែមួយតាមរយៈការចាត់តាំងរបស់នាយឋានានុក្រមរបស់ខ្លួនបាន ។

**៥ គោលការណ៍មិនទទួលខុសត្រូវ**

ចៅក្រមអយ្យការបំពេញការងារជាសមូហភាព ធ្វើសេចក្តីសន្និដ្ឋានសម្រេចចិត្តតំណាងឲ្យអង្គអយ្យការរបស់ខ្លួនទាំងមូលមិនមែនក្នុងនាមបុគ្គលណាមួយឡើយ ហេតុដូច្នេះបានជាចៅក្រមអយ្យការមិនបានដាក់ឲ្យទទួលខុសត្រូវ ចំពោះការធ្វើសេចក្តីសម្រេចចិត្តរបស់ខ្លួនណាមួយឡើយ ។ ម្យ៉ាងទៀតនៅក្នុងចំណាត់ការសំណុំរឿងក្តី ក៏មិនបានមើលឃើញថាព្រះរាជអាជ្ញាមានសិទ្ធិអំណាចពាក់ព័ន្ធនិងការសម្រេចចិត្តផងដែរ ព្រោះថាចៅក្រមអយ្យការមានតួនាទីត្រឹមតែជាភាគីនៃរឿងក្តី ដែលមានសិទ្ធិត្រឹមតែស្នើសុំឲ្យតុលាការអនុវត្តច្បាប់តែប៉ុណ្ណោះ ។

## ផ្នែកទី ១ មូលហេតុទូទៅ

បណ្តឹងអាជ្ញានិងរលត់ កាលបើមានមូលហេតុទាំងឡាយដូចខាងក្រោមៈ

### ១.១ មរណភាពនៃជនល្មើស

ប្រសិនបើជនល្មើសទទួលមរណភាព មុនពេលមានបណ្តឹងអាជ្ញា ឬស្លាប់មុនពេលមានសេចក្តីសម្រេចផ្តន្ទាទោសជនល្មើស បណ្តឹងអាជ្ញាត្រូវរលត់ ។

ការរលត់ប្រភេទនេះ គឺវាមានលក្ខណៈឯកត្តបុគ្គលតឹងរឹងខ្លាំងទៅនិងជនល្មើស ដែលវាមិនបានផ្តល់ប្រយោជន៏ដល់សហចារី អ្នកសមគំនិត ឬអ្នកផ្តើមគំនិត និងមិនអាចបង្កជាបញ្ហាដល់ការរឹបអូសនានាដែលអាចត្រូវបានធ្វើនៅក្នុងពេលដំណើរការនីតិវិធីនោះឡើយ ។ យោងតាមមាត្រា២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់ថា ប្រសិនបើជនជាប់ចោទទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ ទោះបីជាបណ្តឹងអាជ្ញារលត់ក៏ដោយ ក៏តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនិងសិទ្ធិវន្តរបស់ជនជាប់ចោទបានដែរ ។

[46] មេធាវី កុយ នាម សៀវភៅស្តីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប ឆ្នាំ២០០៦ ទំព័រទី ៧៤

### ១.២ ការផុតអាជ្ញាយុកាល

អវត្តមាននៃការធ្វើឲ្យមានចលនានៃបណ្ដឹងអាជ្ញា ក្នុងអំឡុងពេលមួយដែលគិតរាប់ចាប់ពីការប្រព្រឹត្តបទល្មើស ឬក្នុងករណីដែលបណ្ដឹងអាជ្ញាត្រូវបានធ្វើឲ្យមានចលនារួចហើយ តែអវត្តមាននៃការបន្តការអនុវត្តបណ្ដឹងអាជ្ញា និងបង្កើតឲ្យមានការរលត់បណ្ដឹងអាជ្ញា ដោយសារការផុតអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា ។[47]

លើកលែងតែបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម ដែលមិនអាចផុតអាជ្ញាយុកាលបានទេ ។

អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាមានដូចតទៅៈ

- ១៥ ( ដប់ប្រាំ ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ ( ប្រាំ ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ ( មួយ ) ឆ្នាំ ចំពោះបទលហុ ។[48]

ចិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្ដើមគិតពីពេលប្រព្រឹត្តបទល្មើស ។ អាជ្ញាយុកាលត្រូវផ្ដាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗនាំឲ្យចាប់ផ្ដើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល ស្របតាមចិរវេលាកំណត់ដូចខាងលើ ។ ចិរវេលាថ្មីអាចយកទៅជំទាស់បានចំពោះជនគ្រប់រូបដែលទាក់ទិននៅក្នុងរឿងនេះ ។

#### ១.២.១ ការផុតអាជ្ញាយុកាលនៃបទល្មើស

ការផុតអាជ្ញាយុកាលនៃបទល្មើស ជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់បានទេ ឬនិយាយម្យ៉ាងទៀតថា ព្រះរាជអាជ្ញាពុំអាចដាក់បណ្ដឹងអាជ្ញាឲ្យមានចលនាបានឡើយ ។ ចិរវេលានៃអាជ្ញាយុកាលប្រែប្រួលទៅតាមប្រភេទនីមួយៗនៃបទល្មើស ។ ដោយអនុលោមតាមមាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា លើកលែងតែបទប្បញ្ញត្តិនៃមាត្រា៩ ( ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់ ) នៃក្រមនេះ ។ [49]

ជាគោលការណ៍អាជ្ញាយុកាលនៃបទល្មើស ចាប់ផ្ដើមគិតពីថ្ងៃដែលបានប្រព្រឹត្តបទល្មើសតទៅ ។

#### ១.២.២ ការផុតអាជ្ញាយុកាលនៃទោស

ជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ទោសពុំអាចអនុវត្តបានទៀតទេ ។ អនុលោមតាមមាត្រា១៤៤ នៃក្រមព្រហ្មទណ្ឌ បានកំណត់ចិរវេលាអាជ្ញាយុកាលនៃទោសមានដូចតទៅៈ

---

[47] សាលាគំនិតត្រាជូ ចក សម្បត្តិ, នីតិវិធីព្រហ្មទណ្ឌ ការបោះពុម្ពលើកទី១ ឆ្នាំ២០១៥ ទំព័រ ៧៣

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១០

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៧

- ទោសដែលប្រកាសចំពោះបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ ( ម្ភៃ ) ឆ្នាំ ។
- ទោសដែលប្រកាសចំពោះបទមជ្ឈិមមានអាជ្ញាយុកាល ៥ ( ប្រាំ ) ឆ្នាំ ។
- ទោសដែលប្រកាសចំពោះបទលហុមានអាជ្ញាយុកាល ១ ( មួយ ) ឆ្នាំ ។

ចិរវេលានេះ ចាប់ផ្ដើមគិតពីថ្ងៃដែលសេចក្ដីសម្រេចផ្ដន្ទាទោសបានចូលជាស្ថាពរ ។

## ១.៣. ការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅ ជាមូលហេតុនៃការរលត់បណ្ដឹងអាជ្ញា តែក្នុងករណីដែលការលើកលែងទោសទូទៅត្រូវបានធ្វើឡើងនៅមុខការផ្ដន្ទាទោសជាស្ថាពរលើជនល្មើសតែប៉ុណ្ណោះ ។ ប្រសិនបើវាត្រូវបានធ្វើក្រោយការផ្ដន្ទាទោសជាស្ថាពរ ឬក្នុងអំឡុងពេលអនុវត្តទោស នោះការលើកលែងទោសជាទូទៅ គឺជាមូលហេតុនៃការរលត់ទោសទៅវិញ ។

### ១.៣.១ អានុភាព

អានុភាពនៃការលើកលែងទោសជាទូទៅ ក៏បានជាប្រយោជន៍ដល់អ្នកសមគំនិតនៃអំពើល្មើសដែរ រឿងចម្បងគឺវាលែងបង្ហាញឡើងនូវលក្ខណៈផ្ដន្ទាទោសនោះទៀតហើយ ។ យើងអាចនិយាយបានថា ការលើកលែងទោសជាទូទៅ វាមានអានុភាពតែទៅលើទោសទេ តែវាមិនមានអានុភាពទៅលើការចោទប្រកាន់នោះទេ ប្រសិនបើវាត្រូវបានធ្វើក្រោយការផ្ដន្ទាទោសជាស្ថាពរ ឬទោសនោះកំពុងអនុវត្ត ។

ការលើកលែងទោសជាទូទៅ មានចែងក្នុងមាត្រា ៩០ ថ្មី វាក្យខណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានលុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនិងច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ។[50]

ការលើកលែងទោសជាទូទៅនាំឲ្យ:

- ទោសមិនអាចយកមកអនុវត្តទេ ។
- ទោសដែលកំពុងអនុវត្តត្រូវតែបញ្ចប់ ។

ប៉ុន្តែចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្ដី ដែលបានបង់រួចហើយមិនអាចទាមទារសំណងពីរដ្ឋវិញបានទេ ។ យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់មាត្រា៩០ ថ្មី កថាខណ្ឌទី៤ អះអាងថា រដ្ឋសភាអនុម័តច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ ។ ដូច្នេះមានន័យថា កាលណាបើមានច្បាប់ស្ដីពីការលើកលែងទោសជាទូទៅសម្រេចថាបទល្មើសណាមួយ ឬស្ថានភាពណាមួយដោយច្បាប់បានកំណត់ថាត្រូវបានលើកលែងទោសនោះព្រះរាជអាជ្ញានិងមិនធ្វើការចោទប្រកាន់ចំពោះស្ថានភាពនោះទេ ។

[50] ច្បាប់ស្ដីពីពន្ធនាគារ ចូលជាធរមាន ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ មាត្រា ៧៩

ផ្អែកតាមច្បាប់ស្តីពីការលើកលែងទោសជាទូទៅ និងមានកំណត់ក្នុងរដ្ឋធម្មនុញ្ញផងដែរនោះបានតម្រូវឲ្យមានមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ( មាត្រា ៩០ ថ្មី នៃរដ្ឋធម្មនុញ្ញ ) ។ ច្បាប់លើកលែងទោសជាទូទៅកំណត់ពីដែនអនុវត្តរបស់ខ្លួន ។ ច្បាប់លើកលែងទោសជាទូទៅអាចអនុម័តបានដោយមានមូលហេតុយ៉ាងច្រើនដូចជាៈ កុំឲ្យមានទណ្ឌិតក្នុងពន្ធនាគារច្រើនពេកក្នុងឱកាសហេតុការណ៍សំខាន់ៗណាមួយ ។ល ។[51]

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅអាចពាក់ព័ន្ធជាទូទៅទាំងទណ្ឌកម្មព្រហ្មទណ្ឌ និងទណ្ឌកម្មរដ្ឋបាល ច្បាប់លើកលែងទោសជាទូទៅ កំណត់ច្បាស់លាស់ពីការបរិច្ឆេទដែលក្នុងនោះការប្រព្រឹត្តបទល្មើសត្រូវតែលើកលែង ឬពីប្រភេទនៃបទល្មើសដែលត្រូវលើកលែងឬពីទោសប្រកាសដែលត្រូវតែលើកលែង ។

ឧទាៈ ទណ្ឌិតដែលជាអនីតិជនទាំងអស់ដែលត្រូវបានផ្តន្ទាទោសដោយតុលាការពី ៦ ខែទៅ ៣ ឆ្នាំទាំងអស់ត្រូវលើកលែង ឬពីគុណសម្បត្តិរបស់ចារីនៃបទល្មើសដែលត្រូវលើកលែងទោសនោះ ។[52]

ឧទាៈ ចារីដែលជាជនចាស់ជរា ដែលមានអាយុលើសពី ៧០ ឆ្នាំ ជាដើម ។ ជាទូទៅករណីដូចខាងក្រោមនេះ ច្បាប់លើកលែងទោសជាទូទៅ តម្រូវឲ្យទណ្ឌិតដែលមានអាយុចាប់ពី ៧០ ឆ្នាំឡើងធ្វើពាក្យស្នើសុំថ្វាយព្រះមហាក្សត្រក្នុងរយៈពេលណាមួយណាមួយកំណត់ ហើយព្រះរាជក្រឹត្យនឹង ធ្វើការលើកលែងទោសជាបន្ទាប់ពីមានការសិក្សាទៅលើករណីនីមួយៗ ។ ចំពោះការលើកលែងទោសដែលបានកំណត់ដោយច្បាប់ ក៏អាចមានលក្ខខណ្ឌមួយចំនួនផងដែល ។[53] ឧទាហរណ៍ៈ មុននឹងលើកលែងទោសត្រូវបង់ប្រាក់ពិន័យឲ្យអស់ផងដែរ ។

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ អាចកំណត់ថា បទល្មើសមួយចំនួនមិនទទួលបានផលប្រយោជន៍ពីការលើកលែងទោសជាទូទៅនេះបានទេ ។ [54] ឧទាហរណ៍ៈ ចំពោះបទល្មើសស្តីពីភេរវកម្មជាដើម ។

ច្បាប់លើកលែងទោសជាទូទៅ មានអានុភាពលុបចោលដោយប្រតិសកម្មនូវការផ្តន្ទាទោសអំពើល្មើស ។ អំពើល្មើសដែលទទួលបាននូវការលើកលែងទោសត្រូវបានគេចាត់ទុកថាមិនមែនជាបទល្មើសឡើយ ។ អាស្រ័យហេតុនេះការលើកលែងទោសជាទូទៅមានអានុភាពដូចខាងក្រោមៈ

- ចំពោះអំពើល្មើសដែលទទួលបាននូវការលើកលែងទោស ហើយមិនទាន់ត្រូវបានវិនិច្ឆ័យដោយតុលាការនៅឡើយ បណ្តឹងអាជ្ញាត្រូវរលត់ ចៅក្រមមិនអាចផ្តន្ទាទោសចារីបានោឡើយ ។ ប្រសិនបើការលើកលែងទោសធ្វើឡើងដោយអនុលោមទៅតាមអត្រាទោសប្រកាសវិញចៅក្រមត្រូវប្តាសទោសជាមុនសិនទើបអាចដឹងថាទោសចូលទៅក្នុងអត្រាដែលត្រូវលើកលែងទោសឬអត់ ។

[51] ច្បាប់ស្តីពីពន្ធនាគារ ចូលជាធរមាន ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ មាត្រា ៧៨
[52] ច្បាប់ស្តីពីពន្ធនាគារ ចូលជាធរមាន ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ មាត្រា ៨០
[53] ច្បាប់ស្តីពីពន្ធនាគារ ចូលជាធរមានថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ មាត្រា ៧៧
[54] ច្បាប់ស្តីពីពន្ធនាគារ ចូលជាធរមានថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ មាត្រា ៧៦

- ប្រសិនបើមានការផ្តន្ទាទោសជាស្ថាពរ ការផ្តន្ទាទោសនោះត្រូវទុកជាឥតបានការ អាស្រ័យហេតុនេះ គេត្រូវលុបការផ្តន្ទាទោសចេញពីបញ្ជីថ្កោលទោស។[55] បើជនជាប់ចោទកំពុងតែទទួលរងទោសជាប់ពន្ធនាគារ នោះត្រូវតែដោះលែងភ្លាម ។ ប៉ុន្តែប្រសិនបើជនជាប់ចោទបានបង់ប្រាក់ពិន័យរួចហើយ ជនជាប់ចោទពុំអាចទារសំណងវិញបានឡើយ ។[56]

ការលើកលែងជាទូទៅមិនមែនជាឧបសគ្គក្នុងការទាមទារសំណងជម្ងឺចិត្តពីសំណាក់ជនរងគ្រោះទេ ។[57]

### ១.៣.២ ការបន្ធូរបន្ថយទោស ការលើកលែងទោស និងការដោះលែងទណ្ឌិត

ដោយយោងតាមមាត្រា ៧៤ នៃច្បាប់ស្តីពន្ធនាគារបានបញ្ញត្តិ អភិបាលរាជធានី ខេត្ត ត្រូវបានបង្កើតគណៈកម្មការមួយដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅក្នុងពន្ធនាគារដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណៈសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោសនិងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ តាមរយៈអគ្គនាយកនៃអគ្គនាយកពន្ធនាគារយ៉ាងយឺតបំផុត ៣០ ( សាមសិប ) ថ្ងៃ មុនថ្ងៃកំណត់ពីធីបុណ្យនីមួយៗ ។

ចំពោះគណៈកម្មការនេះមានសមាសភាពដូចខាងក្រោមៈ

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធាន
- តំណាងអង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត ជាអនុប្រធាន
- ប្រធានក្រុមការងារប្រលងប្រណាំងនៃពន្ធនាគាររាជធានី ខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍
- អនុប្រធានពន្ធនាគាររាជធានី ខេត្ត ទទួលបន្ទុកអប់រំកែប្រែ ជាសមាជិក
- អនុប្រធានពន្ធនាគាររាជធានី ខេត្ត ទទួលបន្ទុកប្រតិបត្តិ ជាសមាជិក

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។[58]

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបានបង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិតក្នុងរយៈពេលជាប់ឃុំនៅតាមមណ្ឌលអប់រំកែប្រែដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការ

[55] ច្បាប់ស្តីពីពន្ធគារ ចូលជាធរមានថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មាត្រា ៧៩

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១៤៩ កថាខណ្ឌទី៤

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១៥១

[58] ច្បាប់ស្តីពីពន្ធនាគារ ចូលជាធរមានថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មាត្រា ៧៤

នេះត្រូវធ្វើជាបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណៈសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោសដែលនិងត្រូវលើកលែងទោសជាទូទៅបញ្ជូនទៅគណៈកម្មការជាតិ យ៉ាងតិចបំផុត ៣០ ( សាមសិប ) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

ចំពោះគណៈកម្មការនេះមានសមាសភាពដូចខាងក្រោមៈ

- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកពន្ធនាគារ ជាប្រធាន
- តំណាងអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ចលើមណ្ឌលអប់រំកែប្រែសាមី ជាអនុប្រធាន
- ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ជាអនុប្រធាន
- អគ្គនាយកដ្ឋានពន្ធនាគារ ជាអនុប្រធានអចិន្ត្រៃយ៍
- ប្រធាននាយកដ្ឋានប្រតិបត្តិ ជាសមាជិក
- ប្រធាននាយកដ្ឋានអប់រំកែប្រែ ជាសមាជិក
- ប្រធានក្រុមការងារប្រឡងប្រណាំងនៃមណ្ឌលអប់រំកែប្រែនីមួយៗ ជាសមាជិក

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ។[59]

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ដែលបានផ្ញើមកពីគណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីដាក់សំណើរថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងមានលើកលែងទោសឲ្យទណ្ឌិត យ៉ាងតិចបំផុត ១០ ( ដប់ ) ថ្ងៃ មុនថ្ងៃកំណត់ពិធីបុណ្យនីមួយៗ ។

ចំពោះគណៈកម្មការនេះមានសមាសភាពដូចខាងក្រោមៈ

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកពន្ធនាគារ ជាអនុប្រធានអចិន្ត្រៃយ៍
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាអនុប្រធានអចិន្ត្រៃយ៍
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់ចំនួន ០១ រូប ជាសមាជិក
- ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ជាសមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ជាសមាជិក
- តំណាងក្រសួងយុត្តិធម៌ចំនួន ០១ រូប ជាសមាជិក
- ប្រធាននាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានពន្ធនាគារ ជាសមាជិក
- ប្រធាននាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានចំនួន ០២ រូប ជាសមាជិក

[59] ច្បាប់ស្តីពន្ធនាគារ ចូលជាធរមានថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ មាត្រា ៧៥

គណៈកម្មនេះអាចមានសមាសភាពមួយចំនួននេះជាការចាំបាច់ [60]។ ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ លក្ខណៈសម្បត្តិនិង ចំណាត់ថ្នាក់ប្រឡងប្រណាំង សំដៅជម្រុញលើកទឹកចិត្តដល់ទណ្ឌិតម្នាក់ៗ ឲ្យខិតខំប្រឹងកែប្រែគំនិតមារយាទក្លាយជាពលរដ្ឋល្អដើម្បីធ្វើសមាហរណកម្មបញ្ចូលទៅក្នុងសង្គមជាតិវិញបាននៅពេលអនាគតត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែមិនត្រូវបាប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការថ្នាក់ជាតិ ដូចមានចែងក្នុងមាត្រា ៧៥ នៃច្បាប់ស្តីពីពន្ធនាគារ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ ។ ក្នុងករណីចាំបាច់ ប្រមុខរាជរដ្ឋាភិបាលមានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំស្នើលើកលែងទោសឲ្យទណ្ឌិតនៅពេលណាក៏បាន [61]។

### ១.៣.៣ ចំពោះបុណ្យជាតិ

ត្រូវមានលក្ខខណ្ឌបែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោស និងការលើកលែងទោសត្រូវកំណត់ព្រះរាជក្រឹត្យ ។ គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារ មួយ ឬច្រើនអាចត្រូវបានដោះលែងដោយបានមានលក្ខខណ្ឌប្រសិនបើទណ្ឌិតនោះបានបង្ហាញខ្លួនឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលចាប់ឃុំ និងមានសម្បទាដែលអាចបញ្ជូនខ្លួនទៅក្នុងសង្គមវិញបាន ។

លក្ខខណ្ឌនិងបែបបទនៃការអនុវត្តការដោះលែងដោយមានលក្ខខណ្ឌក្នុងច្បាប់នេះត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ ប្រធានពន្ធនាគារត្រូវធ្វើការដោះលែងជនជាប់ឃុំក្រោយពីបានការទទួលបានលិខិតសម្រេចពីអាជ្ញាធរតុលាការ ។ ជាគោលការណ៍ ទណ្ឌិតដែលមានទោសរបស់ត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិបានកំណត់ ត្រូវតែដោះលែងឲ្យមានសេរីភាពវិញ នៅមុនថ្ងៃឈប់សម្រាកនោះ ស្របតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។[62]

## ១.៤.និរាករណ៍ច្បាប់ព្រហ្មទណ្ឌ

និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ គឺសំដៅដល់គោលការណ៍នៃការច្រានចោល ឬលុបចោលនូវបទបញ្ញត្តិរបស់ច្បាប់ព្រហ្មទណ្ឌចាស់ ដោយមូលហេតុច្បាប់ព្រហ្មទណ្ឌថ្មីដែលបានបង្កើតនោះមិនមានចែង ឬមានចែងផ្ទុយនិងបទបញ្ញត្តិនៃច្បាប់ចាស់ ។ វាត្រូវបានយកមកអនុវត្តនៅពេលដែលច្បាប់ព្រហ្មទណ្ឌថ្មីនោះ មានអានុភាព

[60] ច្បាប់ស្តីពីពន្ធនាគារ ចូលជាធរមានថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មាត្រា ៧៤ កថាខណ្ឌទី២

[61] ច្បាប់ស្តីពីពន្ធនាគារ ចូលជាធរមានថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ មាត្រា ៧៥,៧៦

[62] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចូលជាធរមានថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា២៧

អនុវត្តចូលជាធរមាន ហើយបានបញ្ញត្តិអំពីលក្ខខណ្ឌនៃការអនុវត្ត និងវិធាននៃការនិរាករណ៍ចំពោះបទបញ្ញត្តិព្រហ្មទណ្ឌពីមុន ។

កាលអនុវត្តច្បាប់ដែលបានលុបចោលបទល្មើស គឺសំដៅទៅលើបទបញ្ញត្តិដែលលុបចោលបទល្មើសណាមួយនោះត្រូវតែអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទបញ្ញត្តិនោះចូលជាធរមាន មិនអាចចោទប្រកាន់បានទៀតឡើយ ហើយការចោទប្រកាន់នោះកំពុងតែប្រព្រឹត្តក៏ត្រូវបានបញ្ចប់ដែល ។[63] ដូច្នេះនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ គឺជាការច្រានចោលនូវបទបញ្ញត្តិរបស់ច្បាប់ព្រហ្មទណ្ឌចាស់ដែលផ្ទុយនឹងបទបញ្ញត្តិរបស់ច្បាប់ព្រហ្មទណ្ឌ ថ្មី នៅពេលដែលច្បាប់ថ្មីចូលជាធរមានដែលមានអានុភាពអនុវត្ត នេះគឺមានការពាក់ព័ន្ធនិងគោលការណ៍នីត្យានុកូលភាពសុទ្ធសាធ ព្រោះច្បាប់ដែលកំណត់អំពើមួយជាបទល្មើសលុះត្រាច្បាប់នោះនៅជាធរមានទើបមានអានុភាពអនុវត្ត ។ ដោយសារច្បាប់ត្រូវបាននិរាករណ៍ដោយច្បាប់ថ្មីហើយ ដូចនេះជាគោលការណ៍អំពើដែលច្បាប់មុនកំណត់ជាបទល្មើសតែត្រូវបានច្បាប់ថ្មីបដិសេធ អំពើនោះមិនអាចត្រូវបានចោទប្រកាន់ទៀតឡើយ ។

អានុភាពនៃបទបញ្ញត្តិ ដែលលុបចោលបទល្មើសនេះមិនត្រឹមតែហាមមិនអោយចោទប្រកាន់ទេ តែថែមទាំងការកំណត់ថារាល់ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តក៏ត្រូវបានបញ្ចប់ ហើយបើមានការប្រកាសទោសរួចហើយការផ្តន្ទាទោសនេះមិនត្រូវអនុវត្តបានទេ ឬត្រូវតែបញ្ឈប់ការអនុវត្ត ។ [64]

### ១.៤.១ និរាករណ៍នៃច្បាប់ដោយតុណ្ហីភាព

ចំពោះការនិរាករណ៍ប្រភេទនេះគឺសំដៅច្បាប់ណាមួយដែលកំពុងត្រូវបានអនុវត្ត រហូតមកដល់ថ្ងៃដែលថ្ងៃដែលច្បាប់ថ្មីមួយទៀតបានចូលខ្លួនជាធរមាន ហើយបានប្រកាសឲ្យប្រើដោយមិនបានប្រកាសបញ្ជាក់ច្បាស់លាស់ថាច្បាប់ចាស់ត្រូវបានលុប ឬឈប់ប្រើដោយស្ងៀមស្ងាត់ស្រាប់តែច្បាប់ថ្មីបានបង្ហាញខ្លួនជំនួសតែម្តង ។

### ១.៤.២ និរាករណ៍នៃច្បាប់ ដោយមានការបង្ហាញខ្លួននៃច្បាប់ថ្មី

ចំពោះការនិរាករណ៍នៃច្បាប់ប្រភេទនេះវិញគឺ តែងតែឃើញថាមានលក្ខណៈងាយស្រួលយល់ជាងការនិរាករណ៍នៃច្បាប់ដោយតុណ្ហីភាព ។ ព្រោះអង្គការនីតិប្បញ្ញត្តិមុននិងប្រកាសឲ្យប្រើច្បាប់ថ្មីគឺ ត្រូវបានធ្វើការផ្សព្វផ្សាយក្នុងរយៈពេលតែមួយឲ្យមហាជនបានដឹងបានស្គាល់ និងមានច្បាប់ថ្មីមកជំនួសច្បាប់ដែលអនុវត្តច្បាប់អន្តរកាលវិញ ។[65]

## ១.៥. អាជ្ញាអស់ជំនុំ

ជាប្រភេទនៃការចោទប្រកាន់ចំពោះបទល្មើសណាមួយឬអំពើណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួន

[63] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៩ កថាខណ្ឌទី១

[64] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ១០

[65] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៩

ស្ថាពរហើយជននោះមិនត្រូវបានធ្វើការចោទប្រកាន់ចំពោះបទល្មើសដដែលទៀតទេ ។ ជាគោលការណ៍ទោះបីជាស្ថិតក្រោមការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ[66] ។ ការទទួលយកគោលការណ៍អាជ្ញាអស់ជំនុំនេះគឺ ដើម្បីធានាចំពោះជំនឿរបស់ប្រជាពលរដ្ឋលើអង្គតុលាការ និងធានាដល់សិទ្ធិរបស់ប្រជាពលរដ្ឋ ដែលកំណត់ក្នុងកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។[67]

ប្រសិនបើក្នុងរឿងព្រហ្មទណ្ឌ តុលាការបានសម្រេចសេចក្តីដាក់ទោសជនជាប់ចោទនោះបានសេចក្តីថាជនជាប់ចោទមានកំហុស ហេតុដូចនេះបណ្តឹងរដ្ឋប្បវេណីនិងទទួលបានជោគជ័យដោយស្វ័យប្រវត្តិ ។ ផ្ទុយទៅវិញប្រសិនបើតុលាការសម្រេចឲ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ ជនរងគ្រោះក៏ពុំអាចនិងទទួលបាននូវសំណងពីការខូចខាតពីជនជាប់ចោទដែរ ។ ប៉ុន្តែករណីខ្លះទោះបីជាតុលាការឲ្យជនជាប់ចោទរួចផុតពីបទចោទក៏ដោយក៏ជនរងគ្រោះនៅតែទទួលបានសំណងដែរ ។ ព្រោះថាអំពើរបស់ជនជាប់ចោទ ពុំមែនជាបទល្មើសតែជាអំពើល្មើសផ្នែករដ្ឋប្បវេណី ។

គោលការណ៍មិនអាចជំនុំជម្រះពីរដងក្នុងរឿងតែមួយ នាំឲ្យមានផលវិបាកនិងមានកំណត់តាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ ដោយបានកំណត់ថាបណ្តឹងអាជ្ញាពុំអាចធ្វើបានទៀតទេ ប្រសិនបើមានសាលក្រមតុលាការ សម្រេចដោះលែងជនជាប់ចោទចំពោះអំពើដដែលនេះ ទោះបីជាក្រោយពេលមានសាលក្រមស្ថាពរហើយ គេរកឃើញភស្តុតាងដាក់បន្ទុកថ្មីក៏ដោយ ។[68] ចំពោះបទល្មើសដែលត្រូវបានតុលាការជំនុំជម្រះរួចហើយឬបានចូលជាស្ថាពររួចទាំងការអនុវត្តទោសគ្រប់គ្រាន់ទោះជាមានអំពើថ្មីតែអង្គហេតុ និងអង្គច្បាប់ដូចគ្នាទាំងកម្មវត្ថុនោះ គឺមិនត្រូវបានធ្វើការចោទប្រកាន់ទៀតនោះទេចំពោះអំពើដដែលៗ ។

### ១.៥.១ គោលការណ៍មិនអាចជំនុំជម្រះពីរដងក្នុងរឿងតែមួយ

ក្នុងគោលការណ៍នៃការមិនជំនុំជ្រះក្តីពីរដងក្នុងរឿងតែមួយ គឺដោយសារតែមានគោលការណ៍ដែលមានចែងក្នុងបទបញ្ញត្តិមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានប្បញ្ញត្តិថាៈ *អនុលោមតាមគោលការណ៍ អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានចោទប្រកាន់ទៀតទេចំពោះអំពើដដែលទោះបីជាក្រោយការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ ។*[69]

---

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៩

[67] កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៩ មាត្រា១៤ ចំណុចទី៧

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១២

[69] ការអនុវត្តក្នុង អង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា ឬហៅកាត់ថា អ.វ.ត.ក ចំពោះបទល្មើសដូចបានចោទប្រកាន់ក្នុងរឿងក្តីលោក អៀង សារី ត្រូវតែដូចគ្នាយ៉ាងជាក់លាក់ទៅនិងការសម្រេចឲ្យជាប់ពិរុទ្ធភាព ក្នុងការសម្រេចឲ្យផុតពីបទចោទនាពេលកន្លងមកៈ

- គោលការណ៍នៃអាជ្ញាអស់ជំនុំនៅក្នុងច្បាប់កម្ពុជា រារាំងការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីថ្មីចំពោះអំពើដូចគ្នា (ប៉ុន្តែពុំមែនជាបទល្មើសដូចគ្នានោះទេ ) ។

ប្រទេសកម្ពុជា គឺជាភាគីនៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ( ICCPR ) ដែលបញ្ញត្តិតាមគោលការណ៍ច្បាប់អន្តរជាតិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញអំពីរបៀបដែលមាត្រាស្រដៀងគ្នាទាំងឡាយនៅក្នុងកតិការសញ្ញា ICCPR ត្រូវបានបកស្រាយនិងអនុវត្តដោយស្ថាប័នអនុវត្តរបស់ខ្លួន គឺគណៈកម្មាធិការសិទ្ធិមនុស្ស ។

### ១.៥.១.១ ការការពារពីការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល

ប្រភពឯកសារនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ

| |
|---|
| ក.អ.ស.ព.ន "គ្មានជនណាម្នាក់ត្រូវបានយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើងវិញចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ ។" ក.អ.ស.ន ( មាត្រា១៤ ) កថាខណ្ឌទី៧ ។ |
| ក្រមព្រហ្មទណ្ឌ ( មាត្រា២៣ ) "ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនិងបុគ្គលណាម្នាក់ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយដែលក្នុងករណីការផ្តន្ទាទោស តាមបុគ្គលនោះបានបង្ហាញថា ខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។" |
| ក្រមនីតិវិធីព្រហ្មទណ្ឌ ( មាត្រា១២ ) "ដោយអនុវត្តតាមគោលការណ៍ *អាជ្ញាអស់ជំនុំ* ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀត ។" |

ការវិនិច្ឆ័យ[70]ទោសពីរដងចំពោះបទល្មើសដដែល ឬគោលការណ៍ *អាជ្ញាអស់ជំនុំ* ( ពាលគឺថា "បានវិនិច្ឆ័យរួចហើយ" )សំដៅលើសិទ្ធិរបស់បុគ្គលដែលមិនត្រូវឲ្យមានការជំនុំជម្រះលើសពីរម្តងចំពោះអំពើ ឬបទល្មើសដដែល ក្នុងករណីនេះ កំណត់ថាសេចក្តីសម្រេចស្ថាពររបស់តុលាការ ទោះបីជាការលើកលែង ឬការផ្តន្ទាទោសជនជាប់ចោទក្តីនិងក្លាយជារបាំងហាមចំពោះការចោទប្រកាន់បន្ថែមទៀតទៅលើអំពើល្មើសដដែលនោះ។[71]មានអត្ថប្រយោជន៍ជាច្រើនសម្រាប់ទាំងបុគ្គលជាជនជាប់ចោទនិងសង្គមជារួមក្នុងការទទួលយកសេចក្តីសម្រេចចុងក្រោយនេះរួមទាំងការផ្តល់ភាពច្បាស់លាស់ផ្នែកច្បាប់និងបង្ការនូវភាពខ្វះខ្នាយធនធានផ្នែកច្បាប់នៅពេល មានសេចក្តីសម្រេចត្រូវបានធ្វើរួចរាល់ ។

ជនណាម្នាក់ដែលត្រូវបានសម្រេចឲ្យមានពិរុទ្ធភាពពីបទល្មើសណាមួយមិនអាចត្រូវបានជំនុំជម្រះលើបទល្មើសនេះសារជាថ្មីបានទេ ជាពិសេសនៅពេលជំនុំជម្រះរួមជាមួយនិងបទល្មើសផ្សេងទៀត ។ នេះគឺជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយការរំលោភបែបនេះកាន់តែមានភាពធ្ងន់ធ្ងរ នៅពេលដែលយកមកជំនុំជម្រះឡើងវិញ ពីព្រោះថាគណៈកម្មការវិនិច្ឆ័យបានស្តាប់ព័តមានលម្អៀងដែលពុំពាក់ព័ន្ធនិង

[71] ក្រមនីតិព្រហ្មទណ្ឌចូលជាធរមានថ្ងៃទិ១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១២

បទចោទដែលជននេះត្រូវបានជំនុំជម្រះយ៉ាងត្រឹមត្រូវរួចមកហើយ ។ [72] គ្មានការរំលោភសិទ្ធិ ប្រសិនបើការសម្រេចឲ្យរួចផុតពីបទចោទត្រូវបានច្រានចោលមុនពេលចូលជាស្ថាពរសិទ្ធិពុំត្រូវបានគេជម្រះពីរដងចំពោះបទល្មើសដែលបានសម្រេចនិងចេញសាលក្រម ។

ការរំលោភសិទ្ធតាមការច្រានចោលលើសេចក្តីសម្រេចឲ្យរួចផុតពីបទចោទ ដោយអនុវត្តតាមអនុភាពនៃគោលការណ៍ប្រតិសកម្មមានន័យថា សិទ្ធិត្រូវបានកាត់ទោសពីរដងចំពោះបទល្មើសដដែលត្រូវបានកំណត់នៅពេលតុលាការច្រានចោលសេចក្តីសម្រេចឲ្យរួចផុតពីបទចោទដោយផ្អែកលើមូលដ្ឋាន នៃការអនុវត្តច្បាប់តាមអនុភាពប្រតិសកម្មចំពោះអង្គហេតុដែលពុំបានបង្កើតជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលដែលអំពើសកម្ម និងអំពើអកម្មបានកើតឡើង ។[73]

### ១.៥.២ ផលវិបាកនៃការជំនុំជម្រះលើរឿងក្តីតែមួយ

ជាទូទៅនៅពេលដែលជនណាម្នាក់ត្រូវបានតុលាការសម្រេចឲ្យរួចផុតពីបទចោទឬក៏ឲ្យរួចខ្លួនជាស្ថាពរហើយជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោយមានការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយដែលជាគោលការណ៍អាជ្ញាអស់ជំនុំកើតឡើងតែចំពោះសាលក្រមស្ថាពរ និងសាលដីកាស្ថាពរតែប៉ុណ្ណោះ ។[74]នេះមានន័យថាអង្គហេតុដែលតុលាការបានជំនុំជម្រះបានសព្វគ្រប់ហើយអង្គហេតុនេះមិនត្រូវបានលើកយកមកអនុវត្ត ជំនុំជម្រះបានជាថ្មីទៀតទេ ។

#### ១.៥.២.១ ករណីលើកលែង

ក្នុងករណីដែលអាចចោទប្រកាន់បាននោះគឺមានការលើកលែងតែត្រូវមានបទបញ្ញត្តិច្បាប់ចែងទុកក្នុងច្បាប់ចែងទុកដូចជាករណីបណ្តឹងសើរើជាដើម ។ក៏ប៉ុន្តែបណ្តឹងប្រភេទនេះអាចធ្វើបានតែចំពោះសាលក្រម ឬសាលដីកាចូលជាស្ថាពរដែលបានសម្រេចប្រកាសពិរុទ្ធភាព និងផ្តន្ទាទោសតែប៉ុណ្ណោះ ចំពោះសាលក្រម ឬសាលដីកាដែលសម្រេចឲ្យរួចផុតពីបទចោទ មិនអាចធ្វើបណ្តឹងសើរើបានឡើយដោយអនុលោមនិងអនុវត្តនៅគោលការណ៍មួយដែលបានផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ "វិមតិសង្ស័យដែលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។"[75]

#### ១.៥.២.២ សិទ្ធិដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ និងកង្វះតស្លុតាង

បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បង្កើតបាននូវធាតុផ្សំដ៏សំខាន់នៃនីតិរដ្ឋនិងជាការរៀបចំប្រព័ន្ធយុត្តិធម៌ត្រឹមត្រូវ សិទ្ធិនេះបុគ្គលជាច្រើន ដែលគ្របដណ្តប់នូវនីតិវិធីច្បាប់ទាំងស្រុង ។ ចាប់តាំងពីដំណាក់កាលចាប់ខ្លួនជនជាប់ចោទជាលើកដំបូង រហូតដល់ប្តឹងសារទុក្ខចុងក្រោយ ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសិទ្ធិមូលដ្ឋានរបស់បុគ្គលគ្រប់រូបដោយមានការទទួលស្គាល់ជាសកលមានចែងក្នុងឋានានុក្រមខ្ពស់បំផុតនៃច្បាប់អន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

---

[72] រឿងក្តី BABKIN ទល់និងសហព័ន្ធរុស្សីគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ៣ មេសា ឆ្នាំ២០០៨ ត្រង់កថាខណ្ឌទី១៣.៦

[73] កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៩ មាត្រា១៤ កថាខណ្ឌទី៧

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧មាត្រា១២

[75] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចូលជាធរមានថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣៨

ប្រទេសកម្ពុជា ក៏បានផ្តល់សច្ចាប័នលើ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ ។ នៅក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ។

បុគ្គលដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការរៀបរាប់ប្រាប់ពីព្រះរាជអាជ្ញាដែលជាម្ចាស់នៃបណ្តឹងអាជ្ញាដូជខាងក្រោម៖

- ជនគ្រប់រូបមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី ។
- ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសវនាការជាសាធារណៈពីសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ ។
- ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ថាគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ជននោះត្រូវបានរកឃើញដោយសាលាជម្រះក្តី ។[76]

ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកខ្លួនជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមាដោយស្មើភាពគ្នាយ៉ាងពេលលេញដូចខាងក្រោម៖

- ត្រូវបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនដែលជននោះត្រូវតែដឹង ។
- ត្រូវមានពេលវេលា និងសម្ភារះរូបវ័ន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង ។
- ត្រូបានជំនុំជម្រះដោយឥតពន្យាពេលយូរហួសហេតុ
- ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារក្តីដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ ឬការផ្តល់មេធាវីការពារក្តីដោយឥតគិតថ្លៃ ប្រសិនបើជននោះពុំមានលទ្ធភាពជួលមេធាវីដោយខ្លួនឯង ។
- ត្រូវមានការសួរឆ្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរឆ្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងសាក្សីដោះបន្ទុក ។
- ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតថ្លៃបើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ ។
- មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកមកលើខ្លួន ឬសារភាពថាមានពិរុទ្ធ ។[77]

[76]សូមមើលមាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីសម្រេចជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយណាដែលទាក់ទងនិងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។ អាចមើលបានតាមរយៈ http//bit.ly/1hcjqyv .

[77] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចូលជាធរមានថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣១ និងមាត្រា៣៨

## ផ្នែកទី២.មូលហេតុផ្សេងទៀតដែលនាំឲ្យរលត់បណ្តឹងអាជ្ញា

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយការចោទប្រកាន់ ខាងបទល្មើសព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទេទៀតទេ ឬត្រូវតែបញ្ឈប់[78] ។ មានន័យថាប្រសិនបើមានមូលហេតុណាមួយនៃការផុតរលត់នៃបណ្តឹងអាជ្ញាបានកើតឡើង ក្នុងករណីដែលនីតិវិធីបានដំណើការដល់ដំណាក់ការអយ្យការនោះព្រះរាជអាជ្ញាមិនអាចចាប់ផ្តើមធ្វើការចោទប្រកាន់បានទៀតទេ គឺត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការហើយក្នុងករណីនេះព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់រួចហើយក៏ដោយ នីតិវិធីនៅគ្រប់ដំណាក់កាលត្រូវតែបញ្ឈប់ ។

មូលហេតុដែលនាំឲ្យមានការរលត់នៃបណ្តឹងអាជ្ញាមានដូចជា៖ មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ[79] ។ ក្រៅពីមូលហេតុដូចដែលបានពន្យល់ និងរៀបរាប់ខាងលើរួចមក ក៏មានមូលហេតុផ្សេងទៀតដែលនាំឲ្យរលត់បណ្តឹងអាជ្ញាផុតរលត់ផងដែរ កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ ។ មូលហេតុទាំងនោះមានដូចជាៈ ការសម្របសម្រួលជារដ្ឋ ការដកពាក្យបណ្តឹង នៅក្នុងករណីដែលពាក្យបណ្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ និងដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់សម្របសម្រួល[80] ។

### ២.១ ការសម្របសម្រួលជាមួយរដ្ឋ

ជាអាទិ៍ក្នុងករណីដែលច្បាប់បានចែងយ៉ាងច្បាស់ ចម្លើយខាងផ្នែកព្រហ្មទណ្ឌអាចត្រូវបានផ្តល់ដល់អង្គហេតុដោយអ្នកប្រព្រឹត្តមិនចាំបាច់ចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រម ។ ក្រមនីតិវិធីព្រហ្មទណ្ឌចែងអំពីលទ្ធភាពក្នុងការដាក់ពិន័យសម្របសម្រួល ដោយមិនបានកំណត់អំពីបែបបទនៃការដាក់ពិន័យនេះដាក់លាក់នោះឡើយ ។ ប៉ុន្តែយើងអាចចាត់ទុកថាការបង្កើតវិធានបែបនេះ ត្រូវអាស្រ័យទៅលើការទទួលស្គាល់ជាមុនដោយជនសង្ស័យអំពីការប្រព្រឹត្តរបស់ខ្លួន[81]។

ការអនុវត្តព្រមព្រៀងនេះធ្វើឲ្យរលត់បណ្តឹងអាជ្ញាតាមការសម្របសម្រួលនេះជាអាទិ៍៖

- ការទទួលស្គាល់នូវកំហុសរបស់ជនល្មើស
- ការសន្យាឈប់ប្រព្រឹត្តអំពើបែបនេះតទៅទៀត
- ការធានាចូលទៅរួមរស់ក្នុងសង្គមវិញ

[78] មាត្រា៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[79] មាត្រា៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[80] មាត្រា៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៨

- ការសុំពេលដើម្បីជួសជុលការខូចខាតចំពោះជនរងគ្រោះ
- ការទទួលការព្រមានរបស់ព្រះរាជអាជ្ញា
- និងការសម្រុះសម្រួលព្រហ្មទណ្ឌដទៃទៀត ករណីចែងដោយច្បាប់ដោយឡែក ។

ឧទាហរណ៍ៈ បទល្មើសមិនព្រមបង់ពន្ធទំនិញជូនរដ្ឋ ហើយក្រោយមកជនល្មើសបានសម្រប សម្រួលសងនូវពន្ធដែលជំពាក់រដ្ឋទាំងអស់ រួមទាំងការពិន័យផងដែរ ។

## ២.២ ការដកពាក្យបណ្តឹង

ការដកពាក្យបណ្តឹងដោយជនរងគ្រោះអាចធ្វើទៅបានចំពោះ បទល្មើសមួយចំនួនដែលច្បាប់ដោយឡែកបានចែងជាក់លាក់ ហើយពាក្យបណ្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់។ បទបញ្ញត្តិច្បាប់ជាធរមានមួយចំនួន ដែលបានអនុញ្ញាតឲ្យជនរងគ្រោះធ្វើការដកពាក្យបណ្តឹងបាន ។ ឧទាហរណ៍ៈ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះតាមរយៈមាត្រា៣៦ "ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចត្រូវធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជា បទមជ្ឈិមស្រាល ឬបទលហុ...។ តាមន័យនេះបើមានសំណើពីជនរងគ្រោះដើម្បីកុំឲ្យមានការចោទប្រកាន់ នោះព្រះរាជអាជ្ញានិងមិនធ្វើការចោទប្រកាន់ចំពោះបទមជ្ឈិមស្រាល ឬបទលហុនោះបានឡើយ ។ សំណើនេះត្រូវចាត់ទុកជាការដកពាក្យបណ្តឹងបើសិនមានការចោទប្រកាន់រួច ដែលនាំឲ្យបណ្តឹងអាជ្ញាត្រូវផុតរលត់ ។[82]

## ២.៣ ការបង់ប្រាក់ពិន័យសរុបដើម្បីសម្របសម្រួលជាមួយរដ្ឋ

បទល្មើសមួយចំនួនអាចបញ្ចប់បានដោយមិនចាំបាច់ធ្វើបណ្តឹងអាជ្ញា ឬចោទប្រកាន់គឺ គ្រាន់តែបង់ប្រាក់ពិន័យសរុបស ឬប្រាក់ពិន័យសម្របសម្រួលតែប៉ុណ្ណោះ ។ ករណីភាគច្រើនសង្កេតឃើញមានអនុវត្តតែចំពោះបទល្មើសចរាចរណ៍ ។

ឧទាហរណ៍ៈ មាត្រា៦៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៥ "បទល្មើសចរាចរណ៍ដែលត្រូវបានផ្តន្ទាទោសពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ។ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក អាចសម្រុះសម្រួលក្នុងករណីមានគ្រោះថ្នាក់ ដែលបណ្តាលឲ្យអ្នកសងតែសំណងខូចខាត" ។[83]

ដូចនេះ ចំពោះបទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមពិន័យជាប្រាក់ អាចអនុញ្ញាតឲ្យអ្នកប្រព្រឹត្តរួចផុតពីបណ្តឹងអាជ្ញាតាមរយៈការបង់ប្រាក់ពិន័យអន្តរកាលនេះតែម្តង ។[84]

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៨ ត្រង់ចំណុចទី២

[83] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នា២០១៥ ត្រង់មាត្រា៦៥

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៨ ត្រង់ចំណុចទី៣

# ជំពូកទី៣
# នីតិវិធីរំលត់បណ្តឹងអាជ្ញា

អង្គការអយ្យការ ជាអ្នកអនុវត្តដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[85]។ មានន័យថា អង្គការអយ្យការជាម្ចាស់នៃបណ្តឹង ដើម្បីធ្វើការចោទប្រកាន់ពីបទល្មើសណាមួយដែលកើតមានឡើងក្រោយពីពេលដែលខ្លួនបានទទួលពាក្យបណ្តឹង ឬពាក្យប្តឹងបរិហាដោយផ្ទាល់ ឬដោយមន្ត្រីនគរបាលយុត្តិធម៌ ។ តាមរយៈបណ្តឹងដែលទទួលបានព្រះរាជអាជ្ញានិងធ្វើការចោទប្រកាន់ទៅលើអំពើដែលបង្កឲ្យមានព្យសនកម្ម ។

ប៉ុន្តែបើតម្រូវឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់នូវរាល់បទល្មើស ដើម្បីយកជនល្មើសមកផ្តន្ទាទោសនោះប្រាកដណាស់និងកើតមាននូវចំណុចអវិជ្ជមានច្រើនជាងវិជ្ជមានសម្រាប់ប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ។ ដោយហេតុថារាល់ការចោទប្រកាន់ហើយមានការផ្តន្ទាទោសដាក់ពន្ធនាគារនាំឲ្យមានតម្រូវការពន្ធនាគារច្រើនសម្រាប់ទទួលបន្ទុករបស់ទណ្ឌិត ជាកត្តាដែលនាំឲ្យធនធានជាច្រើនត្រូវបានខាតបង់ និងនាំប្រទេសទៅជួបនិងហានិភ័យដែលមិនអាចរំពឹងទុក ។

ដូចនេះការចោទប្រកាន់នឹងកើតមាននូវផលវិបាកពីរ គឺការរក្សាសណ្តាប់ធ្នាប់សាធារណៈឲ្យមានរបៀបរៀបរយល្អនិងការរៀបចំធនធានដល់ឥតប្រយោជន៍។នេះជាហេតុដែលនាំឲ្យព្រះរាជអាជ្ញាមានអំណាចឆន្ទានុសិទ្ធិដោយមិនធ្វើការចោទប្រកាន់ និងតម្កល់រឿងទុកឥតចាត់ការ ។ តើអ្វីទៅជាការតម្កល់រឿងទុកឥតចាត់ការ ហើយមូលហេតុយ៉ាងណាទើបនាំឲ្យមានការតម្កល់រឿងទុកឥតចាត់ការ?

កាលបើមានមូលហេតុដែលនាំឲ្យរលត់បណ្តឹងអាជ្ញាដូចមាននៅក្នុងលក្ខខណ្ឌក្នុងការអនុវត្តនៃការរលត់បណ្តឹងអាជ្ញាខាងលើ នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា អយ្យការត្រូវបំពេញនីតិវិធីមួយចំនួន ដើម្បីឈានដល់ការរលត់ ( បិទបញ្ចប់ ) នីតិវិធីបណ្តឹងអាជ្ញាប្រឆាំងនិងបុគ្គលណាមួយ ។

នៅក្នុងជំពូកនេះ យើងនិងសិក្សាអំពីការអនុវត្តជាក់ស្តែងទាក់ទិន និងការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា និងសំអាងហេតុ និង សំអាងច្បាប់ ។

- **ការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា**

នៅក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត គោលការណ៍នៃភាពអាថ៌កំបាំងត្រូវបានយកមកអនុវត្តមានន័យថា "ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់"[86]។ មានន័យថា រាល់ព័ត៌មានដែលតំណាងអយ្យការទទួលបាន តំណាងអយ្យការត្រូវតែថែរក្សារការសម្ងាត់នៃវិជ្ជាជីវៈជាដាច់ខាត ដោយជៀសវាងឲ្យបានរាល់ការផ្សព្វផ្សាយនូវព័ត៌មាន

[85] មាត្រា ១៣១ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[86] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៨៣ កថាខណ្ឌទី១ ។

ទាំងឡាយទៅដល់សាធារណៈ ។ ប៉ុន្តែការគោរពនូវការរក្សាការសម្ងាត់មិនមែនជាឧបសគ្គសម្រាប់តំណាងអយ្យការក្នុងការពារខ្លួន នៅពេលមានការចោទប្រកាន់ចំពោះខ្លួនឡើយ ។

ការស៊ើបអង្កេត គឺជានីតិវិធីមួយដែលត្រូវបានដឹកនាំដោយតំណាងអយ្យការ ។ ក្នុងដំណាក់កាលស៊ើបអង្កេត ជនល្មើសមានឈ្មោះត្រឹមជាជនសង្ស័យក្នុងការប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ ដូចនេះតំណាងអយ្យការត្រូវស្វែងរកភស្តុតាងដាក់បន្ទុកឲ្យបានគ្រប់គ្រាន់តាមរយៈការស៊ើបអង្កេត ដើម្បីធ្វើការចោទប្រកាន់ទៅលើជនសង្ស័យ ហើយបញ្ជូនសំណុំរឿងទៅតុលាការ ។ ការស៊ើបអង្កេតនេះត្រូវបានបែងចែកជាពីរប្រភេទ គឺ ការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម ។

- **ការស៊ើបអង្កេតក្នុងបទល្មើសជាក់ស្តែង**

ការស៊ើបអង្កេតករណីជាក់ស្តែង មិនត្រូវបានឲ្យនិយមន័យនៅក្នុងច្បាប់កម្ពុជាណាមួយឡើយនាពេលបច្ចុប្បន្ន ។ ការស៊ើបអង្កេតករណីជាក់ស្តែង ត្រូវបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ៨៥ ដល់មាត្រា១១០ ។

ការស៊ើបអង្កេតលើករណីជាក់ស្តែង ត្រូវបានយកមកអនុវត្តដើម្បីប្រមូលភស្តុតាងក្នុងស្ថានភាពបន្ទាន់ចំពោះបទល្មើសដែលទើបប្រព្រឹត្តហើយថ្មីៗ ។ ដូចនេះ ទើបគេបង្កើតឲ្យមានការស៊ើបអង្កេតករណីជាក់ស្តែងដែលជាវិធានដែលមានលក្ខណៈបែបរហ័ស និងផ្តល់អំណាចទូលំទូលាយដល់អាជ្ញាធរ ដើម្បីងាយស្រួលក្នុងការប្រមូលភស្តុតាងទាំងនោះ ។ ការស៊ើបអង្កេតបទល្មើសជាក់ស្តែងក៏អាចត្រូវអនុវត្តដើម្បីធានាការពារបង្ការ និងស្តារឡើងវិញឲ្យបានឆាប់រហ័សនូវការខូចខាតនៃសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ អាយុជីវិតមនុស្ស រូបរាងកាយ ឬទ្រព្យសម្បត្តិដែលបង្កឡើងដោយបទល្មើស ។[87]

ដូចនេះ ពេលវេលាជាកត្តាសំខាន់បំផុតសម្រាប់ការស៊ើបអង្កេតករណីជាក់ស្តែង ព្រោះភស្តុតាងអាចត្រូវបានបាត់ដានតាមភាពចេតនា ឬអចេតនាណាមួយដែលនេះតម្រូវឲ្យកម្លាំងនគរបាលយុត្តិធម៌ត្រូវធ្វើការឲ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន ។ ក្នុងការសិក្សាអំពីការស៊ើបអង្កេតករណីជាក់ស្តែងនេះយើងមិនលម្អិតទេ ព្រោះយើងលម្អិតតែទៅលើករណីដែលរំលត់បណ្តឹងអាជ្ញាតែប៉ុណ្ណោះ ។

- **ការបើការស៊ើបអង្កេតចំពោះករណីបឋម**

ការស៊ើបអង្កេតបឋម គឺជានីតិវិធីស៊ើបអង្កេតធម្មតាមួយ ។ ក្នុងការស្វែងរកភស្តុតាងដាក់បន្ទុកដោយពុំត្រូវបានកំណត់រយៈពេលជាក់លាក់ឡើយ ។ ក្នុងការស៊ើបអង្កេតបឋមនេះ ក៏ពុំត្រូវបានកំណត់និយមន័យនៃ

[87] សៀវភៅ ចក សម្បត្តិ, បទល្មើសជាក់ស្តែងក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ការផ្សព្វផ្សាយរបស់សមាគមន៍សាលាត្រាជូ ខែកញ្ញា ឆ្នាំ២០១៦
<http://salatraji.com/index.php/postop=162> ចូលទស្សនាថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៧

ការស៊ើបអង្កេតករណីជាក់ស្តែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែរ ។

ការស៊ើបអង្កេតបឋម គឺជានីតិវិធីស៊ើបអង្កេតធម្មតាមួយ ។[88]ក្នុងការស្វែងរកភស្តុតាងដាក់បន្ទុកដោយពុំត្រូវបានកំណត់រយៈពេលជាក់លាក់ឡើយ ។ ក្នុងការស៊ើបអង្កេតបឋមនេះ ក៏ពុំត្រូវបានកំណត់និយមន័យនៃការស៊ើបអង្កេតករណីជាក់ស្តែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែរ ។

ការស៊ើបអង្កេតនេះត្រូវបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចែងក្នុងមាត្រា១១១ ដល់មាត្រា១១៨ ។

- **ការបិទបញ្ចប់ការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា**

ការបិទបញ្ចប់ការស៊ើបអង្កេត ( ករណីជាក់ស្តែង និងករណីបឋម ) ព្រះរាជអាជ្ញាត្រូវពិនិត្យ និងពិចារណាថ្លឹងថ្លែងទៅលើលទ្ធផលដែលប្រមូលបានពីការស៊ើបអង្កេតទាំងនៅនគរបាលយុត្តិធម៌ ក៏ដូចជានៅអយ្យការខ្លួនឯងផ្ទាល់ដែរ ។ មានន័យថា ក្រោយពីទទួលបានបាននីតិវិធី ព្រះរាជអាជ្ញាធ្វើការសិក្សាវាយតម្លៃស្ថានការ ស្ថានភាពជាក់លាក់ និងភាពសមហេតុផលរបស់ភស្តុតាងដែលទទួលបាន និងលទ្ធភាពស្របច្បាប់ដែលនីតិវិធីផ្តល់ឲ្យក្រោមរូបភាពជាបណ្តឹង ហើយប្រសិនបើមានមូលហេតុនៃការរលត់បណ្តឹងអាជ្ញាដូចមានចែងនៅក្នុង ជំពូកទី១ ផ្នែកទី១ ខាងលើបើទោះបីជាមានតម្រុយពិរុទ្ធភាព ឬគ្មានក៏ដោយព្រះរាជអាជ្ញាត្រូវមានវិធានការដើម្បីរលត់បណ្តឹងអាជ្ញានេះទៅតាមនីតិវិធីដែលច្បាប់បានកំណត់ ។ លទ្ធភាពនៃការស៊ើបអង្កេតគឺជាកត្តាសំខាន់ដែលកំណត់ពីអត្ថិភាពនៃការរំលត់បណ្តឹងអាជ្ញា ។

ការអនុវត្តជាក់ស្តែងនៅអយ្យការ យើងអាចពិនិត្យទៅលើលទ្ធផលនៃការស៊ើបអង្កេតបាន ដោយពិនិត្យទៅលើរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងកំណត់ហេតុស្តាប់ចម្លើយរបស់ជនសង្ស័យ និងជនទាំងឡាយណាពាក់ព័ន្ធនៅក្នុងសំណុំរឿងព្រមទាំងភស្តុតាងនានាក្នុងសំណុំរឿង[89] ។

- **សំអាងហេតុ**

ព្រះរាជអាជ្ញាត្រូវលើកអំពីសំអាងហេតុ និងសំអាងច្បាប់ ដើម្បីលេចឲ្យបានឃើញនូវស្ថានភាពនិងមូលហេតុគតិយុត្តក្នុងការរលត់បណ្តឹងអាជ្ញា ធ្វើយ៉ាងណាឲ្យគេយល់អំពីចំណាត់ការរបស់ខ្លួន ។

ដើម្បីដំណើរការនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញា ចាំបាច់ព្រះរាជអាជ្ញាត្រូវលើកអំពីទឡ្ហីករណ៍នានាអំពីអង្គហេតុដែលនាំឲ្យខ្លួនសម្រេចរំលត់បណ្តឹងអាជ្ញាបាន ។ សំអាងហេតុត្រូវបានគេចាត់ទុកថាជាផ្នែកដ៏ចាំបាច់មួយនៅក្នុងសេចក្តីសម្រេចរបស់តុលាការ ដូចនេះផ្នែកនេះត្រូវគប្បីសរសេរឲ្យបានច្បាស់លាស់អំពីអង្គហេតុដែលលេចចេញ និងលក្ខខណៈនានាដែលឆ្លើយនិងការសម្រេចរបស់ព្រះរាជអាជ្ញា ។ ការអនុវត្តនៅអយ្យការ

[88]សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ.មេរៀននីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ,ទំព័រទី២៧ ។

[89] អយ្យការអមសាលាដំបូងខេត្តកណ្តាល ដីការតម្កល់រឿងទុកឥតចាត់ការលេខ ០៤១ អយត ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ សំណុំរឿងលេខ៤១២៣ ចុះថ្ងៃទី២០ ខែវិច្ឆកា ឆ្នាំ២០១៤ ។

ដែលបានជួបប្រទះនៅក្នុងសេចក្ដីសម្រេចរបស់តុលាការត្រង់ផ្នែកសំអាងនេះ ព្រះរាជអាជ្ញាត្រូវបានលើកឡើងអំពីកាលៈទេសៈ និងការបរិច្ឆេទនៃការកើតហេតុនៃអំពើល្មើស និងអង្គហេតុដែលនាំឲ្យព្រះរាជអាជ្ញាអាចសម្រេចរំលត់បណ្ដឹងអាជ្ញាបាន ។ ឧទាហរណ៍ៈ សំណុំរឿងព្រហ្មទណ្ឌដែលព្រះរាជអាជ្ញាអាចតម្កល់ទុកឥតចាត់ការបានគឺត្រូវមើលទៅលើ សំអាងហេតុ ទីកន្លែងកើតហេតុ និងពិនិត្យទៅលើជីវិតនៃបុគ្គលល្មើសនោះ ។

➢ **សំអាងច្បាប់**

ទន្ទឹមនិងការលើកឡើងអំពីអង្គហេតុ គឺព្រះរាជអាជ្ញាក៏ត្រូវតែលើកអំពីសំអាងច្បាប់ដែលនូវជាធរមានដើម្បីបង្ហាញដល់ភាគី ក៏ដូចជាសាធារណជនទូទៅឲ្យបានយល់អំពីស្មារតីនៃច្បាប់ និងមាត្រាដែលបានអនុញ្ញាតឲ្យខ្លួនអាចធ្វើសេចក្ដីសម្រេច មិនចោទប្រកាន់ចំពោះការដាក់ឲ្យរំលត់បណ្ដឹងអាជ្ញាបែបនេះបាន ។

ឧទាហរណ៍ថាៈព្រះរាជអាជ្ញាបានលើកយកនូវមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មកអនុវត្តជាក់ស្ដែងត្រង់ចំណុចមរណភាពនៃជនល្មើស ក្នុងការសម្រេចរំលត់បណ្ដឹងអាជ្ញា[90] ។

➢ **ការចេញសេចក្ដីសម្រេច**

ការចេញសេចក្ដីសម្រេច គឺជាបញ្ហាចម្បងដ៏សំខាន់មួយនៅក្នុងដំណើរការនីតិវិធីនៃការរំលត់បណ្ដឹងអាជ្ញាហើយដែលត្រូវបានគេលើកយកមកជជែកពិភាក្សាគ្នាយ៉ាងផុសផុល ត្បិតតែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងឲ្យបានជាក់ច្បាស់អំពីការសម្រេចសេចក្ដី ត្រូវធ្វើឡើងក្រោមទម្រង់បែបណានោះឡើយ ។ បច្ចុប្បន្ននេះយើងសង្កេតឃើញមាននិន្នាការចំនួន០២ ( ពីរ ) ពាក់ព័ន្ធនិងការចេញសេចក្ដីសម្រេចរំលត់បណ្ដឹងអាជ្ញានេះដែលរួមមាន៖ ការតម្កល់រឿងទុកឥតចាត់ការ និងសេចក្ដីសម្រេចរំលត់បណ្ដឹងអាជ្ញា ឬហៅថាដីកាសម្រេចរំលត់បណ្ដឹងអាជ្ញា ។

➢ **ការតម្កល់រឿងទុកឥតចាត់ការ**

ការតម្កល់រឿងទុកឥតចាត់ការគឺ ជាជម្រើសមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា ដែលផ្អែកទៅលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយគត់ ។ ការសម្រេចនេះត្រូវមានសំអាងហេតុ និងសំអាងច្បាប់តែមួយគត់ ។

ការតម្កល់រឿងទុកឥតចាត់ការគឺ ជាសិទ្ធិអំណាចថ្មីមួយដែលក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានប្រគល់មកឲ្យតំណាងអយ្យការ ។ សិទ្ធិអំណាចថ្មីនេះអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចទុកចោទសំណុំរឿងក្ដីព្រហ្មទណ្ឌណាមួយឥតចាត់ការបាន គឺនៅពេលដែលព្រះរាជអាជ្ញាគាត់យល់ថា ជម្រើសធ្វើការចោទប្រកាន់មិនមែនជាមធ្យោបាយដ៏ល្អនោះ ។ ប៉ុន្តែមិនមែនមានន័យថាការសម្រេចមិនធ្វើការចោទប្រកាន់ចំពោះរឿងក្ដីមានន័យស្មើថាជាការបញ្ចប់រឿងក្ដីនោះឡើយ ។ ការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំទេ។ ព្រះរាជអាជ្ញានៅតែអាច

[90] អយ្យការអមសាលាដំបូងខេត្តកណ្ដាល ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៤៥៤ អយត ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ សំណុំរឿងព្រហ្មទណ្ឌ លេខ២២៣៦៨ ចុះថ្ងៃទី១៧ កក្កដា ឆ្នាំ២០១៣

លើកសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនឡើងវិញបានគ្រប់ពេល ប្រសិនបើបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ ។[91]

ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចពិសេសនេះដល់តំណាងអយ្យការក៏ពិតមែន និងក៏ជាអំណាចឯករាជ្យដល់ខ្លួនក្នុងការធ្វើជម្រើសនៃការចោទប្រកាន់ និងតម្កល់រឿងទុកឥតចាត់ការចំពោះរឿងក្តីក៏ពិតមែនក៏ក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិអំពីករណីលើកលែងខ្លះដែលហាមឃាត់តំណាងអយ្យការធ្វើការតម្កល់រឿងទុកឥតចាត់ការផងដែល ។ ឧទាហរណ៍ថា៖ ដូចជាករណីរឿងក្តីនៃបទឧក្រិដ្ឋជាដើម ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីកាតព្វកិច្ចថាតំណាងអយ្យការត្រូវតែបើកការស៊ើបសួរ[92] ។ ម៉្យាងវិញទៀតក្រមនីតិវិធីព្រហ្មទណ្ឌនេះក៏បានកំណត់អំពីលក្ខខណ្ឌទម្រង់ផ្សេងៗទៀតដែលទាមទារឲ្យតំណាងអយ្យការត្រូវតែគោរពដើម្បីអាចធ្វើការតម្កល់រឿងទុកឥតចាត់ការផងដែរ ។

ការតម្កល់រឿងក្តីដែលមិនមែនជារឿងព្រហ្មទណ្ឌទុកឥតចាត់ការ គឺធ្វើឡើងតាមតក្កវិទ្យានីតិសាស្ត្រ ដែលត្រូវបានគេយល់ជាទូទៅថា ក្នុងនាមជាបុគ្គលដែលមានមុខនាទីជាម្ចាស់នៃបណ្តឹងអាជ្ញាផ្តល់ដោយរដ្ឋធម្មនុញ្ញវាជារឿងមិនសមហេតុផលឡើយដែលទៅធ្វើចំណាត់ការលើរឿងក្តីមិនមែនជាបទល្មើសព្រហ្មទណ្ឌ ។ រឿងក្តីដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ យើងអាចសង្ខេបន័យឲ្យខ្លីថា គឺជាអង្គហេតុនៃរឿងក្តីទាំងឡាយណាដែលអង្គហេតុរបស់វាមិនបានបំពេញសព្វគ្រប់នូវធាតុផ្សំនៃបទល្មើស ។ រឿងក្តីប្រភេទទាំងនេះអាចជា រឿងរដ្ឋប្បវេណី រដ្ឋបាល ពាណិជ្ជកម្ម វិវាទការងារ ជាអាទិ៍ ។ តែក្នុងស្ថានភាពជាក់ស្តែង យើងឃើញថាមានប្រភេទនៃរឿងក្តីមួយចំនួនដោយគ្រាន់តែផ្អែកលើទំនាស់នៃផលប្រយោជន៍ ត្រូវគេបានបកស្រាយធ្វើឲ្យអង្គហេតុមានលក្ខណៈប្រហាក់ប្រហែល ឬច្រឡំទៅនិងរឿងក្តីព្រហ្មទណ្ឌដើម្បីធ្វើ បណ្តឹងអាជ្ញា ឬធ្វើឲ្យបណ្តឹងអាជ្ញាមានចលនា ។ ឧទាហរណ៍៖ រឿងក្តីទាក់ទងការបំពានកិច្ចសន្យា ត្រូវបានបកស្រាយឲ្យមានលក្ខណៈភាន់ច្រឡំទៅនឹងបទល្មើសឆបោក ឬរំលោភលើទំនុកចិត្ត ចំណែកឯរឿងក្តីពាក់ព័ន្ធនិងអំពើអនីត្យានុកូលត្រូវបានបកស្រាយឲ្យស្រដៀងទៅនឹងបទល្មើសបង្កឲ្យខូចខាតដោយចេតនាជាអាទិ៍ ។

ដោយឡែកចំពោះ ការតម្កល់រឿងដែលជាបទល្មើសព្រហ្មទណ្ឌទុកឥតចាត់ការវិញ គឺធ្វើឡើងក្រោមហេតុផលចំនួនពីរសំខាន់ គឺទី១ បទល្មើសជារឿងព្រហ្មទណ្ឌដែលមិនគួរចោទប្រកាន់ និងទី២ បទល្មើសជារឿងព្រហ្មទណ្ឌដែលមិនអាចចោទប្រកាន់បាន ។ បទល្មើសមួយមិនគួរចោទប្រកាន់ កាលណាអង្គហេតុនៃបទល្មើសនោះតូចតាច និងមិនជះឥទ្ធិពលដល់តម្លៃការពារសង្គម ចំណែកឯពន្យសកម្មចំពោះជនរងគ្រោះទាំងផ្នែកសីលធម៌ និងសេដ្ឋកិច្ចក៏មានភាពស្តួចស្តើង ហើយពេលខ្លះជនរងគ្រោះគ្មានការអើពើអ្វីសោះ ។ ម្យ៉ាងវិញទៀតមាន

[91] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤១

[92] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៤

ស្ថានភាពមួយចំនួនទោះបីជា ចៅក្រមអយ្យការធ្វើការចោទប្រកាន់ ក៏មិនបានទទួលផលហើយពេលខ្លះអត្ត សញ្ញាណនៃជនបង្កហេតុគឺ គ្មានទាល់តែសោះតែម្តង ( មិនអាចកំណត់សវតាជាតិបាន ) ។ ដូច្នេះការចោទ ប្រកាន់គឺគ្មានប្រយោជន៍អ្វីឡើយ ។ តែទោះបីជាយ៉ាងណាក៏ដោយ មុនពេលសម្រេចតម្កល់រឿងទុកឥតចាត់ការ ចំពោះរឿងក្តីទាំងឡាយដែលមានអង្គហេតុបែបនេះ តាមរយៈការពន្យល់ណែនាំដើម្បីគេបានដឹងខ្លួនពីផលដែល ពិបាកនៃការផ្តន្ទាទោស ហើយចេះកែប្រែខ្លួនឈប់ប្រព្រឹត្តអំពើល្មើសច្បាប់តទៅទៀត ។ ចំពោះ បទល្មើសដែល មិនអាចចោទប្រកាន់គឺ ដោយសារតែមានបញ្ញត្តិច្បាប់ចែងជាក់លាក់ ហាមមិនឲ្យចៅក្រមអយ្យការធ្វើការប្រកាន់ បានតាមរយៈច្បាប់ជាតិ ។[93] និងតាមរយៈនៃច្បាប់ស្តីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរង គ្រោះយោងតាមមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៨ នៃច្បាប់ស្តីឯកពន្ធភាព ជាអាទិ៍ ។ តាមរយៈនេះ គឺអាចកំណត់ជាទ្រឹស្តីបានថា មានបញ្ញាតិនៃច្បាប់ខ្លះ បានបង្កើតជារនាំងដើម្បីរាំងស្ទះសិទ្ធិអំណាច នៃការចោទប្រកាន់របស់ចៅក្រមអយ្យការ។

ការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះពុំមែនជាសេចក្តីសម្រេចរបស់តុលាការទេ ហើយក៏មិនមែន ជាលិខិតរដ្ឋបាលធម្មតាដែរ ដោយសារដីកានេះអនុញ្ញាតឲ្យមានការតវ៉ាពីសំណាក់អ្នកដែលមិនសុខចិត្ត និង សេចក្តីសម្រេចនេះ[94]។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើអធិបញ្ញាឲ្យធ្វើការចោទប្រកាន់ តែមិនអាចបញ្ញាឲ្យធ្វើការតម្កល់រឿងទុកឥតចាត់ការនូវសំណុំរឿងណាមួយបានឡើយ[95]។ ការតម្កល់រឿងទុក ឥតចាត់ការអាច ជាការអនុវត្តគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ឬអាចជាការសម្រេចដោយ ទៅលើមូលហេតុមួយចំនួន។

## ផ្នែកទី១ ការតម្កល់រឿងទុកឥតចាត់ការ

ថ្វីត្បិតតែព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការដោយឆន្ទានុសិទ្ធិ តាមរយៈការថ្លឹងថ្លែង របស់ខ្លួន ប៉ុន្តែការសម្រេចតម្កលត់រឿងទុកឥតចាត់ការនេះត្រូវផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមស្របដែលមាន ដូចជា៖ នត្ថិភាពនៃបទល្មើស មូលហេតុគតិយុត្តិ និងការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ ។

### ១.១នត្ថិភាពនៃបទល្មើស

រាល់អំពើដែលបានបង្កើតជាពន្យសនកម្មមិនប្រាកដថាអំពើទាំងអស់នោះ គឺជាបទល្មើសព្រហ្មទណ្ឌ

[93] រដ្ឋធម្មនុញ្ញចូលជាធរមានថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣ ត្រង់មាត្រា៨០ បញ្ញាតិពី អភ័យឯកសិទ្ធិតំណាងរាស្ត្រ

[94] ប្រសាន៍ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌,អំពីអយ្យការ និងចំណាត់ការសំណុំរឿង,ថ្ងៃទី២១,២៣ ខែមេសា ឆ្នាំ២០០៩ ទំព័រ ទី៤ កថាខណ្ឌទី៨ ។

[95] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា២៨

នោះទេ នៅក្នុងក្រមព្រហ្មទណ្ឌ តាមរយៈគោលការណ៍នីត្យានុកូលភាព មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន មានន័យថា លុះត្រាតែមានអត្ថបទច្បាប់បានចែងថាអំពើនោះជាបទល្មើស ទើបការចោទប្រកាន់អាចប្រព្រឹត្តទៅបាន[96] ។ដូច្នេះ នត្ថិភាពនៃបទល្មើសសំដៅដល់ អវត្តមានបទល្មើស និងធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ ។

## ១.២ អវត្តមាននៃបទល្មើសដែលពិបាកចោទប្រកាន់

នៅខណៈពេលដែលព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងទៅលើបណ្តឹង ដែលខ្លួនទទួលបានដោយផ្ទាល់ ឬដោយកំណត់ហេតុមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមកដល់ដែលពុំគ្រប់ ព្រមទាំងបានបើការស៊ើបអង្កេតបន្ថែមហើយតែ បណ្តឹងនោះ មិនមានវត្តមានបទល្មើសព្រហ្មទណ្ឌទេនោះព្រះរាជអាជ្ញានឹងសម្រេចតម្កល់រឿងទុកឥតចាត់ការ។ អវត្តមានបទល្មើសសំដៅបណ្តឹងដែលធ្វើឡើងប្រឆាំងនឹងអំពើដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ដែលអាចជាបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានប្តឹងមកនោះវាជាសមត្ថកិច្ចតុលាការរដ្ឋប្បវេណីទៅវិញ ឬការបញ្ជូនកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលធ្វើសេចក្តីសន្និដ្ឋានដោយមានការភាន់ច្រឡំ ឬមិនបានពិនិត្យច្បាស់។

ចំណាំ៖ អង្គហេតុដែលព្រះរាជអាជ្ញាទទួលបានមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។

## ១.៣ បទល្មើសមានលក្ខណៈមិនគ្រប់គ្រាន់

នៅក្នុងអង្គហេតុមួយ ដែលព្រះរាជអាជ្ញាមិនអនុញ្ញាតឲ្យកំណត់ពីធាតុផ្សំបទល្មើសដែលគេរាយការណ៍មកអំពីអំពើមួយត្រូវបានចាត់ទុកថាបទល្មើសព្រហ្មទណ្ឌ លុះត្រាតែអំពើនោះមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ។ ករណីដែលមានធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ វាជាកត្តាមួយដែលនាំឲ្យព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បាន នោះការតម្កល់រឿងទុកឥតចាត់ការត្រូវបានយកមកអនុវត្ត ។ជាគោលការណ៍ធាតុផ្សំបទល្មើសជាដាច់ខាតត្រូវតែមានបីគឺ៖ ធាតុផ្សំនីត្យានុកូលភាព ធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័ត ។

សូមបញ្ជាក់ថាក្នុងបទល្មើសដែលច្បាប់ព្រហ្មទណ្ឌបានចែងថាជាបទល្មើស គឺត្រូវតែមានធាតុផ្សំទាំងបីខាងនេះជាដាចខាត មិនអាចខ្វះធាតុផ្សំណាមួយបានទេ ។ បើសិនជាគ្មានធាតុផ្សំណាមួយនោះច្បាប់មិនកំណត់ថាជាបទល្មើសមួយបានទេ ខ្ញុំសូមមិនធ្វើការបញ្ជាក់លម្អិតពីបញ្ហានេះទេ ។[97]

## ១.៤ មូលហេតុគតិយុត្តផ្សេងទៀត

ក្រៅពីការផុតរលត់នៃបណ្តឹងអាជ្ញា ដែលនាំឲ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការក៏នៅមានមូលហេតុគតិយុត្តផ្សេងទៀត ដែលមានប្បញ្ញត្តិក្នុងច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជាផងដែរ ។

[96] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា៣ កថាខណ្ឌទី១

[97] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រង់មាត្រា៣ និង មាត្រា៤

ដែលនាំឲ្យព្រះរាជអាជ្ញាមិនធ្វើការចោទប្រកាន់ ដោយមូលហេតុគតិយុត្តទាំងនោះមានដូចជា៖ អភ័យឯកសិទ្ធិ អនិយ័តភាពនៃកិច្ចនីតិវិធី និងការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើស ។

### ១.៤.១ អភ័យឯកសិទ្ធិ

អភ័យឯកសិទ្ធិគឺ ជាសិទ្ធិរបស់បុគ្គលណាមួយ ដែលច្បាប់បញ្ញត្តិឲ្យអំពីលក្ខខណ្ឌពិសេសទាក់ទងនិង កិច្ចនីតិវិធី ការទទួលខុសត្រូវ ឬការទទួលបាននូវស្ថានសម្រាលចំពោះការប្រព្រឹត្តល្មើសណាមួយ ។តាមរយៈ បទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា គោលការណ៍នៃអភ័យឯកសិទ្ធិនេះត្រូវបានផ្តល់ឲ្យបុគ្គលមួយចំនួន ប៉ុណ្ណោះ ។ បុគ្គលទាំងនោះមានដូចជា ព្រះហាមក្សត្រ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា តំណាងទូត និង អភ័យឯកសិទ្ធិគ្រួសារចំពោះបទល្មើសលួច ។[98]

ដូចនេះ បុគ្គលដែលមានអភ័យឯកសិទ្ធិទាំងនេះ មិនអាចត្រូវបានចោទប្រកាន់បានទេ ដែលតម្រូវឲ្យ ព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

### ១.៤.២ អនិយ័តភាពនៃកិច្ចនីតិវិធី

ក្នុងចំណោមមូលហេតុជាច្រើនអនិយ័តភាពនៃកិច្ចនីតិវិធីជា មូលហេតុមួយដែលព្រះរាជអាជ្ញាលើក យកមកធ្វើសំអាងហេតុមិនធ្វើការចោទប្រកាន់តាមរយៈ ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការផងដែរ ។ មាន ន័យថាអនិយ័តភាពនៃកិច្ចនីតិវិធី គឺសំដៅដល់ភាពមិនស្របច្បាប់នៃនីតិវិធីក្នុងដំណើរការប្រតិបត្តិការរបស់ព្រះ រាជអាជ្ញា ឬនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេត ឬស្រាវជ្រាវបន្ថែមរបស់នគរបាលយុត្តិធម៌ហើយនោះ ប្រតិបត្តិការនេះហាក់ដូចជាមិនស្របច្បាប់នីតិវិធី និងមិនបានចូលជាលទ្ធផល ឬគ្មានប្រយោជន៍ទេ នោះព្រះរាជ អាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការដោយមូលហេតុអនិយ័តនៃនីតិវិធី[99] ។

### ១.៤.៣ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស

ការរួចផុតពីកាទទួលខុសត្រូវរបស់ជនល្មើស សំដៅដល់ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ របស់អ្នកប្រព្រឹត្តបទល្មើសនោះ ។ ដោយមូលហេតុនៃការរួចផុតពីកាទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ ដោយច្បាប់ ដែលត្រូវបានពិចារណាទៅលើកាលៈទេសៈនៃការប្រព្រឹត្ត ឬបុគ្គលិកលក្ខណៈនៃជនល្មើស ដែល អាចតម្រូវឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ។

តាមរយៈក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១០ មូលហេតុនៃការរួចផុតពីការទទួលខុស ត្រូវព្រហ្មទណ្ឌមានដូចជា៖

98 រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចូលជាធរមានថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា ៨០

99 ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ២៦៧

- វិបល្លាសស្មារតី[100]: ការបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ប៉ុន្តែបើការកើតវិបល្លាសស្មារតីនោះ បន្ថយនូវការដឹងខុសត្រូវ ឬកើតឡើងដោយការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ នោះជននោះមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ។
- ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ[101]:អំពើដែលអនុញ្ញាតដោយច្បាប់ ឬបទប្បញ្ញត្តិនានា និងតាមការបញ្ជារបស់អាជ្ញាធរស្របច្បាប់ ទោះមានរូបភាពជាបទល្មើសក៏ដោយ ក៏នាំឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ លើកលែងតែពាក់ព័ន្ធនិងបទល្មើសប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម និងអំពើខុសច្បាប់ជាក់ច្បាស់ណាមួយ ។
- ការការពារស្របច្បាប់[102]: ការប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ប៉ុន្តែលុះត្រាតែការការពារស្របច្បាប់បំពេញលក្ខខណ្ឌ ៣ គឺលក្ខខណ្ឌទី១: ភាពចាំបាច់ដើម្បីការពារខ្លួប អ្នកដទៃ ឬទ្រព្យសម្បត្តិ ដែលប្រឈមមុខនិងការឈ្លានពាន ។ លក្ខខណ្ឌទី២: បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា ។ លក្ខខណ្ឌទី៣: គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារ និងទម្ងន់នៃការឈ្លានពាន ។
- សច្ចធារណ៍នៃការការពារស្របច្បាប់[103]:ត្រូវសន្មត់ថាជាការការពារស្របច្បាប់ ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ និងប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនិងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។
- ស្ថានភាពចាំបាច់[104]:ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌ ២ គឺ លក្ខខណ្ឌទី១: ស្ថានភាពចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនិងគ្រោះថ្នាក់ដែល

[100] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៣១
[101] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៣២
[102] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៣៣
[103] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៣៤
[104] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៣៥

កំពុងកើតមាន ឬដែលនិងកើតមាន ។ លក្ខខណ្ឌទី២: គ្មានវិសមាមាត្ររវាងមធ្យោបាយការពារខ្លួន និងទម្ងន់នៃគ្រោះថ្នាក់ ។

- អានុភាពនៃកម្លាំងឬការបង្ខំ[105]: ការប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលមិនអាចទប់ទល់បាន បុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ហើយមិនអាចមើលឃើញជាមុន និងមិនអាចជៀសវាងបាន ។
- ជនល្មើសជាអនីតិជនអាយុក្រោម ១៤ឆ្នាំ: នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ ១៨ឆ្នាំ ឡើងទៅ[106] ។ តែការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន គឺចាប់ពីអាយុ ១៤ឆ្នាំ ឡើងទៅ[107] ។ ដូចនេះ អនីតិជនអាយុក្រោម ១៤ឆ្នាំមិនទទួលខុសត្រូវព្រហ្មទណ្ឌ ។

ជារួមមក ថ្វីត្បិតតែអំពើប្រព្រឹត្តខាងលើ គឺជាបទល្មើសក៏ពិតមែន ប៉ុន្តែច្បាប់បានបញ្ញត្តថា អំពើទាំងអស់នោះជាអំពើយុត្តិកម្ម ដែលតម្រូវឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដូច្នេះព្រះរាជអាជ្ញាក៏មិនអាចធ្វើការចោទប្រកាន់បានដែរ ដែលត្រូវសម្រេចតម្កល់រឿងទុតតតចាត់ការ ។

### ១.៤.៤ ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

ទោះបីជាអំពើដែលប្រព្រឹត្ត គឺជាបទល្មើសក្តី ប៉ុន្តែព្រះរាជអាជ្ញាអាចធ្វើការពិចារណាថ្លឹងថ្លែងថា គួរតែធ្វើការចោទប្រកាន់ ឬធ្វើការតម្កល់រឿងទុកឥតចាត់ការ ដោយអាស្រ័យទៅលើស្ថានភាព និងកាលៈទេសៈនានា ។ ជាទូទៅកម្មវត្ថុនៃការចោទប្រកាន់ គឺជាការទាមទារឲ្យជនល្មើសមកទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌមិនតែប៉ុណ្ណោះ ក៏ចាំបាច់ផងដែរសម្រាប់ការធានាដល់សិទ្ធិជនរងគ្រោះក្នុងបទល្មើសនោះ ដើម្បីទទួលបាននូវសំណងព្យសនកម្មពីអំពើល្មើសរបស់ជនល្មើសមកលើខ្លួន ។ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាធ្វើការពិចារណាថ្លឹងថ្លែងមើលទៅឃើញថា ការចោទប្រកាន់នោះ ហាក់មិនបានផ្តល់នូវប្រយោជន៍ទាំងអស់ ដូច្នេះការចោទប្រកាន់ក៏ពុំមានន័យអ្វីដែរ ។

ដោយមូលហេតុដែលបណ្តាលឲ្យការចោទប្រកាន់មិនផ្តល់ប្រយោជន៍ អាចបណ្តាលមកពីមូលហេតុផ្សេងៗដូចជា:

- ការស្វែងរកមិនបានផល

[105] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៣៦

[106] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៣៨

[107] ក្រមព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ៣៩ កថាខណ្ឌទី២

- ការបោះបង់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង
- ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ជនល្មើស
- ការខកខានរបស់ដើមបណ្ដឹង
- អាកប្បកិរិយារបស់ជនរងគ្រោះ
- ជនរងគ្រោះមិនចាប់អារម្មណ៍និងបទល្មើស
- ព្យសនកម្ម ឬការខូចខាតតិចតួចបង្កដោយបទល្មើស ជាអាទិ៍ ។

សរុបជារួមមក ការចោទប្រកាន់មិនបានផ្ដល់ប្រយោជន៍ សំដៅដល់ការចោទប្រកាន់ដែលធ្វើឡើងនាំឲ្យខាតពេលវេលា មិនបានផ្ដល់ផលប្រយោជន៍សម្រាប់ជនរងគ្រោះ ឬដើមបណ្ដឹង និងផ្ដល់ប្រយោជន៍សាធារណៈ ហើយហាក់មិនអាចសម្រេចនូវកម្មវត្ថុនៃការចោទប្រកាន់ ដូច្នេះវានិងក្លាយជាកម្មវត្ថុនៃការពិចារណាលើការមិនចោទប្រកាន់ ដែលនាំឲ្យព្រះរាជអាជ្ញាធ្វើការតម្កល់រឿងទុកឥតចាត់ការ ។

## ផ្នែកទី២ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

ចំពោះការសម្រេចរបស់ព្រះរាជអាជ្ញាដោយមិនចោទប្រកាន់ចំពោះអង្គហេតុណាមួយ ដោយមូលហេតុនត្ថិភាពនៃបទល្មើសក្ដី មូលហេតុគតិយុត្តក្ដី ឬដោយសារការចោទប្រកាន់មិនបានប្រយោជន៍ក្ដី ហើយហាក់មិនអាចសម្រេចនូវកម្មវត្ថុត្រូវធ្វើឡើងតាមរយៈដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ដោយការសម្រេចនេះត្រូវធ្វើឡើងតាមនីតិវិធីមួយច្បាស់លាស់ ត្រឹមត្រូវតាមទម្រង់ច្បាប់នឹងតាមទម្រង់នៃដីកាដើម្បីឲ្យដីកាសម្រេចនេះមានអានុភាពក្នុងការអនុវត្ត[108] ។

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្ដឹង និងពាក្យបណ្ដឹងបរិហារដែលខ្លួនបានទទួលនោះដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមកខ្លួន[109]។ ប្រសិន ព្រះរាជអាជ្ញាសម្រេចមិនចោទប្រកាន់ទៅលើពាក្យប្ដឹង ឬពាក្យប្ដឹងបរិហារ ដែលខ្លួនបានទទួលនោះទេ ព្រះរាជអាជ្ញាត្រូវធ្វើការចេញសេចក្ដីសម្រេចមួយតាមរយៈដីកាតម្កលើរឿងទុកឥតចាត់ការ ។

បន្ទាប់ពីព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងដល់អ្នកប្ដឹង អំពីសេចក្ដីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ ខែគិតចាប់ពីថ្ងៃចុះពាក្យប្ដឹងនៅក្នុងបញ្ជី[110]។ មានន័យថា នៅពេលដែលព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងទៅអ្នកប្ដឹង ព្រោះអ្នកប្ដឹងត្រង់ចំណុចនេះគឺ សំដៅដល់ជនរងគ្រោះ អ្នកតំណាងស្របច្បាប់

[108] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ត្រង់មាត្រា៤០

[109]ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ត្រង់មាត្រា៤១ កថាខណ្ឌទី១

[110] ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ត្រង់មាត្រា៤១ កថាខណ្ឌទី១

និងសិទ្ធិវ័ន្តនៃជនរងគ្រោះហើយ ការជូនដំណឹងនេះត្រូវធ្វើឡើងតាមរយៈ លិខិតជូនដំណឹង ។ ការជូនដំណឹងនេះត្រូវធ្វើឡើងដើម្បីឲ្យគេបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ដែលបានសម្រេចទៅលើការដាក់ពាក្យបណ្តឹងរបស់ខ្លួន ហើយក៏ដើម្បីជានានូវសិទ្ធិរបស់អ្នកប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចនេះផងដែរ ។

ចំពោះរយៈពេលនៃការឲ្យដំណឹង ត្រូវធ្វើឡើងយ៉ាងខ្លីបំផុត ហើយយ៉ាងយូរត្រូវមិនផុតរយៈ ២ខែ ឡើយ ដោយគិតចាប់ពីថ្ងៃចុះពាក្យប្តឹងនៅក្នុងបញ្ជី ។

## ២..១ ទម្រង់ការនៃដីកាតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវធ្វើឡើងតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ ។ ទម្រង់ការនៃដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ សំដៅដល់ធាតុទាំងឡាយណាដែលមានក្នុងដីកាតម្កល់រឿងទុកឥតចាត់ការដែលតម្រូវឲ្យមានដើម្បីឲ្យដីកានេះមានភាពត្រឹមត្រូវ ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ពុំមានប្បញ្ញត្តិពីទម្រង់ការនៃដីកាតម្កល់រឿងទុកឥតចាត់ការបានច្បាស់លាស់នោះទេប៉ុន្តែគ្រាន់តែបានប្បញ្ញត្តិថាការតម្កល់រឿងទុកឥតចាត់ការត្រូវតែមានសំអាងហេតុនិងសំអាងច្បាប់[111]។មានន័យនេះដីកាតម្កលត់រឿងទុកឥតចាត់ការដាច់ខាតត្រូវតែមានសំអាងហេតុនិងសំអាងច្បាប់ដែលជាលក្ខខណ្ឌចាំបាច់ដោយពុំអាចខ្វះបាន ។

សំអាងហេតុ សំដៅដល់ការលើកយកនូវអង្គហេតុទាំងឡាយដែលពាក់ព័ន្ធមកធ្វើជាសំអាងដែលជាមូលហេតុដែលនាំឲ្យមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ឯសំអាងច្បាប់ គឺជាការលើកយកនូវអត្ថបទច្បាប់ដែលគ្រាំដល់អង្គហេតុ និងមូលហេតុដែលធ្វើឲ្យមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

## ២.២ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ខ្ញុំសូមមិនលើកអំពីអានុភាពនៃការរំលត់បណ្តឹងអាជ្ញា ដែលពាក់ព័ន្ធនឹងបណ្តឹងរដ្ឋប្បវេណីទេដោយសារតែនៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណីមិនទាន់ត្រូវបានគេទទួលស្គាល់នូវសិទ្ធិរបស់គាត់នៅឡើយ និងម្យ៉ាងយើងបានលើកឡើងខ្លះអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងជំពូកទី១ ផ្នែកទី២ រួចហើយ ។ ដោយជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា ឬ ចៅក្រមជំនុំជម្រះ[112] ។

ការតម្កល់រឿងទុកឥតចាត់ គឺពុំមានអានុភាពអាជ្ញាអស់ជំនុំនោះឡើយ ដូច្នេះនាំឲ្យព្រះរាជអាជ្ញាអាចសម្រេចបើកការស៊ើបអង្កេតឡើងវិញ ប្រសិនបើខ្លួនយល់ថាមានការផ្លាស់ប្តូរស្ថានភាពដែលនាំឲ្យការតម្កល់រឿងទុកឥតចាត់ការនោះ ហើយកាលបើបណ្តឹងអាជ្ញានៅមិនទាន់ផុតរលត់នៅឡើយ ។ ម្យ៉ាងវិញទៀតដីកាតម្កល់

[111]ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ត្រង់មាត្រា៤១ កថាខណ្ឌទី២

[112]ក្រមនីតិវិធីព្រហ្មទណ្ឌ ចូលជាធរមានថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ត្រង់មាត្រា១៣៧ កថាខណ្ឌទី៣ និងមាត្រា៣១១ កថាខណ្ឌទី១ ។

រឿងទុកឥតចាត់ការ បើកសិទ្ធិដល់ភាគីប្ដឹងឧបាស្រ័យបាន តាមរយៈការតវ៉ាទៅអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។

ដោយឡែកដីកាសម្រេចរំលត់បណ្ដឹងអាជ្ញាយើងអាចនិយាយបានថា មានអាជ្ញាអស់ជំនុំ បើទោះបីជាអាជ្ញាអស់ជំនុំនៅក្នុងមាត្រា១២ សំដៅដល់តែសេចក្ដីសម្រេចដែលតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរមានន័យថាតុលាការបានចេញនៅ សាលក្រម ឬសាលដីកាស្ថាពរក៏ដោយ បើយើងពិនិត្យមើលទៅលើសេចក្ដីសម្រេចបញ្ចប់នីតិវិធីនេះឃើញថា តុលាការមិនអាចធ្វើការផ្ដើមចោទប្រកាន់ឡើងវិញបានទេ ឬ ត្រូវបញ្ឈប់ការចោទប្រកាន់ ប្រសិនបើមានមូលហេតុនៃការរលត់បណ្ដឹងអាជ្ញាដូចចែងក្នុងមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលវាមានលក្ខណៈផ្ទុយពីដីកាតម្កល់រឿងទុកឥតចាត់ការ ដែលព្រះរាជអាជ្ញាអាចផ្ដើមធ្វើការចោទប្រកាន់ឡើងវិញនៅពេលរកឃើញមានពិរុទ្ធភាពថ្មី ។

ដីកាសម្រេចរំលត់បណ្ដឹងអាជ្ញានេះ ក៏មានអានុភាពប្ដឹងបញ្ជូនសំណុំរឿង និងវត្ថុតាង ព្រមទាំងភស្តុតាងនានាទៅយុត្តាធិការជំនុំជម្រះដើម្បីសម្រេចអំពីសំណងរដ្ឋប្បវេណី[113] ផ្ទុយពីដីកាតម្កល់រឿងទុកឥតចាត់ការដែលពុំមានអានុភាពប្ដឹងបញ្ជូនសំណុំរឿង និងវត្ថុតាង ព្រមទាំងភស្តុតាងនានាទៅយុត្តាធិការជំនុំជម្រះឡើយ ។

**កំណត់ចំណាំ** ៖ អានុភាពចម្បងចំនួន ២ ( ពីរ ) នៃការរលត់បណ្ដឹងអាជ្ញាទាំងសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការក្ដី ទាំងដីកាសម្រេចរំលត់បណ្ដឹងអាជ្ញាគឺ៖

- អានុភាពតាមផ្លូវច្បាប់ៈ គឺជាការមិនអាចផ្ដើមចោទប្រកាន់ខាងព្រហ្មទណ្ឌលើជនដែលបានប្រព្រឹត្តអំពើជាបទល្មើស ឬ ត្រូវបញ្ឈប់ការចោប្រកាន់ ករណីមានការចោទប្រកាន់រួចហើយនោះ ។
- អានុភាពតាមផ្លូវរដ្ឋបាលៈ បិទបញ្ចប់សំណុំរឿង ឬ ការចំណាយរឿងចេញពីបញ្ជីសំណុំរឿងដែលនិងកំពុងចាត់ការនៃនីតិវិធី ។

## ២.៣ បច្ច័យនៃការតម្កល់រឿងទុកឥតចាត់ការ

ការអនុវត្តតម្កល់រឿងទុកឥតចាត់ការរឿង អាចបង្កើតជាភាពវិជ្ជមានជាច្រើនសម្រាប់សង្គមជាតិដូចជាការកាត់បន្ថយនូវការកកស្ទះសំណុំរឿងក្ដីនៅតុលាការ ការកាត់បន្ថយភាពណែនស្ទះនៅក្នុងពន្ធនាគារ និងជាពិសេស វាគឺជាការជួយជម្រុញការបំពេញការងាររបស់តំណាងអយ្យការឲ្យក្លាយជានិយ័តករដ៏រស់រវើកក្នុងសង្គមដែលមិនមែនជាតួម៉ាស៊ីនសម្រាប់ការចោទប្រកាន់ដូចមុនឡើយ ។ ការអនុវត្តនេះក៏ជានយោបាយព្រហ្មទណ្ឌទាក់ទង និងការលុបបំបាត់ការបង្ក្រាបតាមបែបសងសឹកជាបណ្ដើរៗ ដោយជំនួសនយោបាយព្រហ្មទណ្ឌ និងបង្ក្រាបតាមបែបអប់រំ[114] ។

---

[113] លោក តាន់ សេងណារ៉ុង ព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ-ពីដីកាសម្រេចរំលត់បណ្ដឹងអាជ្ញា ។

[114] សូមមើលការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ,ចូលមើលខែកក្កដា ឆ្នាំ២០១៧ http://salatraju.com/index/php/post?p=33,

ក្រៅពីភាពវិជ្ជមានក្នុងចំណោមខាងលើនេះ ការអនុវត្តនេះបានផ្តល់ផលអវិជ្ជមានមួយចំនួនទៀតដែលអាចកើតឡើងពីការអនុវត្តគោលការណ៍កាលាអនុវត្តភាពនៃការចោទប្រកាន់នេះ ដូចជា៖

*ចៅក្រមអយ្យការមានអំណាចធំធេង ហើយគាត់អាចប្រើប្រាស់អំណាចនេះដើម្បីការពារផលប្រយោជន៍ និងបក្សពួករបស់ខ្លួន ប្រសិនបើគាត់គ្មានមនសិការជាតិនិងវិជ្ជាជីវៈ*[115]។

ដោយឡែកតាមរយៈការអនុវត្តនីតិវិធីរលត់បណ្តឹងអាជ្ញា ដូចបានរៀបរាប់ខាងលើ យើងឃើញថាវាបានផ្តល់ជាវិបាកមួយចំនួនផងដែរ ។ វិបាកទាំងនោះរួមមានជាអាទិ៍ៈ

- ការយកមូលហេតុនៃការរលត់បណ្តឹងអាជ្ញា ជាមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការនាំឲ្យមានការភាន់ច្រឡំអំពីអានុភាពនៃអាជ្ញាអស់ជំនុំនៃដីកាតម្កល់រឿងទុកឥតចាត់ការ ។
- ការអនុវត្តមិនស្របគ្នារវាងយុត្តាធិការជាតិ និងសាលាក្តីខ្មែរក្រហម ពាក់ព័ន្ធនិងការរលត់បណ្តឹងអាជ្ញា និងនាំឲ្យមានការបកស្រាយផ្សេងៗគ្នាពីអ្នកអនុវត្តច្បាប់ ដែលមាននិន្នាការទៅរកយុត្តាធិការជាតិ និងអ្នកមាននិន្នាការទៅរកយុត្តាធិការ អ.វ.ត.ក ។
- វិសោធនកម្មនៃមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលកំណត់ថា ការរលត់បណ្តឹងអាជ្ញា គឺជាមូលហេតុនៃការការលើកលែងចោទការប្រកាន់ រឹតតែនាំឲ្យមានការភាន់ច្រឡំកាន់តែខ្លាំងលើអានុភាពនៃការរលត់បណ្តឹងអាជ្ញាចំពោះ ដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនិងជនជាប់ចោទថាតើការរលត់បណ្តឹងអាជ្ញានាំឲ្យបញ្ចប់នីតិវិធីប្រឆាំងនិងជននោះដែរឬទេ ។

## ២.៤.យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ

ដោយហេតុដូចការបកស្រាយខាងលើការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំទេមានន័យថាការចោទប្រកាន់អាចត្រូវបានធ្វើឡើងសារជាថ្មី។ចំពោះយន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការដើម្បីធ្វើការចោទប្រកាន់ជាថ្មីមានដូចជា៖

- ការសើរើកែប្រែសេចក្តីសម្រេចរបស់តំណាងអយ្យការ ទោះបីពាក្យប្តឹងត្រូវបានតម្កល់រឿងទុកឥតចាត់ការដោយតំណាងអយ្យការក៏ដោយ បើក្រោយមកខ្លួនយល់ថាអំពើល្មើសមានធាតុផ្សំគ្រប់គ្រាន់ ឬមានភស្តុតាងថ្មីដែលអាចបញ្ជាក់ពីរឿងហេតុ នោះតំណាងអយ្យការអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញបានលើកលែងអាជ្ញានោះមិនទាន់រលត់នៅឡើយ[116] ។
- ការធ្វើបណ្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ ៖ កាលណាពាក្យប្តឹងត្រូវបានតម្កល់រឿងទុកឥតចាត់ការ

[115] ការតម្កល់រឿងទុកឥតចាត់ការ របស់សាលាត្រាជូ, ចូលមើល ខែកក្កដា ឆ្នាំ២០១៧htt://salatraju.com/index/php/post?p=33, ទំព័រទី៤ ។

[116] មាត្រា ៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ហើយអ្នកប្ដឹងមិនសុខចិត្តនិងសេចក្ដីសម្រេចនោះទេ សាមីខ្លួនអាចធ្វើបានការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងអំឡុងពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ បើការតវ៉ាមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នឹងចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឲ្យធ្វើការចោទប្រកាន់[117] ។

- ការធ្វើអធិបញ្ញាតាមនាយឋានានុក្រមនៃអង្គការអយ្យការ ដោយអង្គការអយ្យការជាអង្គឯកភាពដែលត្រូវស្ថិតនូវក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមនាយឋានានុក្រមរបស់ខ្លួន ដែលមានរដ្ឋមន្ត្រីជាក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមសាលាតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[118]។

- ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្ដឹងដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ដែលមានអានុភាពប្ដឹងដល់នៅចៅក្រមស៊ើបសួរ អំពីបណ្ដឹងក្នុងលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា ១៣៩ ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា និងមាត្រា ១៤០ ការបង់ប្រាក់តម្កល់ទុក ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បន្ទាប់មកចៅក្រមស៊ើបសួរនិងធ្វើការបញ្ជូនបណ្ដឹងនេះទៅព្រះរាជអាជ្ញាឲ្យធ្វើការចោទប្រកាន់តាមបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ[119] ។

117 មាត្រា ៤១ កថាខណ្ឌទី៤ .៥.៦ នៃក្រមនីតិព្រហ្មទណ្ឌ ឆ្នាំ២០០៧

118 មាត្រា៧៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

119 មាត្រា៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

តាមរយៈកាសិក្សា និងលទ្ធផលនៃការស្រាវជ្រាវលើទ្រឹស្តីគតិយុត្ត អំពីប្រធាបបទ " មូលហេតុនិងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញា" នេះរួចមកបានបង្ហាញឲ្យយើងមើលឃើញថាការជ្រើសរើសជម្រើសណាមួយចំពោះ ចំណាត់ការរឿងក្តីព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញាគឺ មិនមែនជារឿងដ៏ងាយស្រួលនោះទេ ។ ការប្តឹងចោទប្រកាន់ ឬការតម្កល់រឿងទុកឥតចាត់ការ និងដីកាសម្រេចរំលត់បណ្តឹងអាជ្ញា គឺជាវិធានមួយដ៏ស្មុគស្មាញដែលតំណាងអយ្យការត្រូវដឹងនិងថ្លឹងថ្លែងឲ្យបានម៉ត់ចត់បំផុតនៅមុនពេលធ្វើសេចក្តីសម្រេចណាមួយ ។ ការសម្រេចចិត្តប្តឹងសុំចោទប្រកាន់របស់តំណាងអយ្យការ មានអានុភាពដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យអំពីបទល្មើសចំពោះបុគ្គលណាម្នាក់ ឬច្រើននាក់ ។

ដើម្បីកាត់បន្ថយវិបត្តិដែលកើតពីការសម្រេចចិត្តទាំងនេះនីតិករបាន បង្កើតនូវលក្ខខណ្ឌជាច្រើនដែលតម្រូវឲ្យតំណាងអយ្យការត្រូវតែគោរពជាចាំបាច់ ចំពោះចំណាត់ការលើរឿងក្តីរបស់ខ្លួនដូចយើងបានមើលឃើញនៅក្នុងមាត្រា៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា " មុននិងសម្រេច ( តម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ) តំណាងអយ្យការត្រូវបើកការស៊ើបអង្កេតបឋមឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែមសិន"។មិនតែប៉ុណ្ណោះក្រមនីតិវិធីព្រហ្មទណ្ឌនេះក៏បានបង្កើតនូវលក្ខខណ្ឌទម្រង់ និងចែងជាមូលហេតុចាំបាច់មួយចំនួនទៀតជូនតំណាងអយ្យការ ដើម្បីជាជំនួយក្នុងសម្រេចចិត្តធ្វើការតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ផងដែរ ។

ដូច្នេះយើងអាចសន្និដ្ឋានចំពោះនីតិវិធីនៃការចោទប្រកាន់ ទោះបីជាការចោទប្រកាន់អាចត្រូវបានធ្វើឡើងតាមនីតិវិធីផ្សេងៗគ្នាក៏ដោយ ប៉ុន្តែវាមានចំណុចរួមមួយគឺ ដើម្បីឲ្យភាគីនៃរឿងក្តីទទួលបានផលប្រយោជន៍និងភាពយុត្តិធម៌ពិតប្រាកដ ។

ក្រៅពីការចោទប្រកាន់ចំពោះបទល្មើស ព្រះរាជអាជ្ញាក៏អាចម្រេចធ្វើការមិនចោទប្រកាន់បានដែរ ទោះបីជាអំពើដែលបានប្រព្រឹត្តនោះជាបទល្មើសក៏ដោយ ព្រោះការចោទប្រកាន់ចំពោះអំពើខ្លះ អាចធ្វើឲ្យមានផលប៉ះពាល់ និងខាតបង់ទៅវិញ ដូចនេះព្រះរាជអាជ្ញាអាចធ្វើការពិចារណាទៅលើមូលហេតុដូចបានបកស្រាយរួចមក ។ មូលហេតុដែលព្រះរាជអាជ្ញាអាចសម្រេចមិនចោទប្រកាន់ គឺបណ្តាលមកពីហេតុផលមួយចំនួនទាក់ទងនិងផលប្រយោជន៍របស់តុលាការ ភាគី និងរដ្ឋ ។ ចំពោះផលប្រយោជន៍សម្រាប់តុលាការ គឺអាចកាត់បន្ថយសំណុំរឿងដែលកកស្ទះ ផ្តល់ប្រសិទ្ធិភាពក្នុងការស៊ើបសួរ និងជំនុំជម្រះ ព្រោះនៅពេលដែលសំណុំរឿងត្រូវបានកាត់បន្ថយចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះមានលទ្ធភាព និងពេលវេលាគ្រប់គ្រាន់ក្នុងការបំពេញកិច្ចរបស់ខ្លួន។

ចំណែកផលប្រយោជន៍របស់ភាគី គឺភាគីដែលជាជនល្មើសអាចមានលទ្ធភាពគ្រប់គ្រាន់ដើម្បីកែខ្លួននិងរួមរស់ជាមួយសង្គមវិញ ជាពិសេសអនីតិជន និងជនដែលកំពុងជាប់កាតព្វកិច្ច ដូចជាចិញ្ចឹមបីបាច់គ្រួសារ

ជាអាទិ៍ ។ ឯផលប្រយោជន៍ចំពោះរដ្ឋ គឺកាត់បន្ថយការចំណាយទាំងពេលវេលា និង ថវិការ ដោយអាចកាត់បន្ថយការចំណាយលើទណ្ឌិត និងកាត់បន្ថយចំនួនទណ្ឌិត ។ ប៉ុន្តែស្របពេលដែលនិងការផ្តល់ប្រយោជន៍ នីតិវិធីនេះ ក៏បានផ្តល់គុណវិបត្តិផងដែរ ។ ដោយគុណវិបត្តិនេះ ត្រូវបានផ្តល់តាមរយៈការបង្កើតវប្បធម៌និទណ្ឌភាព ។ ព្រះរាជអាជ្ញាអាចមានសិទ្ធិអំណាចក្នុងការមិនធ្វើការចោទប្រកាន់ ដូចនេះជនល្មើសអាចនិងត្រូវបានរួចខ្លួនពីការប្រព្រឹត្តអំពើល្មើសរបស់ខ្លួន មិនតែប៉ុណ្ណោះវាអាចបង្កើតឲ្យមានអំពើពុករលួយថែមទៀតផង ។

ដូច្នេះយើងអាចសន្និដ្ឋានចំពោះនីតិវិធីមិនធ្វើការចោទប្រកាន់បានថា គឺជានីតិវិធីមួយដែលផ្តល់ទាំងគុណសម្បត្តិ និងគុណវិបត្តិ ប្រសិនបើនីតិវិធីនេះត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវវាពិតជាធ្វើឲ្យមានការប៉ះពាល់សិទ្ធិរបស់ភាគីជនរងគ្រោះយ៉ាងធ្ងន់ធ្ងរ ។

សរុបមកក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញា ជាអ្នកបម្រើឲ្យផលប្រយោជន៍ទូទៅការពារផលប្រយោជន៍សង្គម តំណាងអយ្យការត្រូវបំពេញការងារដោយតាំងចិត្តក្នុងការដោះស្រាយខ្ចស់រាល់ចំណុចអសកម្មទាំងឡាយ ទោះបីជាមានទាំងបញ្ហាផ្នែកបច្ចេកទេសក្តី បញ្ហាថវិកាក្តី ឬការកើតចេញពីបញ្ហារបស់បុគ្គលដែលអនុវត្តច្បាប់ក្តី គឺត្រូវមានឆន្ទៈស្វែងរកយុត្តិធម៌ជូនសង្គមជាតិ និងមាតុភូមិរបស់ខ្លួន ។

# អនុសាសន៍

ឆ្លងតាមរយៈនៃការសិក្សាលើផ្នែកទ្រឹស្តីគតិយុត្តដែលមានការលំបាក និងជួបប្រទះនូវបញ្ហាមួយចំនួនកន្លងមកក៏ដោយខ្ញុំនៅតែជឿជាក់ថា ប្រសិនបើអ្នកអនុវត្តច្បាប់ទាំងអស់ចូលរួមសាមគ្គីគ្នា ក្នុងឆន្ទៈបម្រើវិស័យយុត្តិធម៌ និងប្រជុំពិភាក្សាគ្នាក្នុងឆន្ទៈដោះស្រាយបញ្ហានោះ ពិតជាអាចដោះស្រាយនិងឧបសគ្គទាំងឡាយបានជាក់មិនខាន ហើយនៅពេលនោះភាពអយុត្តិធម៌និងត្រូវបានកាត់បន្ថយហើយស្តែងឡើងជាសត្យានុម័ត ។

នៅក្នុងប្រធានបទ "មូលហេតុ និងនីតិវិធីនៃការរំលត់បណ្តឹងអាជ្ញា" ព្រះរាជអាជ្ញា គឺជាតួអង្គមួយដ៏សំខាន់ក្នុងនីតិវិធីនេះ ។ នីតិវិធីនេះអាចប្រព្រឹត្តបានល្អ ត្រឹមត្រូវ ដើម្បីធានាបាននូវនីតិរដ្ឋ លុះត្រាតែព្រះរាជអាជ្ញាបំពេញតួនាទីរបស់ខ្លួនដោយឈរលើចំណុចសំខាន់ៗដូចជា៖

**១.ទាក់ទងនិងការរំលត់បណ្តឹងអាជ្ញា៖** មានន័យថានីតិវិធីដែលមានចែងក្នុងមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺព្រះរាជអាជ្ញាត្រូវពិនិត្យ និងសម្រេចរំលត់បណ្តឹងអាជ្ញាទៅតាមមូលហេតុដែលមានចែងក្នុងមាត្រា ៧ នេះតែម្តង ។

**២.ទាក់ទងនិងការតម្កល់រឿងទុកឥតចាត់ការ៖** គឺជាការមិនចោទប្រកាន់ដែលជានីតិវិធីដែលបើកសិទ្ធិអំណាចដ៏ទូលាយដល់ព្រះរាជអាជ្ញា ដែលផ្តល់ឱកាសដល់ជនល្មើសបានរួចខ្លួន និងមានសេរីភាពផងដែរ ដូច្នេះហើយព្រះរាជអាជ្ញាត្រូវប្រកាន់ខ្ជាប់នូវការអនុវត្តច្បាប់ ក្រមសីលធម៌ វិជ្ជាជីវៈរបស់ខ្លួនឲ្យបានត្រឹមត្រូវមុន និងសម្រេចតម្កល់រឿងទុកឥតចាត់ការ ដើម្បីឲ្យជនរងគ្រោះ និងសង្គមទទួលបាននូវយុត្តិធម៌យ៉ាងពិតប្រាកដ ។ មិនតែប៉ុណ្ណោះ ការសម្រេចតម្កល់រឿងទុកឥតចាត់ ត្រូវធ្វើឡើងដោយឈរលើគោលការណ៍ផលប្រយោជន៍ពិតប្រាកដរបស់ភាគី និងសង្គមជៀសវាងការគិតដល់ផលប្រយោជន៍របស់ខ្លួនជាការដោះដូរនិងលាភសក្ការៈ ។

# ឯកសារយោង

# ឯកសារយោង

## ១).លិខិតបទដ្ឋានគតិយុត្ត

### ក).រដ្ឋធម្មនុញ្ញ

១). រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ។

### ខ).សន្ធិសញ្ញាអន្តរជាតិ

១). សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ ។

២). កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ។

៣). អនុសញ្ញាក្រុងវីយ៉ែនស្តីពីទំនាក់ទំនងការទូត អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៦១ ស្តីពីការប្រាស័យទាក់ទងការទូត និងអភ័យឯកសិទ្ធិការទូត ។

### គ).ក្រម

១). ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើ ក្រមនីតិវិធីព្រហ្មទណ្ឌ ។

២). ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៩ ប្រកាសឲ្យប្រើ ក្រមព្រហ្មទណ្ឌ ។

៣). ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី ។

### ឃ). ច្បាប់

១). ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ ។

២). ព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

៣). ព្រះរាជក្រមលេខ នស/រកម/១០០៥/០៣១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

## ២). ឯកសារជាសៀវភៅ និងអត្ថបទ

### ក). សៀវភៅមេរៀន

១). សៀវភៅសាស្ត្រាចារ្យ **មីន សំអុល** ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៧ - ២០១៨ ។

២). លោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** មេរៀននីតិព្រហ្មទណ្ឌទូទៅ សម្រាប់ឆ្នាំសិក្សាទី២ ។

៣). **សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ និងរាជបណ្ឌិតវិជ្ជាជីវៈតុលាការ** មេរៀននីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ។

៤). គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ លោក **តុប ឈុនហេង** មេរៀនស្តីពីការអនុវត្តបណ្តឹងអាជ្ញាដោយស្ថាប័នអយ្យការ ។

៥).លោកសាស្ត្រាចារ្យ **រុន ពណ្ណរិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** មេរៀននីតិវិធីព្រហ្មទណ្ឌ ឆ្នាំសិក្សា ២០១៣-២០១៤ ។

៦). នាយកក្រឡាបញ្ជីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក **ជួន សុរាសី** នីតិវិធីព្រហ្មទណ្ឌព្រហ្មទណ្ឌ និងនីតិវិធីរដ្ឋប្បវេណី បោះពុម្ពលើកទី១ ខែមករា ឆ្នាំ២០០៩ ។

៧). មេធាវី **កុយ នាម** សៀវភៅស្តីពី**អយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប** ឆ្នាំ២០០៦ ទំព័រទី៧៤ ។

### ខ).ឯកសារជាអត្ថបទ

១).សូមមើលការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ចូលមើលខែកក្កដាឆ្នាំ២០១៧ http://salatraju.com/index/php/post?p=33, ។

២). **ការតម្កល់រឿងទុកឥតចាត់ការ** របស់សាលាត្រាជូ, ចូលមើល ខែកក្កដា ឆ្នាំ២០១៧ http://salatraju.com/index/php/post?p=33, ទំព័រទី៤ ។

៣). អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា **ស្តីពីសេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនិងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី** ។

៤). លោក **តាន់ សេងណារ៉ុង** ព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ-ពីដីកាសម្រេចរំលត់បណ្តឹងអាជ្ញា ។

៥). អយ្យការអមសាលាដំបូងខេត្តកណ្តាល **ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៤៥៤** អយត ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ ។

៦). រឿងក្តី **BABKIN ទល់និងសហព័ន្ធរុស្សីគណៈកម្មាធិការសិទ្ធិមនុស្ស** អ.ស.ប ៣ មេសា ឆ្នាំ២០០៨ ត្រង់កថាខណ្ឌទី១៣.៦ ។

៧). សាលាគំនិតត្រាជូ **ចក សម្បត្តិ**, នីតិវិធីព្រហ្មទណ្ឌ ការបោះពុម្ពលើកទី១ ឆ្នាំ២០១៥ ទំព័រ ៧៣ ។

៨). ប្រព័ន្ធច្បាប់ស៊ីវិល ( Civil Law System ) ជាប្រព័ន្ធច្បាប់សម្រាប់សរសេរ ដែលអនុវត្តដូចជានៅប្រទេសកម្ពុជា និងបារាំងជាដើម ។

៩). ប្រព័ន្ធច្បាប់ខមម៉ន់ឡ ( Common Law System ) ជាប្រព័ន្ធច្បាប់ឥតសរសេរ ដែលអនុវត្តដូចជានៅសហរដ្ឋអាមេរិកជាដើម ។

១០). ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, អំពីអយ្យការ និងចំណាត់ការសុំណុំរឿង ថ្ងៃទី២១-២៣ ខែមេសា ឆ្នាំ២០០៩ ទំព័រ៤ កថាខណ្ឌទី៧ ។

១១). អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សេចក្តីសម្រេចលើការបញ្ចប់កិច្ច**នីតិវិធីប្រឆាំងនិងជនជាប់ចោទ អៀង សារី** សំណុំរឿងលេខ ០០២/១៩កញ្ញា ឆ្នាំ២០០៧ /អ.វ.ត.ក /អ.ជ.ស.ដ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ។

## ៣). វចនានុក្រម និងសន្ទានុក្រម

### ក). វចនានុក្រម

១). សម្តេចសង្ឃរាជ **ជួន ណាត** វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៦៧ ។

២). លោក **ភូ ឡាយស៊ុន** និងលោក **ភូ វួចចេង** វចនានុក្រមច្បាប់ខ្មែរ-អង្គគ្លេស បោះពុម្ពលើកទី១ ឆ្នាំ២០១២ ។

### ខ). សន្ធានុក្រម

១). ឧបនាយករដ្ឋមន្ត្រី រដ្ឋម្រ្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី **សុខ អាន** សន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ បោះពុម្ពផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ២០១១ ។

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រឡាបញ្ជី: [redacted]
បន្ទប់:.......ជាន់ទី.....

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ............
ចុះថ្ងៃទី ........ ខែ .......... ឆ្នាំ ២០១៦

# <u>ដីកាកោះ</u>

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

អញ្ជើញឈ្មោះ **កកកកកកក** ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅ ផ្ទះគ្មានលេខ ផ្លូវលំ៥ ភូមិទ្រា៥ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

ឲ្យចូលទៅកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី......ខែ..........ឆ្នាំ២០១៦ វេលាម៉ោង ០៩និង៣០នាទី ដើម្បី **សាកសួរ** ពីដំណើររឿង **ហិង្សាដោយចេតនា** តាមបណ្ដឹងរបស់ឈ្មោះ **ខខខខខខខខ** ភេទប្រុស អាយុ ២៨ឆ្នាំ។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ធ្វើនៅភ្នំពេញ, ថ្ងៃទី........ខែ...........ឆ្នាំ២០១៦

**ជ.ព្រះរាជអាជ្ញា**

យើង ....................................................................................................
បានប្រគល់លិខិតអញ្ជើញនេះអោយឈ្មោះ ..................................................................
ទីលំនៅសព្វថ្ងៃ ........................................................ ផ្លូវ ....................... ភូមិ .........................
ឃុំ-សង្កាត់ ............................. ស្រុក-ខណ្ឌ .............................. ខេត្ត-រាជធានី .......................
នៅថ្ងៃទី .......... ខែ .............. ឆ្នាំ ................. ផ្ទាល់រួចហើយ ដោយយើងបានទុកចុងដីកានេះមួយច្បាប់ អោយសាមីខ្លួន ហើយប្រាប់ថាអោយសាមីខ្លួន ប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលខ្លួនចូលទៅដល់តុលាការ ឬអយ្យការ។

**អ្នកទទួលលិខិត** **អ្នកប្រគល់**

ហត្ថលេខា ឬ ផ្តិតម្រាមដៃ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្ត
.....................................
លេខ:.............................

## ដីកាបង្គាប់ឲ្យស៊ើបអង្កេតបឋម

យើង...............ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត កណ្ដាល ។

- បានឃើញរបាយការណ៍លេខ........../..........ចុះថ្ងៃទី........ខែ............ឆ្នាំ.................. របស់អង្គភាពកាំកុងត្រូលខេត្ត............................។
- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ.............ចុះថ្ងៃទី.......ខែ..........ឆ្នាំ..................។
- បានឃើញមាត្រា...............នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ ។

### <u>សម្រេច</u>

១-បង្គាប់ឲ្យអង្គភាពកាំកុងត្រូតខេត្ត..........................បើកការស៊ើបអង្កេតបឋមលើករណីឈ្មោះ................ ហើយឲ្យឈ្មោះ.............បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី ។

២-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្ត..................។

ធ្វើនៅរាជធានី/ខេត្ត,ថ្ងៃទី.............ខែ............ឆ្នាំ............

**ព្រះរាជអាជ្ញារង**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
....................................
លេខៈ............................

## ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង ........................ព្រះរាជាអាជ្ញាការអមសាលាដំបូងរាជធានី/ខេត្ត..................... ។

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ..............ចុះថ្ងៃទី..........ខែ.........ឆ្នាំ................ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា ។

**១. អវត្តមានបទល្មើស**

☐ ១.១. អវត្តមានបទល្មើស

**២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់**

☐ ២.១. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

**៣. មូលហេតុគតិយុត្ត**

☐ ៣.១. ការដកពាក្យបណ្តឹង

☐ ៣.២. ការលើកលែងទោសជាទូទៅ

☐ ៣.៣. មរណភាពជនល្មើស

☐ ៣.៤. ការផុតអាជ្ញាយុកាល

☐ ៣.៥. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

☐ ៣.៦. អាជ្ញាអស់ជំនុំ

☐ ៣.៧. ការសម្រុះសម្រួលជាមួយរដ្ឋ

☐ ៣.៨. ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្រុះសម្រួល

☐ ៣.៩. អភ័យឯកសិទ្ធិ

- ☐ ៣.១០. អនិយ័តភាពនៃនីតិវិធី
- ☐ ៣.១១. ការរួចផុតពីការទទួលខុសត្រូវរបស់[១]

**៤. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍**

- ☐ ៤.១. ការស្វែងរកមិនបានផល
- ☐ ៤.២. ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[២]
- ☐ ៤.៣. ស្ថានភាពវិបល្លាសស្មារតីដែលបន្តយនូវការដឹងខុសត្រូវ
- ☐ ៤.៤. ការខកខានរបស់ដើមបណ្តឹង
- ☐ ៤.៥. អាកប្បកិរិយារបស់ជនរងគ្រោះ
- ☐ ៤.៦. ជនរងគ្រោះមិនចាប់អារម្មណ៍ និងបទល្មើស
- ☐ ៤.៧. និយ័តកម្មដោយឯកឯង[៣]
- ☐ ៤.៨. ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

**៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា**

- ☐ ៥.១. ការជួសជុលការខូចខាតដោយ/ដល់អនីតិជន
- ☐ ៥.២. សន្ធានកម្ម[៤]
- ☐ ៥.៣. អធិបញ្ញាផ្តល់ការព្យាបាល
- ☐ ៥.៤. ជនគ្រោះ/ដើមបណ្តឹងបោះបង់បណ្តឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា
- ☐ ៥.៥. និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា
- ☐ ៥.៦. ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[៥]
- ☐ ៥.៧. ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាព នៃសង្គម ឬវិជ្ជាជីវៈ
- ☐ ៥.៨. ការសម្រុះសម្រួលព្រហ្មទណ្ឌ[៦]

---

១) ដូចជាមូលហេតុ វិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

២) ដើមបណ្តឹងឈប់ប្តឹង

៣) សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និង ស្តារស្ថានភាពឡើងវិញ

៤) ករណីចែងដោយច្បាប់

៥) ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើស តាមកំណត់ច្បាប់ និងធ្វើការព្រមានឲ្យឈប់ប្រព្រឹត្ត

៦) ករណីចែងដោយច្បាប់

**៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗ**

☐ ៦.១. ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

**៧. ជនល្មើសមិនត្រូវបានស្គាល់**

☐ ៧.១. ជនល្មើសមិនត្រូវបានស្គាល់

**៨. ជំនួយការអប់រំ**

☐ ៨.១. ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការសង្កេតផ្សេងៗ៖** កាលពីថ្ងៃទី..............................................................................

..............................................................................................................................

..............................................................................................................................

**បានឃើញ:**

- កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងឈ្មោះ
- កំណត់ហេតុស្តាប់ចម្លើយជនសង្ស័យឈ្មោះ ។
- ពាក្យស្នើសុំដកបណ្តឹងរបស់ឈ្មោះ ចុះថ្ងៃទី...............ខែ.............ឆ្នាំ...............។

**យល់ឃើញថា:**

- តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ

**ហេតុដូច្នេះ សម្រេច**

- តម្កល់រឿងព្រហ្មទណ្ឌលេខ ...............ថ្ងៃទី...............ខែ.............ឆ្នាំ.................។

ទុកឥតចាត់ការតទៅ ។

ធ្វើនៅរាជធានី-ខេត្ត, ថ្ងៃទី........ខែ.........ឆ្នាំ..........

**ព្រះរាជអាជ្ញារង**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
................................
លេខ:........................

## ដីកាតម្កល់រឿងទុកឥតចាត់ការ "១"

យើង.....................................ព្រះរាជអាជ្ញាអមតុលាការរាជធានី/ខេត្ត........................។
- បានឃើញពាក្យបណ្តឹង ឬសំណុំរឿងព្រហ្មទណ្ឌលេខ.................................................
ចុះថ្ងៃទី..................ខែ................ឆ្នាំ................ដែលមានដំណើររឿងដូចតទៅ.................
....................................................................................................................
....................................................................................................................
- បានឃើញ.......................................................................................................
....................................................................................................................
ក្រោយពីពិនិត្យសំណុំរឿង........................................................................................
យល់ឃើញថា "២"...............................................................................................
....................................................................................................................
ហេតុដូច្នេះ សម្រេចតម្កល់រឿងទុកឥតចាត់ការតទៅ ។

ធ្វើនៅ.........ថ្ងៃទី..........ខែ.........ឆ្នាំ.........

**ព្រះរាជអាជ្ញា**

---

**កំណត់សម្គាល់**

"១" ដីកាសម្រេចនេះគ្មានអាជ្ញាជាសេចក្តីសម្រេចដាច់ខាតនៅឡើយទេ អាចប្រែប្រួលបានកុំឲ្យដកបណ្តឹងអាជ្ញាត្រូវរលត់ដោយផុតអាជ្ញាយុកាល ។

"២" រឿងមិនចូលជាបទល្មើសព្រហ្មទណ្ឌ រដ្ឋប្បវេណី " ពាណិជ្ជកម្ម រដ្ឋបាល " ការងារ ។ ល ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម

សាលាដំបូងខេត្ត

................................

លេខ:.........................

**<u>ដីកាសម្រេចរំលត់បណ្តឹងអាជ្ញា</u>**

យើង...........................................ព្រះរាជអាជ្ញាអមសាលាដំបូងតុលាការខេត្ត-ក្រុង................។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ................ចុះថ្ងៃទី............ខែ...............ឆ្នាំ.......................

-បានឃើញសំណុំរឿងស៊ើបសួរលេខ................ចុះថ្ងៃទី...............ខែ.................ឆ្នាំ......................

<u>បានឃើញ</u>:..........................................................................................................

...........................................................................................................................។

<u>យល់ឃើញថា</u>:......................................................................................................

...........................................................................................................................។

**<u>ហេតុដូច្នេះសម្រេច</u>**

១.រំលត់បណ្តឹងអាជ្ញាលើឈ្មោះ.........................អាយុ............ជនជាតិ...................................

...........................................................................................................................

...........................................................................................................................

២.វត្ថុតាង:.............................................................................................................

...........................................................................................................................

៣.ជូនសំណុំរឿងព្រហ្មទណ្ឌលេខ....................ចុះថ្ងៃទី.............ខែ..............ឆ្នាំ.........................

ទាំងអស់ ទៅតុលាការខេត្ត-ក្រុង.............................ដើម្បីចាត់ការច្បាប់អំពីសំណាងជម្ងឺចិត្ត។

ធ្វើនៅ.............................ថ្ងៃទី................ខែ..............ឆ្នាំ................

**ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ......................ចុះថ្ងៃទី..........

ខែ....................ឆ្នាំ......................

សំណុំរឿងព្រហ្មទណ្ឌលេខ ..........

ចុះថ្ងៃទី.......ខែ ឧសភា ឆ្នាំ ២០១៦

## សេចក្ដីសុំប្ដឹងតវ៉ា

ឆ្នាំពីរពាន់.............................................ខែ...............................ថ្ងៃទី..........................................

វេលាម៉ោង...................................................................................................................................។

យើង.....................................................ក្រឡាបញ្ជី អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញឈ្មោះ.........................................................................................................................

ចូលមកចំពោះមុខយើង នៅការិយាល័យក្រឡាបញ្ជីនៃ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហើយ សុំប្ដឹង..............................និង......................................................លេខ............................................

ចុះថ្ងៃទី..........................ខែ..............................ឆ្នាំ............................ត្រង់ចំណុចៈ............................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

ឈ្មោះនេះទទួលថានឹងធ្វើពាក្យបណ្ដឹងបន្ថែម ឲ្យទាន់ពេលវេលា។

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្ដីនេះ ឲ្យឈ្មោះ........................................................................ ស្ដាប់ហើយ ឲ្យចុះហត្ថលេខា ឬ "ផ្ដិតមេដៃ" ជាមួយយើង។

**អ្នកប្ដឹង** **ក្រឡាបញ្ជី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម

សាលាដំបូងខេត្ត

................................

លេខ:.........................

# លិខិតជូនដំណឹង

យើង..................ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី/ខេត្ត.........................

ជម្រាបមកលោក..............អាយុ.............ជនជាតិ.........មុខរបរ....................... មានទីលំនៅផ្ទះលេខ...........ផ្លូវលេខ................ភូមិ............សង្កាត់................ខណ្ឌ.................... រាជធានី/ខេត្ត......................។

ត្បិតសុំរឿងព្រហ្មទណ្ឌលេខ...................ចុះថ្ងៃទី.............ខែ............ឆ្នាំ............. ករណី......................នៅចំណុចផ្លូវ.............កែងផ្លូវ............សង្កាត់.............ខណ្ឌ................. រាជធានី/ខេត្ត........................... កាលពីថ្ងៃទី.............ខែ.............ឆ្នាំ...............នោះយើងបាន សម្រេចតម្កល់រឿងទុកឥតចាត់ការ តាមដីកាសម្រេចរំលត់បណ្តឹងអាជ្ញាលេខ......................ចុះថ្ងៃទី ..........................ខែ...................ឆ្នាំ...................។

រាជធានី/ខេត្ត,ថ្ងៃទី..............ខែ..............ឆ្នាំ.................

**ជ.ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ អ.យ.ណ

**<u>ដីកាអម</u>**

**<u>សូមគោរពជូន</u>**

**ឯកឧត្តម អគ្គព្រះរាជអាជ្ញា មហាអយ្យការអមសាលាឧទ្ធរណ៍**

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| **០១** | -សំណុំរឿងព្រហ្មទណ្ឌលេខ ............... ចុះថ្ងៃ ទី០២ ខែវិច្ឆិកា ឆ្នាំ២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ | ០១ រឿង | |
| | | | |
| | **សរុប** | ០១ រឿង | |

រាជធានីភ្នំពេញ, ថ្ងៃទី ខែកញ្ញា ឆ្នាំ២០១៥

**ជ.ព្រះរាជអាជ្ញា**